មានអត្ថបទគម្ពីរជាច្រើនដែលជំរុញយើងឲ្យហាត់ប្រើគំនិតរបស់យើងក្នុងរបៀបដូច្នេះ ។ នេះគឺជាបទគម្ពីរមួយចំនួនតូច ។ ១ ថែស្សាឡូនីច ៥:១៩-២១ ផ្ដល់ចម្លើយដ៏មានគតិបណ្ឌិតមួយដល់យើង នៅពេលដែលយើងប្រឈមមុខជាមួយសេចក្ដីបង្រៀនថ្មី ( ឬទំនាយផ្សេងៗ )។ ទីមួយសូមកុំធ្វើជាមិនដឹងមិនឮអំពីការនេះ ( ឬ សូមកុំពន្លត់ភ្លើងរបស់ព្រះវិញ្ញាណដោយចាត់ទុកការនេះថាជារឿងគួរឲ្យខ្ពើមឆ្អើម ) ឲ្យសោះ ។ ប៉ុន្តែទីពីរសូមកុំឲ្យត្របាក់លេបការនេះដោយគ្មានការគិតពិចារណាឲ្យសោះ ។ ផ្ទុយទៅវិញសូមល្បងលមើលន័យសេចក្ដីរបស់ការបង្រៀន ឬ ទំនាយនោះ។ ទីបី សូមក្ដាប់យកអ្វីដែលអ្នកយល់ថាជាការល្អចេញពីការបង្រៀននោះ ហើយត្រូវវាត់ចោលនូវអ្វីដែលខុស ឬ អ្វីដែលមិនល្អ។

មជ្ឈដ្ឋានអ្នកស្ដាប់ដែលដើរតាមវិធីនេះ គឺជនជាតិយូដា នៅក្រុងបេរា [១]។ ពេលដែលប៉ូល និង លោកស៊ីឡាសនាំយកដំណឹងស្ដីអំពីព្រះយេស៊ូទៅប្រាប់ពួកគេជាលើកដំបូងនោះ អ្នកក្រុងបេរាមិនមែនមិនអើពើចំពោះការណ៍នេះឡើយ។ ប៉ុន្តែពួកគេក៏មិនទទួលយកដំណឹងនេះទាំងងឹតងងល់ដោយឥតបើគិតដែរ ។ ពួកគេបែរជាស្ដាប់ព្រះរាជសារដោយចិត្តសំភីហើយឆែកពិនិត្យថាតើការបង្រៀននោះស្របតាមបទគម្ពីរ ឬក៏អត់។ ពួកគេប្រៀបធៀបព្រះរាជសារថ្មីរបស់ប៉ូលជាមួយនឹងបទគម្ពីរ។ លទ្ធផលដែលកើតឡើងពីការនោះគឺមានមនុស្សជាច្រើនទទួលជឿ។

យើងមិនគ្រាន់តែត្រូវការគំនិតរឹងប៉ឹងក្នុងការជួយយើងឲ្យចេះជ្រើសរើសយកជំនឿគ្រីស្ដបរិស័ទ ឬ ជំនឿអ្វីមួយផ្សេងទៀតតែប៉ុណ្ណោះទេ។ ក្រោយពីយើងបានក្លាយជាគ្រីស្ដបរិស័ទហើយ យើងក៏ត្រូវការបែងចែកឲ្យដឹងថាក្រុមណាមួយជាក្រុមគ្រីស្ដបរិស័ទពិតប្រាកដត្រឹមត្រូវតាម បទគម្ពីរ និង ក្រុមណាជាក្រុមដែលអះអាងថាខ្លួនជាគ្រីស្ដបរិស័ទតែយល់ច្រឡំប្រើប្រាស់ព្រះគម្ពីរមិនបានត្រឹមត្រូវ ។ សាវ័កយ៉ូហានបានព្រមានអ្នកអានសំបុត្ររបស់គាត់ថា ៖" សូមកុំជឿអស់អ្នកដែលថាខ្លួនមានព្រះវិញ្ញាណគង់នៅជាមួយនោះឡើយ ត្រូវល្បងលមើលដើម្បីឲ្យដឹងថាវិញ្ញាណនេះមកពីព្រះជាម្ចាស់មែន ឬ យ៉ាងណា ដ្បិតមានព្យាការីក្លែងក្លាយជាច្រើនបានមកក្នុងលោកនេះ[២] ។ គ្រីស្ដបរិស័ទអាចនឹងមានគ្រោះថ្នាក់ដោយ" លះបង់ចិត្ត ស្មោះសរ និង ចិត្តបរិសុទ្ធចំពោះព្រះគ្រីស្ដ" ហើយទៅដើរតាម" ព្រះយេស៊ូណាមួយផ្សេងទៀតក្រៅពីព្រះយេស៊ូដែលយើង ( ពួកសាវ័ក ) ប្រកាសនោះ[៣] ឬ ងាកចេញពី" ព្រះជាម្ចាស់ដែលបានត្រាស់ហៅបងប្អូនមកតាមព្រះគុណរបស់ព្រះគ្រីស្ដ

---

[១] *កិច្ចការ ១៧:១០-១៥*

[២] *យ៉ូហាន ៤:១*

[៣] *២កូរិនថូស ១១: ៣-៤*

ហើយបែរទៅរកដំណឹងល្អមួយផ្សេងទៀតដែលមិនមែនជាដំណឹងល្អទាល់តែសោះ"[៤] ។ គ្រីស្ទបរិស័ទ ត្រូវតែឈប់គិតតាមរបៀបកូនក្មេងទៀតគឺត្រូវគិតតាមរបៀបមនុស្សចាស់វិញ [៥] ។

សមត្ថភាពក្នុងការមើលឲ្យឃើញភាពខុសប្លែកគ្នារវាងសេចក្តី ពិត និង សេចក្តីខុសឆ្គង ឬ មួយណាល្អជាងមួយណាល្អដាច់គេ មិនមែនចេះកើតឡើងចំពោះយើងភ្លាមមួយរំពេច ហើយកើតឡើងតែម្តងជាសំរេចនោះទេ។ តែការនេះច្រើនតែកើតឡើងជាបន្តបន្ទាប់ហើយកាន់តែដុះខាត់យើងឲ្យភ្លឺថ្លាឡើងអស់មួយជីវិតយើងមិនថាយើងជាបុគ្គលម្នាក់ ដាច់ដោយឡែកមិនថាយើងរួមគ្នាជាក្រុមជំនុំនោះឡើយ។ ដោយហេតុថា ដូច្នេះបានជាលោកប៉ូលអធិស្ឋានឲ្យក្រុមជំនុំនៅក្រុងភីលីព" មានសេចក្តីស្រឡាញ់ដ៏លើសលប់កាន់តែខ្លាំងឡើងៗធ្វើឲ្យគេចេះដឹងច្បាស់ និង យល់សព្វគ្រប់ទាំងអស់"[៦]។ នៅក្នុងខគម្ពីរនេះ ការសង្កេតស្គាល់មានន័យថាជាការជ្រើសរើសយកអ្វីដែលល្អបំផុតនៅពេលដែលយើងមានអ្វីៗដែលល្អជាច្រើនសំរាប់ជ្រើសរើស ប៉ុន្តែមានមួយដែលល្អដាច់គេសំរាប់ឲ្យយើងជ្រើសរើស។ ក្នុងករណីបែបនេះ យើងចាំបាច់ត្រូវតែនិយាយថា "ទេ" ចំពោះអ្វីណាដែលគ្រាន់តែល្អហើយនិយាយថា"បាទ ឬ ចាស" ចំពោះអ្វីណាដែលល្អដាច់គេ ។ ចំណុចដែលខ្ញុំចង់លើកមកបង្ហាញនៅពេលនេះគឺជំនឿគ្រីស្ទបរិស័ទហៅយើងឲ្យមានកំឡាំងនៃគំនិតជាច្រើនបែបច្រើនយ៉ាងដើម្បីសង្កេតឲ្យស្គាល់សេចក្តីពិតជំនឿគ្រីស្ទបរិស័ទមិន ចេះតែធ្វើពើជាអ្វីៗទាំងអស់សុទ្ធតែស្មើគ្នានោះឡើយ។

---

*[៤]កាឡាទី ១ :៦-៧*
*[៥]១ កូរិនថូស ១៤:២០*
*[៦]ភីលីព ១:៩*

### ភាពដាច់ខាត

ក្រោយពីយើងរកឃើញថាអ្វីជាសេចក្ដីពិតរួចហើយ ព្រះជាម្ចាស់មិនសព្វព្រះហឫទ័យឲ្យគ្រីស្ទបរិស័ទដាក់ចិត្តតែពាក់កណ្ដាលចំពោះសេចក្ដីពិតនោះឡើយ ។ ព្រះគម្ពីរពឹងលើយើងដែលចេះប្ដូរផ្ដាច់យ៉ាងរឹងប៉ឹង យ៉ាងម៉ឺងម៉ាត់ និងយ៉ាងច្បាស់លាស់ ។ ជំនឿគ្រីស្ទបរិស័ទដែលស្របតាម បទគម្ពីរមិនមែនជាជំនឿម៉ាៗយកសឹងនោះទេ។

បទគម្ពីរខ្លះទៀតឲ្យយោបល់យើងថា ព្រះចង់បានគ្រីស្ទបរិស័ទដែលរឹងប៉ឹងក្នុងការប្ដូរផ្ដាច់ ( ទោះបីពេលខ្លះការប្ដូរផ្ដាច់នោះអាចខុសឆ្គងក៏ដោយ )ជាជាងគ្រីស្ទបរិស័ទដែលមិនចេះអារកាត់ ។ យ៉ូស្វេចង់ឲ្យជនជាតិអ៊ីស្រាអែលជ្រើសរើសយកព្រះណាមួយជាជាងអត់ព្រះ ទោះបីព្រះនោះមិនមែនជាព្រះយេហូវ៉ាក៏ដោយ [៧] ។ លោកអេលីយ៉ាជំរុញជនជាតិអ៊ីស្រាអែលដែលស្ទើរស្ទាក់ឲ្យគោរពបំរើព្រះបាល បើព្រះបាលនោះជាព្រះយ៉ាងពិតប្រាកដមែនប្រសើរជាងនៅរវេរវកអល់អែកមិនចេះធ្វើការអារកាត់អ្វីទាល់តែសោះ[៨] ។ ព្រះយេស៊ូប្រាថ្នាចង់ឃើញក្រុមជំនុំនៅក្រុងឡៅឌីសេមានចិត្តក្ដៅគគុក ឬ ត្រជាក់ស្រេបប្រសើរជាងក្ដៅឧណ្ហៗ [៩] ។ បើការរស់ឡើងវិញរបស់យើងមិនអាចក្លាយទៅជាការពិតទេយើងគួរតែ" ស៊ីផឹកអ្វីបានតាមចិត្តព្រោះគង់តែស្លាប់នៅថ្ងៃស្អែកដដែល"[១០] ។ បើយើងចង់រស់មានន័យមានខ្លឹមសារសំរាប់ព្រះរាជ្យរបស់ព្រះជាម្ចាស់យើងត្រូវតែ "លះបង់ខ្លួនឯង លះបង់សាច់ញាតិសន្ដានចិត្តលី

---

[៧] *យ៉ូស្វេ ២៤:១៤-១៥*

[៨] *១ ពង្សាវតារ ១៨:២១*

[៩] *វិវរណៈ ៣:១៥*

[៧] *យ៉ូស្វេ ២៤:១៤-១៥*

[៨] *១ ពង្សាវតារ ១៨:២១*

[៩] *វិវរណៈ ៣ :១៥*

[១០] *១ កូរិនថូស ១៥: ៣០*

ឈើឆ្កាង ហើយដើរតាមព្រះគ្រីស្ទ"[១១]។ ភាពមានន័យមិនដែលកើតឡើង ចំពោះព្រលឹងដែលមិនចេះអារកាត់គឺអ្នក ដែលដៃចាប់កាន់យាមនង្គ័លហើយ ភ្នែកចេះតែសំឡឹងមើលក្រោយ[១២]។ ការធ្វើជាគ្រីស្ទបរិស័ទមែន មិនមែនធ្វើជាគ្រីស្ទបរិស័ទផងថ្វាយបង្គំអារុក្ខអារក្ខ អ្នកតាផង ឬ ថ្វាយបង្គំព្រះពុទ្ធផងក្នុងពេលជាមួយគ្នានោះទេ។

---

*[១១] លូកា ៩:២៣-២៧ ;១៤:២៦ -២៧ ពាក្យ "ស្រឡាញ់ "និង "ស្អប់" ជួនកាលត្រូវគេប្រើនៅក្នុងព្រះគម្ពីរមិនមែន ដើម្បីបកស្រាយពី អារម្មណ៍ស្រឡាញ់ពេញចិត្ត ឬ ស្អប់ខ្ពើមនោះឡើយ ប៉ុន្តែជាសញ្ញាមិនលំអៀងនៃការ "ជ្រើសរើស ឬ បដិសេធ ។ ដូច្នេះក្នុងម៉ាឡាគី ១:២-៥ ព្រះជាម្ចាស់ " ស្រឡាញ់ " យ៉ាកុបតែព្រះអង្គ "ស្អប់ " អេសាវ គឺមានន័យដូច្នេះឯង ។ រឿងនេះជារឿងដែលហាក់ដូចជាពាក់ព័ន្ធដល់ការជ្រើសរើសច្រើនជាងរឿងនៃមនោសញ្ចេតនា ។ លោកប៉ូលបានបញ្ជាក់ពីរឿងនេះយ៉ាងច្បាស់នៅក្នុងរ៉ូម៩:១០-១៣ ថា មុនពេលដែលកូនភ្លោះទាំងប្រសូតចេញមក "ព្រះជាម្ចាស់មានគំរោងការជ្រើសរើសមនុស្សដោយមិនគិតពីអំពើ ដែលគេប្រព្រឹត្តនោះទេគឺ ជ្រើសរើសតាមព្រះហឫទ័យរបស់ព្រះអង្គដែលត្រាស់ហៅ ។ ដើម្បីឲ្យបានស្របតាមគំរោងការ នេះ នៅពេលកូនភ្លោះ នៅក្នុងផ្ទៃពុំទាន់បានប្រព្រឹត្តអំពើ ល្អ ឬ អាក្រក់នៅឡើយផងនោះ ។ ទ្រង់ក៏មានព្រះបន្ទូលទៅនាង រេបេកាថា កូនច្បង នឹងបំរើកូនប្អូន" ដូចមានចែងទុកមកពី " យើងស្រឡាញ់យ៉ាកុបជាងអេសាវ " ( មានន័យថាបដិសេធ ចេញពីភាពជាដៃគូ ក្នុងសម្ព័ន្ធមេត្រី ) ។ ដូចគ្នាដែរព្រះយេស៊ូ មិនបានលើកទឹកចិត្តសាវកព្រះអង្គឲ្យស្រឡាញ់លុយឡើយ ។ សុភាសិតក៏មាននិយាយជាពិសេសអំពីតម្លៃនៃរឿងនេះដែរ ។ ដោយហេតុថាយើងមិនអាចបំរើចៅហ្វាយពីរបានយើងមុខជាស្អប់មួយ ( បដិសេធមិនបំរើ ) និងស្រឡាញ់មួយ ( ជ្រើសរើសបំរើ ) វិញ ។ ក្នុងលូកាពាក្យ "ស្អប់ " មិនមានន័យជាមនោ សញ្ចេតនាស្អប់ខ្ពើមយ៉ាងខ្លាំង ចំពោះឪពុកម្តាយរបស់យើងនោះទេ ដើម្បីកុំឲ្យប្រទាញ ប្រទង់នឹងបទគម្ពីរផ្សេងទៀតដែលបង្គាប់ឲ្យយើងគោរពឪពុកម្តាយ ។ លះបង់ ឬ លះអាល័យពី ឪពុកម្តាយគឺមិនធ្វើតាមចិត្តគាត់ដែលជំទាស់យើងមិនឲ្យដើរតាមព្រះគ្រីស្ទតែប៉ុណ្ណោះ។*

*[១២] លូកា ៩:៦២*

## ការប្រព្រឹត្តិ

ក្រោយពីបានប្រើប្រាស់កំឡាំងដ៏សំខាន់នៃគំនិត ដើម្បីសង្កេតឲ្យស្គាល់សេចក្តីពិត និងកំឡាំងដាច់ណាត់នៃឆន្ទៈ ក្នុងការកាន់តាមសេចក្តីពិតនេះគ្រីស្តបរិស័ទត្រូវ បានទទួលការជំរុញចិត្តឲ្យបង្ហាញកំឡាំងសកម្មនៃការប្រព្រឹត្តិ។ គ្រីស្តបរិស័ទត្រូវតែរស់ដើម្បីសេចក្តីពិត។

ទីមួយ រឿងនេះជារឿងពិតសំរាប់ជីវិតមនុស្សទូទៅ ។ ប៉ុន្តែព្រះគម្ពីរទាមទារជាពិសេសឲ្យសហគមន៍គ្រីស្តបរិស័ទក្រោកឈរឡើងជំទាស់នឹងទស្សនៈមិនត្រឹមត្រូវរបស់សាសនា ។រឹងប៉ឹងក្នុងសេចក្តីពិតរាប់បញ្ចូលទាំងភាពរឹងប៉ឹងប្រឆាំងនឹងការមិនត្រឹមត្រូវ ។ ពេលដែលជនជាតិយូដាខ្លះព្យាយាមចង់បង្ខិតបង្ខំគ្រីស្តបរិស័ទសាសន៍ដទៃឲ្យទទួលពិធីកាត់ស្បែក ហើយគោរពតាមក្រឹត្យវិន័យក្នុងគម្ពីរសម្ពន្ធមេត្រីចាស់នោះ លោកប៉ូល និង លោកបាណាបាស ប្រកែកប្រណាំងគ្នាយ៉ាងតឹងសសៃក[១៣] ។ ការបង្រៀនខុសឆ្គងរបស់ជនជាតិយូដាកក្កូរកកាយចិត្តរបស់ពួកសាវ័កឲ្យចាំបាច់ត្រូវតែបង្ហាញជាបន្ទាន់ឲ្យពួកយូដាឃើញថាការបង្រៀននោះមិនមែនខុសឆ្គងដោយសារវាគ្រាន់តែជា គំនិតខុសប្លែកគ្នាដោយគ្មានកំហុស ចំពោះរឿងមួយដែលពុំសូវជាសំខាន់ប៉ុន្មាននោះទេ គឺជំនឿនោះអាចនឹង បំផ្លាញជំនឿរបស់បុគ្គលម្នាក់ៗ ឬក្រុមគ្រួសារគាត់ទាំងមូលបាន[១៤]។ មានតែត្រូវឃ្លាំពិនិត្យមើលគោលលិទ្ធិរបស់ខ្លួនឲ្យបានដិតដល់នោះទេទើបអ្នកបំរើរបស់ព្រះអម្ចាស់អាចសង្គ្រោះទាំងខ្លួនឯងផង និងទាំងមជ្ឈដ្ឋានអ្នកស្តាប់របស់ខ្លួនផងបាន[១៥]។ អ្នកដឹកនាំក្រុមជំនុំជំនាន់ដើមជាបន្តបន្ទាប់ហាក់ដូចជាមិនសូវជាស្វាគមន៍គោលលិទ្ធិ និង ការប្រតិបត្តិជំនឿខុសឆ្គងប៉ុន្មានទេ ប៉ុន្តែពួកគាត់ជំទាស់ប្រឆាំងនឹងការទាំងអស់នេះ

---

[១៣] *កិច្ចការ ១៥:២*

[១៤] *២ ធីម៉ូថេ ២:១៨; ទីតុស ១:១១*

[១៥] *១ ធីម៉ូថេ ៤:១៦*

យ៉ាងខ្លាំងក្លា គឺហ៊ានរហូតដល់ថ្នាក់ជំទាស់ប្រឆាំងចំពោះអគ្គសាវ័កពេត្រុស ទៀតផង[១៦]។ ព្រះអម្ចាស់ដែលទទួលការតម្កើង សិរីរុងរឿងសរសើរក្រុមជំនុំក្រុងអេភេសូ ដែលហ៊ានជំទាស់ប្រឆាំងចំពោះសាវ័កក្លែងក្លាយ តែផ្ទុយទៅវិញព្រះអង្គបន្ទោសក្រុមជំនុំក្រុងពើកាម៉ុស ដែលបើកឲ្យគ្រូដែលប្រកាន់ទស្សនៈតាមសេចក្តីបង្រៀនរបស់បាឡាម និង នីកូឡាស ចូលមកបង្រៀន ។ ព្រះអង្គក៏បន្ទោសក្រុមជំនុំក្រុងធាតេរ៉ា ដែលអនុគ្រោះព្យាការីនីម្នាក់ដែលហៅខ្លួនឯងថា យេសេបិលទៀតផង[១៧]។ ការបែកចេញពីគោលលិទ្ធិដែលត្រឹមត្រូវពិតប្រាកដអាចនាំឲ្យយើងបាត់រង្វាន់រីឯការបើកទ្វារឲ្យគេចូលមកបង្រៀនគោលលិទ្ធិមិនត្រឹមត្រូវ គឺជាការចូលដៃចូលជើងក្នុងការអាក្រក់របស់ពួកគេ [១៨]។ អ្នកដឹកនាំក្រុមជំនុំជំនាន់ដើមបង្ខំចិត្តជំរុញគ្រីស្តបរិស័ទដែលដើរតាមខ្លួនឲ្យ" តយុទ្ធការពារជំនឿដែលព្រះជាម្ចាស់បានប្រទានដល់ប្រជាជនដ៏វិសុទ្ធម្តងជាសូរេច" [១៩]។

និយាយឲ្យខ្លីទៅគឺថា៖ សេចក្តីពិត និង សេចក្តីខុសឆ្គងនៅក្នុងសេចក្តីបង្រៀនទាំងឡាយផ្នែកសាសនានោះគឺជាបញ្ហាសំខាន់ ។ គ្រីស្តបរិស័ទដែលដើរតាមគំរូរបស់ព្រះគម្ពីរគឺត្រូវតែមានគំនិតរឹងប៉ឹងដើម្បីសង្កេតមើលដឹងពីសេចក្តីពិតមានឆន្ទៈរឹងប៉ឹងដើម្បីចិត្តប្តេជ្ញាចិត្តយ៉ាងមុតមាំចំពោះជំនឿ និង មានភាពរឹងប៉ឹងក្នុងការប្រព្រឹត្តិដើម្បីលើកស្ទួយសេចក្តីពិត និង ហ៊ានតតាំងចំពោះសេចក្តីខុសឆ្គង ។ បុរសខ្លាំងតាមពិតទៅបង្ហាញចំណុចខ្លាំងរបស់ខ្លួននៅក្នុងផ្នែកមួយនៃការដឹកនាំ និង ពន្ធកិច្ចរបស់គ្រីស្តបរិស័ទ។

---

[១៦] *កាឡាទី ២:១១-២១*

[១៧] *វិវរណៈ ២: ២; ២០*

[១៨] *២ យ៉ូហាន ៧-១១*

[១៩] *យូដាស ៣*

## ព័ន្ធកាវីគ្រីស្ទបរិស័ទៈ ទន់ភ្លន់ជាមួយមនុស្សទូទៅ

ប៉ុន្តែតើបុរសខ្លាំងត្រូវខ្លាំងតាំងពីដើមដល់ចប់ឬ ? ជាពិសេសតើយើងត្រូវបង្ហាញពីកម្លាំងរបស់យើងដោយរបៀបណា ? ព័ន្ធកាវីជាគ្រីស្ទបរិស័ទត្រូវតែរឹងប៉ឹងចំពោះសេចក្ដីពិតជានិច្ច ។ ប៉ុន្តែតើឥរិយាបទរបស់គាត់ត្រូវតែដូចមនុស្សទូទៅឬ ?

### គំរូជាទូទៅ

គំរូជាទូទៅគឺភាពទន់ភ្លន់ ។ គឺទន់ភ្លន់ទាំងនៅក្នុងការបញ្ជា និង ក្នុងគំរូផ្ទាល់នៃការដោះស្រាយបញ្ហាផ្សេងៗនៅក្នុងគម្ពីរសញ្ញាថ្មីបានជំរុញលើកទឹកចិត្តឲ្យយើងប្រើភាពទន់ភ្លន់ ជាមធ្យោបាយបង្កើបប្រាប់ពីសេចក្ដី ពិត និង បង្ហាញពីភាពខុសឆ្គង ។ បទគម្ពីរមិនបានលើកទឹកចិត្តយើងមានអំនួត និង ប្រើមធ្យោបាយវាយប្រហារនៅពេលដែលយើងផ្សាយដំណឹងល្អនោះឡើយ។

*២ ធីម៉ូថេ ២ :២៣-២៦* ។២ ធីម៉ូថេនេះប្រហែលជាសំបុត្រចុងក្រោយរបស់សាវ័កប៉ូល។ នៅក្នុងសំបុត្រនោះលោកបានបង្រៀនដល់ពួក សិស្សរបស់លោកពីរបៀបដែលពួកគេត្រូវបន្តការងារបំរើព្រះបន្តទៅទៀត បន្ទាប់ពីពេលដែលការងាររបស់លោកត្រូវបានបញ្ចប់ទៅនោះ ។ សំបុត្រនោះបានបង្ហាញពីគំរូនៃការបញ្ចូលកម្លាំងរឹងប៉ឹងក្នុងសេចក្ដីពិត និងមានចិត្តទន់ភ្លន់ចំពោះមនុស្សទូទៅ ។

នៅអត្ថបទនៃព្រះគម្ពីរត្រង់នេះ យើងឃើញគំរូភាពរឹងប៉ឹងនៃសេចក្ដីពិតបានផុសឡើងនៅពេលដែលលោកប៉ូលមានប្រសាសន៍ថា ព្រះជាម្ចាស់មិនបានប្រទានឲ្យយើងមានវិញ្ញាណដែលនាំឲ្យខ្លាចទេ ។ ហេតុដូច្នេះធីម៉ូថេមិនត្រូវខ្មាសមិនហ៊ាននិយាយពីព្រះអម្ចាស់ឡើយ តែត្រូវតែរឹងប៉ឹងឡើង

ដើម្បីចូលរួមរងការឈឺចាប់ជាមួយលោកប៉ូលក្នុងបុព្វហេតុនៃដំណឹងល្អ[២០]។ គាត់ត្រូវតែរក្សាឲ្យបានខ្ជាប់ខ្ជួននូវសេចក្តីបង្រៀនដ៏ល្អនេះ និង រក្សាទុកឲ្យបានគង់វង្សនូវអ្វីដែលបានផ្ញើទុកនឹងគាត់[២១]។ រីឯប៉ុងនៅក្នុងព្រះគុណព្រះធីម៉ូថេត្រូវហុចបន្តនូវជំនឿគ្រីស្តបរិស័ទដល់អ្នកដទៃ[២២]។ ដោយទទួលខុសត្រូវក្នុងការហុចបន្តដោយត្រឹមត្រូវ[២៣]។ ការផ្តល់គំនិតរបស់គាត់ដោយយកចិត្តទុកដាក់ទៅនឹងសេចក្តីបង្រៀនដ៏ល្អត្រឹមត្រូវគាត់ត្រូវជៀសវាងពីការជជែកវែកញែកដ៏ល្ងីល្ងើផ្តេសផ្តាស[២៤] ។

ប៉ុន្តែតើធីម៉ូថេត្រូវបន្តព័ន្ធកិច្ចនៃការរឹងប៉ឹងចំពោះសេចក្តីពិត នោះដោយរបៀបណា ?

> រីឯអ្នកបំរើរបស់ព្រះអម្ចាស់មិនត្រូវឲ្យការឈ្លោះប្រកែកគ្នាឡើយ ផ្ទុយទៅវិញត្រូវរួសរាយចំពោះមនុស្សទូទៅត្រូវចេះបង្រៀន និង អធ្យាស្រ័យដល់គេត្រូវមានចិត្តស្លូតបូតប្រដៅពួកអ្នកប្រឆាំងក្រែងលោព្រះជាម្ចាស់នឹងប្រោសប្រទានឲ្យគេកែប្រែចិត្តគំនិតដើម្បីឲ្យគេបានស្គាល់ សេចក្តីពិតយ៉ាងច្បាស់ព្រម ទាំងភ្ញាក់ស្មារតីឡើងវិញ ហើយដោះខ្លួនរួចពីអន្ទាក់របស់មារដែលបានចាប់ចងគេបង្ខំឲ្យ ធ្វើតាមបំណងរបស់វា [២៥] ។

ភាសាក្រិកពាក្យបកប្រែ" ឈ្លោះ "មានន័យថាដំបូងឈ្លោះដោយប្រើរូបកាយហើយក្រោយមកប្រើសំដីរបស់យើងគឺ ៖ *ឈ្លោះទាស់ទែងប្រកែក ប្រណាំង*

---

*[២០] ២ ធីម៉ូថេ ១:៧-៨*

*[២១] ២ ធីម៉ូថេ ១:១៣-១៤*

*[២២] ២ ធីម៉ូថេ ២:១-២ ; ១៤*

*[២៣] ២ ធីម៉ូថេ ២:១៥*

*[២៤] ២ ធីម៉ូថេ ២:១៤; ១៦; ២៣*

*[២៥] ២ ធីម៉ូថេ ២:២៤ -២៦*

*ត្ថា* ។ ហេតុដូច្នេះហើយគឺមានន័យធ្ងន់ធ្ងរចំពោះពាក្យ" ទំនាស់" គឺមានការឈឺចុកចាប់ និង ជូរចត់យ៉ាងខ្លាំង ។ អ្នកបំរើព្រះអម្ចាស់មិនត្រូវជាប់ជំពាក់ក្នុងរឿងទាស់ទែងបែបនោះឡើយ ។ តែត្រូវឲ្យមានចិត្ត"សប្បុរស" ដែលជាពាក្យជាភាសាក្រិកក្នុងគម្ពីរសញ្ញាថ្មីប្រើដើម្បីពណ៌នាពីរបៀបដែលម្តាយមើលថែកូនតូចរបស់ខ្លួន [២៦] ។ ម្តាយមិនរហ័សខឹងជាមួយកូនៗឡើយ តែមានចិត្តអំណត់ និង លួងលោមកូន សូម្បីតែនៅពេលដែលគាត់ត្រូវព្យាយាមបង្រៀនអ្វីមួយឲ្យកូនបានដឹង ឬ ត្រូវប្រដៅតម្រង់ ។ ត្រង់នេះបង្ហាញពីរូបភាពដែលគិលានុបដ្ឋាយិកា លួងលោមដល់អ្នកជម្ងឺវ័យក្មេង មិនមែនមានលក្ខណៈដូចបុរសខ្លាំងកំពុងលើកដុំដែកតម្លើងសាច់ដុំនោះឡើយ ម្តាយប្រព្រឹត្តនឹងកូនបែបនោះទើបសមរម្យ ។ លើសពីនេះទៅទៀតព័ន្ធការីគ្រីស្តបរិស័ទមិនត្រូវ "ច្រលោតខឹង" មានន័យថា*អាចអត់ទ្រាំនឹងទុក្ខលំបាកដោយមិនខឹង ឬ មួម៉ៅឡើយ* ។ ការមិនច្រឡោតខឹងអ្នកបំរើព្រះដ៏រឹងមាំនៅក្នុងបទគម្ពីរ បានបង្រៀនដោយសុភាពទន់ភ្លន់ដល់អ្នកដែលប្រឆាំងជាមួយគាត់ ។ ពាក្យ" សុភាពទន់ភ្លន់" មានន័យថា មាន*ឥរិយាបទទន់ភ្លន់ និង អាកប្បកិរិយាមិនឆេវឆាវក្នុងការដោះស្រាយបញ្ហាជាមួយអ្នកដទៃ* ។

នៅក្នុងជំពូក ៤ ចែងបញ្ជាក់ឡើងវិញពីគំរូនៃការរឹងប៉ឹងចំពោះសេចក្តីពិត ហើយសុភាពទន់ភ្លន់ជាមួយមនុស្សទូទៅ ។ តាមទស្សនៈនៃ អំពើឃោរឃៅនៃថ្ងៃចុងក្រោយ និង ការធ្វើទុក្ខបុកម្នេញដែលរង់ចាំពួកអ្នកដែលកោតខ្លាចព្រះ [២៧] ក៏ចូលចិត្តនិយាយទន់ភ្លន់ចំពោះសេចក្តីបង្រៀនត្រឹមត្រូវ [២៨] អ្នកដឹកនាំគ្រីស្តបរិស័ទដែលត្រូវផ្សាយដំណឹងល្អដល់មនុស្សលោក ( គឺថាត្រូវរឹងប៉ឹង

---

[២៦] *១ ថែស្សាឡូនីច ២:៧*
[២៧] *២ ធីម៉ូថេ ៣*
[២៨] *២ ធីម៉ូថេ ៤: ៣-៤*

សំរាប់សេចក្តីពិត )[២៩] ។ គាត់មិនត្រូវព្រមទទួលព្រមតាមវិញ្ញាណអាក្រក់ ឬ វិញ្ញាណនៃសម័យនេះឡើយ ។ ប៉ុន្តែយើងត្រូវសួរម្តងទៀតថាតើគាត់ត្រូវផ្សាយដំណឹងល្អទៅមនុស្សលោកដោយរបៀបណា? "ដោយអំណត់ និង បង្រៀនដោយប្រុងប្រយ័ត្ន" ។ ពាក្យអំណត់បានប្រែថា "ទ្រាំទ្រដោយអត់ធ្មត់ មិនខឹង ឬ មួម៉ៅ" ។ គឺជា" ស្ថានភាពនៃអារម្មណ៍ស្ងប់សុខនៅចំពោះមុខនៃការ អុចអាលបណ្តាលឲ្យខឹង ឬ ការធ្លោយការណ៍អ្វីមួយ និងដោយគ្មានការរអ៊ូរទាំ ឬ ខឹងអ្វីឡើយ"[៣០] ។ ធីម៉ូថេ និង យើងដែលដើរតាមសេចក្តីបង្រៀនរបស់លោក ប៉ូល មិនត្រូវឆាប់ខឹងជាមួយអ្នកដែលប្រឆាំង ជាមួយនឹងយើងឡើយ ប៉ុន្តែត្រូវទ្រាំទ្រចំពោះការរិះគន់ ឬ ចំអកឡកឡឺយពីអ្នកដទៃដោយមិនស្រែកជំទាលស្តីបន្ទោស ឬ ពឹងផ្អែកពាក្យខឹងឯង តែត្រូវឆ្លើយតបទៅគេវិញដោយមានសេចក្តីបង្រៀនដោយប្រុងប្រយ័ត្ន ។ ការប្តេជ្ញាចំពោះសេចក្តីពិតយ៉ាងម៉ឺងម៉ាត់មិនតម្រូវឲ្យយើងតបតជាមួយអ្នកដែលប្រឆាំងនឹងយើងតាមបែបមិនត្រឹមត្រូវនោះឡើយ។ រឹងប៉ឹងចំពោះសេចក្តីពិត ... តែសុភាពទន់ភ្លន់ជាមនុស្សទូទៅ ។

*១ ពេត្រុស ៣:១៥-១៦* ។ ពេត្រុសមានប្រសាសន៍ដូចគ្នានេះដែរ ។ ពេត្រុសចាប់ផ្តើមខគម្ពីរទាំងនេះដោយនិយាយថាអ្នកអានរបស់គាត់ត្រូវ៖ ទី ១). ត្រូវទុកព្រះគ្រីស្ទជាព្រះអម្ចាស់នៅក្នុងដួងចិត្ត ហើយនិងទី ២). ត្រូវត្រៀមជានិច្ច ដើម្បីពន្យល់ និង ការពារសេចក្តីសង្ឃឹមរបស់ខ្លួន ។ ការនេះឯងដែលមានន័យថា រឹងប៉ឹងសំរាប់សេចក្តីពិត គឺរឹងប៉ឹងនៅក្នុងគំនិត ដើម្បីឲ្យអាចពន្យល់ប្រាប់ពីហេតុផលដល់គេ និង រឹងប៉ឹងនៅក្នុងឆន្ទៈដើម្បីឲ្យអាចជ្រើសរើសយកព្រះគ្រីស្ទជាព្រះអម្ចាស់នៅក្នុងជីវិតរបស់ខ្លួន ។

---

[២៩] *២ ធីម៉ូថេ ៤: ២*

[៣០] Johannes P. Louw and Eugene A. Nida, eds., *Greek-English Lexicon of the New Testament based on Semantic Domains* in *Bible Windows 6.0* (Cedar Hill, Texas: Silver Mountain Software, 2001), s.v. μακροθυμια, ας / patience 25.167.

" សុភាពទន់ភ្លន់ជាមួយមនុស្សទូទៅ " ដោយដើរតាមសេចក្តីបង្រៀនរបស់ពួកសាវ័កដែលទាក់ទងទៅនឹងរបៀបរឹងប៉ឹងនេះ ដែលហ៊ានវែកញែករកហេតុផលដើម្បីការពារជំនឿរបស់ខ្លួនគឺ " ដោយសុភាពទន់ភ្លន់ និងដោយគោរពរាប់អាន ..." ។ ចំពោះការ " សុភាពទន់ភ្លន់" លោកពេត្រុសបានលើកឡើងនូវពាក្យសំដីដដែលដូចដែល លោកប៉ូលបានប្រើនៅក្នុង ១ ថែស្សាឡូនិច ២ [៣១]។ ពាក្យ" គោរពរាប់អាន" គឺជាពាក្យដែលគេតែងតែបកប្រែ"គោរពកោតខ្លាច" ។ ពាក្យនោះជួនកាលមានន័យថាភ័យខ្លាចដែលធ្វើឲ្យមនុស្សនោះភ័យរត់គេច ។ ពាក្យនេះក៏គេប្រើដើម្បីពណ៌នាពីការគោរពកោតខ្លាចដល់ព្រះដែរ ។ ដោយព្រោះតែព្រះនោះឯង ទើបមនុស្សបង្ហាញពីការ ខ្លាចស្ញប់ស្ញែង និងគោរពកោតខ្លាច ។ អាកប្បកិរិយាបែបនោះឯងដែលត្រូវប្រកាន់ខ្ជាប់ពេលយើងប្រព្រឹត្តជាមួយមនុស្សដទៃ សូម្បីតែជាមួយមនុស្សដែលបានសួរដេញដោលពីជំនឿគ្រីស្ទបរិស័ទរបស់យើងក៏ដោយ ។ យើងមិនត្រូវនិយាយលេងសើចបែបចំអកឡកឡឺយនិយាយបញ្ឈឺនិយាយឌឺ ឬ សម្តែងអាការៈមិនចាប់អារម្មណ៍ចំពោះគេឡើយ ។ លោកប៉ូលបានណែនាំដូចគ្នានេះដែរ នៅពេលដែលគាត់បង្រៀនថាយើងត្រូវ " បង្ហាញពីការបន្ទាបខ្លួនពិតដល់មនុស្សទាំងអស់" [៣២] ហើយលោកយ៉ាកុប នៅពេលដែលគាត់ព្រមានចំពោះការដាក់បណ្តាសាដល់មនុស្ស [៣៣] ។

---

*[៣១] ពាក្យនោះគេបានប្រើ១១ ដងនៅក្នុងគម្ពីរសញ្ញាថ្មី ១កូរិនថូស ៤:២១: ២កូរិនថូស ១០:១; កាឡាទី ៥:២៣ ; ៦:១: អេភេសូរ ៤:២ កូល៉ុស ៣:១២; ២ធីម៉ូថេ ២:៣៥; ទីតុស ៣:២; យ៉ាកុប ១:២១; ៣:១៣; ១ពេត្រុស៣:១៦ សូមអានក្នុងម៉ាថាយ ៥:៥; ១១:២៩; ២១:៥ និងក្នុង ១ធីម៉ូថេ ៦:១១ ។*

*[៣២] ទីតុស ៣:២*

*[៣៣] យ៉ាកុប ៣:៩-១២*

ហេតុផលនៃការដោះស្រាយបញ្ហាដោយសុភាព

តែហេតុអ្វីចាំបាច់សុភាព ? ហេតុអ្វីបានជាយើងមិនរឹងប៉ឹងនៅក្នុងការដោះស្រាយរបស់យើងជាមួយមនុស្សទាំងពួងគឺ ត្រូវរឹងប៉ឹងដូចដែលយើងត្រូវរឹងប៉ឹងចំពោះសេចក្តីពិតនោះ ? ព្រះគម្ពីរបានផ្តល់នូវការណែនាំមួយចំនួនគឺ ៖

*យើងក៏មានចំណុចខ្សោយដែរ ។* នៅក្នុងការពណ៌នាពីការថ្វាយបង្គំនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ពួកសាសន៍ហេព្រើរបាននិយាយថា ពួកមហាបូជាចារ្យ" អាចដោះស្រាយបញ្ហាយ៉ាងសុភាពជាមួយអស់អ្នកណាដែលអវិជ្ជា និង អ្នកដែលនឹងវង្វេងចេញពីជំនឿដោយហេតុថាខ្លួនគាត់ផ្ទាល់ គឺមានសេចក្តីកំសោយដែរ" [៣៤] ការរំលឹកនឹកចាំពីអំពើបាបរបស់យើងផ្ទាល់គឺជាឱសថដ៏ពូកែដែលអាចជួយកែយើងពីជំងឺនៃការមានអំនួត។ លោកសាវកប៉ូលមានប្រសាសន៍ដូចគ្នានេះដែរ នៅពេលដែលគាត់រំលឹកដល់ លោកទីតុសដែលថា "នៅពេលមួយយើងក៏ល្ងីល្ងើមិនស្តាប់បង្គាប់បោកបញ្ឆោត និងជាប់ជាបាវបំរើដល់តណ្ហាគ្រប់យ៉ាង និងការភ្លើតភ្លើនគ្រប់ជំពូកដូចគេដែរ ។ យើងរស់ក្នុងជីវិតដែលច្រណែនឈ្នានីស និង ចងអាឃាត ព្យាបាត សំអប់ និង ស្អប់គ្នាទៅវិញទៅមក " [៣៥] ។ ភាពកំសោយនៅពេលបច្ចុប្បន្ន និង ភាពល្ងង់ល្ងើពីអតីតកាលបណ្តាលឲ្យយើងចេះបន្ទាបខ្លួន និង ចេះប្រព្រឹត្តដោយសុភាពចំពោះអស់អ្នកដែលកំពុងវង្វេងបែកចេញពីសេចក្តីពិត ។

*អ្នកដទៃប្រហែលជាអាចនិយាយត្រូវ* ។ គ្រីស្ទបរិស័ទខ្លះជឿថា មានតែគេទេដែលមានសេចក្តីពិត និង ជាសេចក្តីពិតតែមួយប៉ុណ្ណោះចំណែកឯអ្វីៗគ្រប់យ៉ាងដែលអ្នកដទៃទៀតជឿគឺសុទ្ធតែខុសឆ្គងទាំងអស់។ គឺមិនពិតតែទាំងពីរ ។

អ័ប្រាហាំជាមនុស្សដែលមានកិត្តិយសជាងគេបំផុតនៅក្នុងព្រះគម្ពីរសញ្ញាចាស់តាមដែលយើងបានអានមក ។ គាត់ជាស្ថាបនិកនៃជនជាតិ

---

[៣៤] *ហេព្រើរ ៥: ២*

[៣៥] *ទីតុស ៣:៣*

យូដា និងជា"បិតានៃជំនឿរបស់មនុស្សទាំងអស់ "[៣៦]។ ជំនឿរបស់គាត់បានលើកស្ទួយគាត់ទៅជាមិត្តសម្លាញ់ជិតស្និទ្ធជាមួយព្រះជាម្ចាស់[៣៧]។ តែទោះជាយ៉ាងនោះក៏ដោយគាត់ក៏មិនមែនត្រូវរហូតនោះដែរ ។

មានពេលម្តងនោះ អ័ប្រាហាំ បានទៅតាំងទីលំនៅត្រង់កេរ៉ា ។ នៅទីនោះហើយដែលគាត់បានកុហកថា សារ៉ាជាប្អូនរបស់គាត់ និងសារ៉ា ធ្លាក់ខ្លួនទៅរស់នៅក្នុងកន្លែងសរិតសំរាំងស្ត្រីសំរាប់ទុកឲ្យស្តេចអ័ប៊ីម៉ាឡិចទៅវិញ ។ ដើម្បីកែខៃបញ្ហានេះឡើងវិញ ព្រះជាម្ចាស់មិនបានមាន បន្ទូលមកអ័ប្រាហាំទេ ដែលមនុស្សទាំងគិតថាព្រះជាម្ចាស់គួរតែមានបន្ទូលមកអ័ប្រាហាំ តែព្រះអង្គបែរជាមានបន្ទូលទៅកាន់ស្តេចសាសន៍ ភីលីស្ទីនទៅវិញ ![៣៨] ។ ដោយសារតែការខ្វះជំនឿ និងការទុកចិត្តលើគ្រោងការណ៍ដែលមិនត្រឹមត្រូវរបស់គាត់នោះ អ័ប្រាហាំបានធ្វើឲ្យខ្លួនគាត់បាត់ឱកាសនៃការឮព្រះសូរសៀងរបស់ព្រះជាម្ចាស់ដើម្បីដោះស្រាយបញ្ហាចំពោះមុខ ។ ព្រះជាម្ចាស់មានបន្ទូលទៅព្រមានដល់ស្តេច អ័ប៊ីម៉ាឡិច ដែលអាចស្តារស្ថានការណ៍ដល់នាងសារ៉ាបាន និង នៅពេលជាមួយគ្នានោះដែរ ព្រះជាម្ចាស់បានប្រើឲ្យស្តេចបន្ទោសដល់អ័ប្រាហាំដែរ ។ អ័ប្រាហាំជាអ្នកជឿ អ្នកចុះសន្ធិសញ្ញាជាមួយព្រះជាមិត្តសម្លាញ់របស់ព្រះជាម្ចាស់ និង ជាបិតានៃជំនឿរបស់មនុស្សដែលបានជឿព្រះទាំងអស់បានស្តាប់ឮព្រះសូរសៀងរបស់ព្រះជាម្ចាស់នៅពេលនេះចេញពីមាត់នៃសាសន៍ដទៃ គឺជាស្តេចនៃសាសន៍ភីលីស្ទីនទៅវិញ ។ គាត់បានកុហកដោយគាត់បានគិតស្មានថានៅកន្លែងនោះប្រហែលជាគ្មាន " ការកោតខ្លាច

---

[៣៦] *រ៉ូម ៤:១១- ១២; ១៦-១៧*

[៣៧] *យ៉ាកុប ២:២៣*

[៣៨] *លោកុប្បត្តិ ២០:១; ២១:២២; ៣៤* . Cp. Isaac's experience with another Abimelech in Gen 26:1.

ព្រះទេមើលទៅ"[៣៩] ដូចដែលគ្រីស្ទបរិស័ទខ្លះសម័យសព្វថ្ងៃបានគិតដូច្នោះដែរ ព្រោះគាត់គិតថាអ្នកដែលគាត់កំពុងរស់នៅជាមួយនោះសុទ្ធតែអ្នកមិនជឿ ។

ការណ៍បែបនេះមិនមែនគ្រាន់តែមានម្តងនៅក្នុងព្រះគម្ពីរប៉ុណ្ណោះទេ ។ យ៉ូសៀសជាស្តេចដែលកោតខ្លាចព្រះសោយរាជ្យនៅក្នុងអាណាចក្រយូដា ដែល"បានប្រព្រឹត្តត្រឹមត្រូវនៅព្រះនេត្រព្រះយេហូវ៉ាព្រមទាំងដើរតាមអស់ទាំងផ្លូវរបស់ដាវីឌជាព្ធយុកោទ្រង់ផងឥតងាកបែរទៅខាងស្តាំឬឆ្វេងឡើយ"[៤០]។ ព្រះគម្ពីរបានចែងថា "គ្មានស្តេចណានៅខាងមុខ និង នៅខាងក្រោយស្តេចយ៉ូសៀសមានចិត្តដូចជាស្តេចអង្គនេះដែលបានបែរមករកព្រះយេហូវ៉ាឲ្យអស់ពីចិត្តអស់ពីព្រលឹង ហើយអស់ពីកម្លាំងតាមគ្រប់ទាំងក្រឹត្យវិន័យរបស់លោកម៉ូសេឡើយ "[៤១] ។

តែផ្ទុយទៅវិញ ស្តេចផារ៉ោននៃប្រទេសអេហ្ស៊ីប ជាទូទៅមិនបានបង្ហាញថា បាននៅកៀកកិតជាមួយព្រះជាម្ចាស់ឡើយ ។ តែនៅពេលដែលស្តេចអេហ្ស៊ីបព្រះនាមនេកោបានលើកទ័ពទៅច្បាំងជាមួយពួកបាប៊ីឡូនទ្រង់បានព្រមានដល់ស្តេចយូសៀសមិនឲ្យប្រឆាំងនឹងទ្រង់ដោយបន្ទូលថា៖" ព្រះក៏បានបង្គាប់ឲ្យយើងប្រញាប់នឹងធ្វើដែរ ដូច្នោះកុំឲ្យឃាត់ឃាំងព្រះដែលគង់ជាមួយនឹងយើងឡើយ ក្រែងព្រះបំផ្លាញទ្រង់ទៅ " គួរឲ្យសោកស្តាយព្រះគម្ពីរបានចែងថាស្តេចយ៉ូសៀសមិនព្រមថយបែរចេញពីនេកោទេឥតស្តាប់តាមពាក្យរបស់នេកោដែលមកពីព្រះឱស្ឋនៃព្រះឡើយ ។ ហើយយាងទៅច្បាំងនៅត្រង់ច្រកភ្នំ មេគីដោ ពួកពលធ្នូក៏បាញ់ត្រូវស្តេច យ៉ូសៀស ហើយទ្រង់ក៏

---

*[៣៩] លោកុប្បត្តិ ២០:២១*

*[៤០] របាក្សត្រ ៣៤:១*

*[៤១] ២ ពង្សាវតារក្សត្រ ២៣:២៥*

សុគតទៅ [៩២]។ ស្តេចដែលកោតខ្លាចព្រះបែរជាមិនព្រមស្តាប់តាមព្រះសូរសៀង របស់ព្រះជាម្ចាស់ដែលកើតចេញពីប្រភពមួយដែលរកនឹកស្មានមិនដល់ ។

ព្រះយេស៊ូបានសង្កេតឃើញថា"មនុស្សនៃលោកិយនេះមាន ប្រាជ្ញា ក្នុងការដោះស្រាយបញ្ហាជាមួយមនុស្សជំនាន់នេះ ជាងមនុស្សខាងពន្លឺ"[៩៣]។ សុភាសិតបានចែងថា យើងគួររៀនយកគំរូតាមសត្វស្រមោច[៩៤] ។ សូម្បីតែ សត្វលា និង ដុំថ្មពេលខ្លះក៏មានរឿងត្រូវនិយាយដែរ [៩៥] ។ មិនថាឡើយយើង មានជំនឿ និង បានដើរកៀកកិតនឹងព្រះអង្គជិតជាងអ័ប្រាហាំ និងមានចិត្ត ឆេះឆួល ស្វែងរកព្រះយេហូវ៉ាច្រើនជាងស្តេច យ៉ូសៀស ប៉ុណ្ណោះទេ យើងក៏ អាចធ្វើមិនអើពើចំពោះអ្នកដែលមិនមែនជាអ្នកជឿដូចយើងដូច្នេះដែរ ។

*ការប្រើសំដីគ្រោតគ្រោះបោះបោកនោះគឺជាឧបករណ៍ដែលពួកខុសឆ្គងគេ ប្រើ ។* ថ្វីដ្បិតតែមនុស្សមួយចំនួនគិតថា ការនិយាយព្រួៗ និង និយាយបង្រ្កប គេនោះ គឺប្រាកដជាគាត់មានសេចក្តីពិតមកចែកចាយច្បាស់ជាង តាមពិត ទៅការនិយាយព្រួៗ និង សេចក្តីពិតនោះវាមិនទាក់ទងគ្នាឡើយ ។ ការនិយាយ មួលបង្កាច់ និង ប្រើសំដីបង្រ្កបនោះគឺជាឧបករណ៍ដែលពួកគ្រូ ក្លែងក្លាយគេប្រើ គឺគេប្រើដើម្បីគ្របបាំងនូវចំណុចខ្សោយរបស់គេ និង ដើម្បីទាក់ទាញមនុស្ស ស៊ើកៗឲ្យទៅតាមគេទៅវិញទេ ។ មានតែ" មនុស្សគ្មានព្រះ និង"អ្នកដែល ស្រមើលស្រមៃ " ដែលប្រើពាក្យ "មួលបង្កាច់ "សូម្បីតែពួកទេវតាក៏មិន លើកលែង ផងនិង " និយាយបង្រ្កបប្រឆាំងនូវអ្វីដែលគេមិនយល់ " ។ គេខ្លាំងជាងមហាទេវតាមីកែលទៅទៀតដែលមិនហ៊ាននិយាយទាស់ប្រឆាំង សូម្បីតែដឹងច្បាស់ថា សាតាំងជាខ្មាំងសត្រូវក៏ដោយ[៩៦] ។

---

[៩២] *២របាក្សត្រ ៣៥:២០-២៤*

[៩៣] *លូកា ១៦:៨*

[៩៤] *សុភាសិត ៦:៦ -១១*

[៩៥] *ជនគណនា ២២:២៨-៣១; លូកា ១៩:៤០*

[៩៦] *យូដាស ៨:១០ ជិតតែស៊ីគ្នាទីដ៍ ២ ពេត្រុស ២:១០-១២*

*ការប្រើពាក្យសុភាពគឺចេញពីមនុស្សដែលគោរពខ្លាចព្រះគឺជាគំរូដ៏ឆ្លាតវៃ ។* ផ្ទុយទៅវិញគ្រូដែលមានប្រាជ្ញាចេះទប់អណ្ដាតរបស់ខ្លួនគឺមិនប្រើដើម្បីដាក់ " បណ្ដាសាដល់មនុស្សដែលជាស្នាព្រះហស្តរបស់ព្រះឡើយ"។ គាត់បានបង្ហាញពីភាពវៃឆ្លាតរបស់គាត់ " ដោយការរស់នៅក្នុងជីវិតល្អប្រពៃដោយការប្រព្រឹត្តិដែលបន្ទាបខ្លួនគឺផុសចេញពីគតិបណ្ឌិត"។ ប្រាជ្ញាមកពីស្ថានលើគឺមិនច្រណែន ឬ មិនលោភលន់តែបរិសុទ្ធមានមេត្រីភាព និងចេះយោគយល់ [៨៧] ។

*ព្រះយេស៊ូវដោះស្រាយបញ្ហាដោយសុភាព ។* នេះជារបៀបមួយព្រះយេស៊ូបានបំរើការងារព័ន្ធកិច្ច ។ នៅក្នុងការស្វែងរកពីរបៀបបង្ហាញប្រាប់ពីរូបភាពនៃព័ន្ធកិច្ចរបស់ព្រះយេស៊ូលោកម៉ាថាយបានដកស្រង់សំដីរបស់ហោរាអេសាយ ៖

" មើលអ្នកបំរើដែលអញបានរើសតាំង ជាអ្នកស្ងួនភ្ងាដែលជាទីពេញចិត្តអញ អញនឹងដាក់វិញ្ញាណអញឲ្យសណ្ឋិតនៅលើទ្រង់ហើយ ទ្រង់នឹងថ្លែងប្រាប់ពីសេចក្ដីយុត្តិធម៌ដល់សាសន៍ដទៃទ្រង់នឹងមិនតតាំងនឹងគេ ឬ ស្រែកសំរែកឡើយ នឹងគ្មានអ្នកណាឮសម្លេងទ្រង់នៅក្នុងផ្លូវទេទ្រង់នឹងមិនផ្ដាច់ដើមត្រែងដែលបាក់ក៏មិនលត់ប្រឆេះដែលនៅហុយឡើយ ទាល់តែបាននាំសេចក្ដីយុត្តិធម៌ឲ្យមានជ័យជំនះ ហើយអស់ទាំងសាសន៍ដទៃនឹងមានសេចក្ដីសង្ឃឹមដោយនូវឈ្មោះទ្រង់ "[៨៨] ។

នៅក្នុងខ ១៩ មិនមានន័យថាព្រះយេស៊ូបានមានបន្ទូលសោះឡើយនោះទេ ដ្បិតនៅ ខ ខាងដើមបានចែងពីព្រះអង្គមានបន្ទូលប្រកាសពីសេចក្ដី

---

[៨៧] *យ៉ាកុប ៣:៩-១៨*

[៨៨] *ម៉ាថាយ ១២:១៨-២១; អេសាយ ៤២:១-៤*

យុត្តិធម៌ ។ តែផ្ទុយទៅវិញត្រង់នេះចង់បញ្ជាក់ពី " ភាពសុភាពទន់ភ្លន់ និង ការបន្ទាបខ្លួន ( ១១:២៩ ) ភាពស្ងប់ស្ងាត់នៃការដកថយចេញទៅ ... និងការ បង្ហាញពីភាពជាព្រះមេស្ស៊ីរបស់ព្រះអង្គដែលមិនក្រអឺតក្រទម ឬ អួតអាង នោះឡើយ"[៤៩] ។ នៅពេលដែលពេត្រុសចង់សង្ខេបពីព័ន្ធកិច្ចរបស់ព្រះយេស៊ូ គាត់បាននិយាយពី " របៀបដែលព្រះជាម្ចាស់បានចាក់ ប្រេងតាំងព្រះយេស៊ូ ជាអ្នកស្រុកណាសារ៉ែតដោយព្រះវិញ្ញាណបរិសុទ្ធនិងអំណាចចេស្តា និង របៀប ដែលព្រះអង្គចេញទៅគ្រប់ទិសទីដើម្បីធ្វើការល្អ និង ការប្រោសជម្ងឺ..."[៥០]។ គំរូដែលជាធម្មតាដែលព្រះយេស៊ូបានធ្វើដែលយើងគួរយកតម្រាប់តាមនោះ គឺព្រះអង្គមិនប្រឈមមុខដោយនិយាយសង្គ្រប់ឡើយ ។

### នៅពេលដែលត្រូវបំបែកគំរូដ៏សុភាពនោះហើយ

ទោះបីជាយ៉ាងណាក៏ដោយមានពេលខ្លះនោះព្រះយេស៊ូបានមាន បន្ទូលខ្លាំងមែនទែន ។ នៅគម្ពីរម៉ាថាយ ២៣ ព្រះអង្គបានមានបន្ទូលទាស់ទទឹង នឹង ពួកបណ្ឌិតក្រឹត្យវិន័យ និង ពួកផារាស៊ីដោយប្រើពាក្យវរហើយប្រាំពីរដង ព្រោះពួកនោះព្រះអង្គបានចាត់ទុកជាមនុស្សមានពុត កូនប្រុសនៃស្ថាននរក អ្នកខ្វាក់ដឹកដៃអ្នកភ្លើ ផ្នូរខ្មោចដែលលាបពណ៌សពីខាងក្រៅ ពួកពស់ និង ពួកហ្វូង ពស់វែក ។ ការណ៍នេះប្រាកដជាមិនមែនជាពាក្យទន់ភ្លន់ឡើយ ។ ក្រៅពីព្រះយេស៊ូ គេអាចនឹកគិតដល់លោកអេលីយ៉ា ពេលដែលគាត់ប្រឈម មុខជាមួយពួកហោរានៃព្រះបាល[៥១] លោកប៉ូល ជាមួយនឹងអេលីម៉ាស[៥២] និង

[៤៩] D. A. Carson, "Matthew," in *The Expositor's Bible Commentary*, gen. ed. Frank E. Gæbelein, CD ROM ed. (Grand Rapids: Zondervan, n.d.), on Matt 12:15–21.

[៥០] *កិច្ចការ ១០:៣៨*

[៥១] *១ ពង្សាវតាក្សត្រ ១៨:២៧*

[៥២] *កិច្ចការ ១៣:៩-១១*

លោកអេសាយ ជាមួយនិងពួកថ្វាយបង្គំព្រះ [៥៣] ។ ហេតុអ្វីបានជានៅក្នុងឱកាសនេះ អ្នកបំរើការងារព្រះជាម្ចាស់បែរចេញពីគំរូនៃការសុភាពទន់ភ្លន់ជាធម្មតាទៅវិញ ?

គន្លឹះសំខាន់ទីមួយគឺដោយសារតែពួកមនុស្សទទួលរងនូវការស្តីបន្ទោសខ្លាំងៗបែបនេះ គឺពួកគេជាមនុស្សដែលគួរយល់ដឹងពីសេចក្តីពិតប្រសើរជាងគេ ។ ពួកបណ្ឌិតខាងក្រឹត្យវិន័យ និងពួកផារាស៊ីបានសិក្សាពីក្រឹត្យវិន័យរបស់ព្រះជាម្ចាស់យូរយារណាស់មកហើយ សេចក្តីកោតខ្លាចព្រះនោះគេមានពេលល្មមគ្រប់គ្រាន់ហើយ តែគេមានបំណងមើលរំលងពីក្រឹត្យវិន័យទាំងនោះទៅវិញ ។ អេលីម៉ាសជាសាសន៍យូដាដែលជាអ្នកមានឱកាសស្គាល់សេចក្តីពិតច្បាស់ តែបែរជាទៅថ្លែងទំនាយក្លែងក្លាយ និង រកស៊ីជាគ្រូទាយទៅវិញ ។ ការប្រព្រឹត្តិរបស់លោកប៉ូលចំពោះគាត់គឺខុសប្លែកស្រឡះពីការដែល លោកប៉ូលបានធ្វើនៅក្នុងកិច្ចការ ១៤:១១-១៨ គឺគាត់បាននិយាយទទូចអង្វរជាមួយសាសន៍ដទៃ ដោយគ្មានប្រើពាក្យស្តីបន្ទោសឡើយ ។ ពួកអ៊ីស្រាអែលដែលលោកអីលីយ៉ាបានប្រឈមមុខតទល់ជាមួយនោះគឺ ពួកគេគួរតែយល់ដឹងពីព្រះយេហូវ៉ា បានច្បាស់រួចហើយ ។ ពួកអ្នកថ្វាយបង្គំរូបព្រះដែលលោកអេសាយ និយាយចំអកឲ្យនោះគឺជាពួកអ្នកមិនយល់ពីរឿងរ៉ាវដ៏សាមញ្ញបំផុតនោះឯង [៥៤] ។ កំហុសរបស់គេសមតែនឹងស្តីបន្ទោសឲ្យយ៉ាងខ្លាំង គឺមិនសមប្រើពាក្យស្លូតបូតឡើយ ។

ទីពីរចំពោះអ្នកទាំងនោះដែលត្រូវបានលោកអេសាយបន្ទោសនោះមិនគ្រាន់តែល្ងីល្ងើតែខ្លួនឯងនោះឡើយ ថែមទាំងនាំអ្នកដទៃឲ្យវង្វេងទៅតាមខ្លួនទៀតផង ។ ពួកបណ្ឌិតខាងក្រឹត្យវិន័យ និង ពួកផារាស៊ីមិនគ្រាន់តែជាមនុស្សខ្វាក់វង្វេងប៉ុណ្ណោះទេ តែជាអ្នកដឹកនាំដែលខ្វាក់វង្វេងទៀតផង ។

---

[៥៣] *អេសាយ ៤៤:៩-២០*

[៥៤] *អេសាយ ៤៤:១៩ -២០*

អេលីម៉ាសបានបង្វែរលោក សើរកាល- ប៉ូឡូស មិនជឿសេចក្តីពិត។ លោកប៉ូល បានប្រឆាំងជាមួយ ពេត្រុសដោយផ្ទាល់នៅ ចំពោះមុខមនុស្សដទៃ (ដោយមិនក្រែងចិត្តថា ពេត្រុសបាក់មុខឡើយ) ពីព្រោះ"សាសន៍យូដាដទៃទៀតបានចូលរួមក្នុងពិធីកំពុតរបស់គាត់"និង"សូម្បីតែបាណាបាសក៏ត្រូវគេនាំឲ្យគាត់វង្វេងដែរ"[៥៥]។ ក្រោយមកគាត់បានឲ្យទីតុសស្តីបន្ទោសយ៉ាងខ្លាំងទាស់នឹងពួកបណ្ឌិតផ្នែកច្បាប់" ពីព្រោះពួកគេបានផ្តួលពួកអ្នកផ្ទះទាំងមូល[៥៦]។

យើងអាចសរុបសេចក្តីបានចំពោះគំរូជាទូទៅនៃការបំពីរព័ន្ធកិច្ចគឺតាមពិតទៅការចាប់ផ្តើមដំបូងនោះ គឺយើងត្រូវប្រើរបៀបទន់ភ្លន់ ។ នេះគឺជាអ្វីដែលអត្ថបទគម្ពីរត្រង់នេះបានបង្រៀនយើង និងជាគំរូជាច្រើន ហើយនិងសាច់រឿងដែលបានគូសបញ្ជាក់បង្ហាញមកនោះ ។ ទោះជាយ៉ាងណាក៏ដោយមានឱកាសជាច្រើន នៅពេលដែលមនុស្សយើងខ្វះការទទួលខុសត្រូវ និងបែរទៅទទួលយកនូវការខុសឆ្គងយ៉ាងសកម្មនោះ គឺគេត្រូវតែទទួលរងការប្រឆាំងតទល់យ៉ាងខ្លាំង ព្រោះតែគេបានទទួលនូវគោលលិទ្ធិដែលខុសឆ្គងមកនាំអ្នកដទៃឲ្យវង្វេង ។

## មានយន្តការបីយ៉ាងនៃការស្តារពលន់ភ្លន់ ញែកបុគ្គលនោះឲ្យដាច់ចេញបញ្ហា

ទោះបីជាយ៉ាងណាក៏ដោយ ដំណើរការដែលគួរឲ្យយើងយកមកប្រើ និង ដំណើរការមួយដែលយើងគួរយកមកធ្វើតាមមុនគេនោះ គឺ គូសបន្ទាត់ឲ្យដាច់ពីការបង្រៀនក្លែងក្លាយ និងមនុស្សដែលបានកាន់តាមសេចក្តីបង្រៀននោះ ។ សេចក្តីបង្រៀនក្លែងក្លាយនោះ គឺជាបញ្ហាមិនមែនជាមនុស្សទេ ដែលជាបញ្ហាយើងត្រូវដោះស្រាយ ។

---

*[៥៥] កាឡាទី ២:១១-១៣ អត្ថបទនេះមិនរាប់បញ្ចូលពាក្យស្តីបន្ទោសនៅក្នុងគំរូលើកមុនៗផង តែគឺជាការណែនាំមួយបែបដែលធ្ងន់ធ្ងរតទល់នឹងមហាសាវ័ក ។*

*[៥៦] ទីតុស ១:១០-១៣*

នៅក្នុងសៀវភៅរបស់ពួកលោក ហ្វីសស៊ើ យ៉ូរី និង ផាតថិន ស្តីពីការចរចារបានលើកឡើងមកនិយាយនៅក្នុងជំពូកមួយ យ៉ាងច្បាស់ចំពោះការញែកមនុស្សចេញពីបញ្ហា [៥៧] ។ គេបាននាំលើកយើងយ៉ាងច្បាស់ថា ដំបូងពួកអ្នកចរចារគឺជាមនុស្ស ហើយនិងអ្នកចរចារគ្រប់រូបមានចំណាប់អារម្មណ៍ពីរបែប គឺទាក់ទងជាមួយសារធាតុនៃការចរចារ និងមួយទៀតទាក់ទងទំនាក់ទំនងនៃអ្នកចរចារ ។ នៅក្នុងជំពូកនៃសៀវភៅនោះបានបញ្ចប់សេចក្តីដោយការសកបញ្ចូលពាក្យថា " ការញែកមនុស្សចេញពីបញ្ហាគឺមិនមែនជាការងារមួយលោកអ្នកអាចធ្វើតែម្តងរួចហើយ បំភ្លេចចោលនោះឡើយ លោកអ្នកត្រូវកំណត់ក្នុងចិត្តជានិច្ចធ្វើការនោះរហូត ។ គោលការណ៍សំខាន់ជាមូលដ្ឋាន គឺត្រូវដោះស្រាយបញ្ហាជាមួយមនុស្សដោយយល់ពីតម្លៃគេជាមនុស្ស និង ដោះស្រាយជាមួយបញ្ហាគឺចាត់ទុកថាវាគ្រាន់តែជាបញ្ហាទុកឲ្យបញ្ហានោះវាស្តែងចេញពីលទ្ធផលរបស់វាផ្ទាល់មក " [៥៨] ។

ម៉ាកហ្គ្រាត បានលើកយកឥរិយាបទនេះផ្តោតសំខាន់លើការងារចរចារដែលមានលក្ខណៈខុសប្លែកគ្នា និងស្រង់យកគោលការណ៍នេះមកប្រើក្នុងការដោះស្រាយក្នុងកិច្ចការពារជំនឿរបស់គ្រីស្តបរិស័ទ [៥៩]។ គាត់បានផ្តល់នូវការណែនាំដូចខាងក្រោមនេះគឺ៖

> ឧបមាថាលោកអ្នកកំពុងនិយាយជាមួយអ្នកដែលមួយជីវិតគាត់មិនជឿថាមានព្រះទេ គឺយើងនិយាយអំពីគំនិតរបស់គាត់ ។ ចំណុចស៊ើ

---

[៥៧] Roger Fisher, William Ury, and Bruce Patton, *Getting to Yes: Negotiating Agreement Without Giving In*, 2nd ed., (Boston: Houghton Mifflin, 1991). Chapter two, "Separate the People from the Problem," occupies pages 17–39, and is the leading chapter in Part II, "The Method."

[៥៨] *ដូចលេខយោងទី ៥៧ ដែរ តែនៅទំព័រទី៣៩*

[៥៩] Alister E. McGrath, *Intellectuals Don't Need God & Other Modern Myths: Building Bridges to Faith through Apologetics* (Grand Rapids: Zondervan, 1993), 88–92.

ដែលយើងបានលើកមកនិយាយគឺថា តើព្រះមានមែន ឬ អត់ ។ ប៉ុន្តែបញ្ហាដែលស៊ីជម្រៅនោះ ប្រហែលជាអាចមានបញ្ហាជាច្រើនទៀតមាននៅក្នុងបុគ្គលនោះដែលយើងមិនបានដឹងច្បាស់ ។ គំនិតទាំងអស់អាចផុសឡើងនៅក្នុងគំនិតរបស់គាត់គឺថា ៖" ខ្ញុំជាមនុស្សដែលមិនថាមានព្រះអស់រយៈពេល ២៥ ឆ្នាំ ហើយគិតមកទល់ឥឡូវនេះ ។ នោះគឺជារយៈពេលយូរ ។ ម្យ៉ាងទៀតនោះអ្នកណាក៏គេដឹងថា ខ្ញុំជាមនុស្សដែលមិនជឿថាមានព្រះ ។ បើសិនជាខ្ញុំប្តូរគំនិតឥឡូវនេះ គេនឹងសើចចំអកឲ្យខ្ញុំជាមិនខាន ។ ខ្ញុំប្រាកដជាបាក់មុខ ។ កេរ្តិ៍ឈ្មោះរបស់ខ្ញុំផ្ទាល់គឺវាទាក់ទងផ្ទាល់នឹងគំនិតយល់ឃើញរបស់ខ្ញុំដែលមិនជឿថាមានព្រះនោះ ។ ខ្ញុំភ្ជាប់វាទៅនឹងស្ថានការណ៍នេះ ។ ជំនឿរបស់ខ្ញុំ និង អត្តសញ្ញាណរបស់ខ្ញុំអាច នឹង ច្របូកច្របល់គ្នាបន្តិច ។ បើសិនខ្ញុំប្តូរគំនិតរបស់ខ្ញុំចំពោះបញ្ហានេះខ្ញុំ ប្រហែលជាប់ក្នុងអារម្មណ៍ចោទប្រកាន់ពីស្ថានភាពអតីតកាលរបស់ខ្ញុំទាំងស្រុង" ។ អ្នកបញ្ចេញមតិការពារជំនឿរបស់ខ្លួនអាចងាយចាប់យកការប្រកាន់បែបនោះ តាមរបៀបដោះស្រាយបញ្ហាដែលខ្វះការប្រុងប្រយ័ត្ន និង ការប៉ិនប្រសព្វទៅនឹងរឿងដែលងាយប៉ះពាល់អារម្មណ៍របស់មនុស្ស[៦០]។

ដើម្បីកាត់បន្ថយនូវការសាងបញ្ហា កុំឲ្យធ្ងន់ធ្ងរឡើងនោះ ម៉ាកប្រ្គាត បានណែនាំថា ដំបូងត្រូវញែកមនុស្សចេញឲ្យដាច់ពីបញ្ហា និង បន្ទាប់មកគឺធ្វើឲ្យងាយស្រួលមនុស្សទាំងនោះប្តូរគំនិតរបស់គេ ។

បទគម្ពីរទំនងដូចជាគាំទ្រនូវគោលការណ៍បែបនោះ ។ សូមមើលត្រឡប់ទៅធីម៉ូថេ ២:២៤-២៦ យើងឃើញថាលោកប៉ូលបានលើកទឹកចិត្ត

---

៦០ ដូចលេខយោងទី ៥៩ ដែរ តែទៅទំព័រទី ៨៨

ឲ្យប្រព្រឹត្តសុភាពដល់មនុស្សដែលជាប់នឹងសេចក្តីបង្រៀនខុសឆ្គងដោយសង្ឃឹមថា បុគ្គលនោះនឹងលះបង់ចោលគំនិតខុសឆ្គងរបស់ខ្លួន ។ ខ្មាំងសត្រូវនៅក្នុងករណីនេះគឺអារក្សដែលវាប្រើល្បិចចាំចាប់អ្នកដែលប្រឆាំងនឹងគោលលិទ្ធិពិត ។ ការបង្រៀនដោយសុភាព និង ជំនួយអន្តរាគមន៍មកពីព្រះជាម្ចាស់ផងនោះ អាចនឹងជួយបើកភ្នែកខ្វាក់ឲ្យគេបានឃើញ និង ព្រមទទួលសេចក្តីពិត ។ ២ កូរិនថូស ៤:១-៦បានចែងភាគច្រើនដូចគ្នានេះដែរ [៦១] ។

ការសុភាពទន់ភ្លន់នោះអាចទំនងជាឥរិយាបទល្អតែមួយគត់ គឺជាឥរិយាបទដែលពិបាកពណ៌នាក្នុងពាក្យណាមួយដែលចំត្រូវពិតប្រាកដ ។ ប៉ុន្តែមានដំណើរការដែលអាចប្រើដើម្បីធានាចំពោះគោលការណ៍សុភាពនោះថាល្អត្រឹមត្រូវ ។ ការញែកមនុស្សចេញពីបញ្ហានោះគឺជា ដំណើរការទីមួយ ។ ការស្តាប់មុនពេលនិយាយនោះ និងការប្រើពាក្យស្រដៀងគ្នានោះ គឺជាដំណើរការពីរថែមទៀត ។ ការយកទាំងអស់នោះជាមួយគ្នាគឺគេបានលើកកំពស់ស្មារតីដែលអ្នកនិយាយមិនសូវស្កប់ចិត្តនូវអ្វីដែល គាត់ចង់និយាយប៉ុន្មាន គឺនិយាយឲ្យតែរួចៗទៅ គឺមានឥរិយាបទដែល"ទទួលយកគំនិតនោះ ឬ ទុកគំនិតនោះចោល"។

*[៦១] នៅក្នុង ២ កូរិនថូស ៤ ប៉ុលបាននិយាយអំពីរបៀបដែលព្រះនៃសម័យនេះបានបិទភ្នែកនិងគំនិតនៃអ្នកមិនជឿ ។ ហេតុដូច្នេះហើយគាត់ជាបញ្ហាដូចគ្នានឹងគោលលិទ្ធិដែលគាត់បង្រៀន ។ ការឆ្លើយតបចំពោះបញ្ហានេះដែលត្រឹមត្រូវនោះ គឺត្រូវលើកយកសេចក្តីពិតឲ្យឃើញច្បាស់ហើយនិងត្រូវចាប់ផ្តើមយល់ពីមនសិការរបស់មនុស្ស ដោយការអធិប្បាយផ្សាយពីព្រះយេស៊ូជាព្រះអម្ចាស់និងទុកខ្លួនឯងជាអ្នកបំរើវិញ ។ ឃ្លាខាងលើទាំងពីរគឺស៊ី គ្មានិងគំរូនៃការរឹងប៉ឹងចំពោះសេចក្តីពិតតែសុភាពទន់ភ្លន់ជាមួយមនុស្ស ។*

## ស្តាប់មុននឹងនិយាយ

"អ្នកណាដែលឆ្លើយមុនដែលបានស្តាប់រឿងនោះរាប់ជាការចំកួត ហើយក៏ជាសេចក្តីខ្មាសដល់ខ្លួនផង" [៦២] មានគតិបណ្ឌិតក្នុងការស្តាប់ និង យល់ដឹងពីគ្នាមុននឹងមានបំណងនិយាយពីគតិលោក ឬ និយាយពីសាសនា ។ លោកប៉ូលបានហាត់ប្រើគោលការណ៍នេះ ដោយមិនគ្រាន់តែមើលសើៗនោះឡើយ តែគាត់ពិនិត្យមើលដោយយកចិត្តទុកដាក់លើកន្លែងថ្វាយបង្គំនៃអាសនារបស់ពួកអ្នកក្រុងអាថែន មុនគាត់លើកពីព្រះដែលគេពុំស្គាល់ [៦៣] ។ ឱកាសនេះឆ្លុះបញ្ចាំងពីយុទ្ធសាស្ត្ររបស់គាត់នៃការយល់ដឹងនៃរឿងរ៉ាវទាំងអស់មនុស្សទាំងអស់ដើម្បីឲ្យអាចផ្សាយដំណឹងល្អដល់គេឲ្យបានច្រើនតាមដែលអាចធ្វើបាន ។ គោលបំណងរបស់គាត់មិនគ្រាន់តែនិយាយឲ្យតែបានច្រើន ហើយមិនខ្វល់ថាគេយល់ ឬ មិនយល់នោះទេ តែក្នុងគោលបំណងឲ្យគេបានជឿឲ្យបានច្រើនតាមដែលអាចធ្វើបាន [៦៤] ។

មានអ្វីដែលគេអាចហៅថា"បច្ចេកទេសនៃការស្តាប់ជាគំរូមាត្រដ្ឋាន"។ ទាំងនេះគឺ៖

យកចិត្តទុកដាក់យ៉ាងជិតដល់នូវអ្វីដែលគេបាននិយាយគឺ ត្រូវសុំឲ្យភាគីម្ខាងទៀតនិយាយចេញមកឲ្យបានច្បាស់ពិតប្រាកដនូវអ្វីដែលគេចង់និយាយ ហើយត្រូវសុំឲ្យគេលើកយកគំនិតនោះមកនិយាយម្តងទៀតបើសិននៅមានកន្លែងណាដែលមិនច្បាស់ ឬ នៅស្រពិចស្រពិល ។ ការងាររបស់អ្នកនៅពេលស្តាប់គេនិយាយមិនត្រូវស្តាប់រកឃ្លាណាមួយដែលត្រូវឆ្លើយទៅគេវិញឡើយ តែត្រូវខំស្តាប់ឲ្យយល់នូវអ្វីដែលគេចង់ និយាយឲ្យយើងយល់ដូចគេយល់ដោយខ្លួនគេផ្ទាល់ ។

---

[៦២] *សុភាសិត ១៨:១៣*

[៦៣] *កិច្ចការ ១៧: ២៣*

[៦៤] *១ កូរិនថូស ៩:១៩-២២*

ទទួលយកការយល់ឃើញសេចក្តីត្រូវការរបស់គេ និង កំរិតព្រំដែនរបស់គេ [៦៥] ។

ការងារសកម្មបែបនេះគឺការស្តាប់ដោយយកចិត្តទុកដាក់មិនមែនបានន័យថា យើងយល់ស្របតាមអ្វីដែលបាននិយាយប្រាប់មកយើងនោះឡើយ ។ ការយល់មិនមែនជាការព្រមទទួលស្របតាមនោះឡើយ ។ គេអាចយល់បានយ៉ាងល្អនៅពេលដែលភាគីម្ខាងទៀតបាននិយាយ ។ ប៉ុន្តែដរាបណាលោកអ្នកអាចបង្ហាញឲ្យគេឃើញថា លោកអ្នកបានយល់នូវអ្វីដែលគេយល់នោះ ទើបលោកអ្នកអាចពន្យល់នូវគំនិតយោបល់របស់លោកអ្នកដល់គេបាន ។ នៅពេលលោកអ្នកបានលើកយកពីករណីរបស់គេឲ្យបានយល់ បន្ទាប់មកវិលត្រឡប់វិញដោយលើកយកបញ្ហាទាំងឡាយដែលលោកអ្នករកឃើញនៅក្នុងសំណើរបស់គេ [៦៦] ។

តាមពិតទៅយើងអាចយល់ស្របជាមួយ នរណាម្នាក់បាន និង ទោះបីជាយ៉ាងណាក៏ដោយយើងអាចស្តាប់ និង ស្វែងយល់ពីគេបាន ។ ហេតុផល [ ការចូលទៅក្នុងគតិលោករបស់ម្នាក់ផ្សេងទៀត ] សំខាន់គឺថា យើងចង់បានហេតុការណ៍ពិត ។ អ្វីដែលអ៊ីត្លែរ៍ គិតនិងមានអារម្មណ៍នឹងបានធ្វើនោះ គឺជាហេតុការណ៍ពិត ។ ហេតុការណ៍ខាងពិតក្នុងអំពីអ៊ីត្លែរ៍ ជួយពន្យល់ឲ្យបានយល់ច្រើនពីស្រទាប់ខាងក្រៅនៃបញ្ហា ហើយយើងត្រូវការដឹងហេតុការណ៍ខាងក្នុងរបស់អ៊ីត្លែរ៍ឲ្យបានច្បាស់តាមដែលយើងអាចធ្វើបានបើសិនយើងមានបំណងចង់យល់ពីប្រវត្តិដ៏គួរឲ្យរន្ធត់កាលពីសម័យនោះ ។ ដូចគ្នាដែរបើសិនយើងមាន បំណងចង់រុករកឲ្យយល់ពីលក្ខណៈនិស្ស័យនៃលិទ្ធិព្រះពុទ្ធសាសនា យើង

---

[៦៥] Fisher, Ury, and Patton, *Getting to Yes*, 34.

[៦៦] *ដូចលេខយោងទី ៦៥ ដែរ តែនៅទំព័រទី ៣៥*

ត្រូវតែខំរកឲ្យយល់អត្ថន័យដែលពួកអ្នកកាន់សាសនាព្រះពុទ្ធគេបានកាន់ និង ស្វែងយល់តាមរយៈសៀវភៅសាសនានោះ ។ គំនិតរបស់យើងមិនមែនជាហេតុការណ៍ពួកគេឡើយ ប៉ុន្តែជាហេតុការណ៍ដែលស្ដីពីជំនឿយើងទៅវិញទេ ។ ក្រោយមកពេលដែលយើងបានដឹងនូវអ្វីដែលពួកពុទ្ធសាសនាគេជឿនោះ គឺអាចជួយឲ្យយើង សំលៀងសំរួចជំនឿរបស់យើងផ្ទាល់ [៦៧] ។

## ផ្សាយដំណឹងល្អពីព្រះគ្រីស្ទដោយប្រើពាក្យស្រដៀងគ្នា

ចំពោះអ្នកទាំងឡាយណាដែលបានឲ្យតម្លៃតិចលើអ្នកស្ដាប់របស់ខ្លួននោះ តែងតែផ្សាយសាររបស់ខ្លួននោះ តាមបែបស្រដៀងនឹង អ្វីដែលជារបស់ផងខ្លួនមិនថាពេលណាឡើយឲ្យតែគេចាប់ផ្ដើមធ្វើការប្រាស្រ័យទាក់ទង ។ តើនរណានឹងខ្វល់ទៅនូវអ្វីដែលខ្ញុំនិយាយ ដោយទាក់ទាញចិត្តអាចយល់បាន ឬ ស៊ីនឹងស្ថានការណ៍របស់អ្នកស្ដាប់របស់ខ្ញុំនោះ ? ខ្ញុំបានរៀបចំជាការអធិប្បាយយ៉ាងសំខាន់ ។ អ្វីដែលខ្ញុំនិយាយនោះគឺច្បាស់គ្រប់គ្រាន់សំរាប់ខ្ញុំហើយ ។ បើសិនជាគេចង់យល់គេត្រូវខំប្រឹងយល់ដោយខ្លួនឯងទៅ ។

ប្រហែលការណ៍នេះនិយាយហួសពីករណីនោះ ។ តែអ្នកដែលប្រាស្រ័យមានប្រសិទ្ធិភាពគឺអ្នកប្រាស្រ័យទាក់ទងដែលចេះប្រើពាក្យសុភាព គឺជាអ្នកដែលរៀនស្គាល់ពីអ្នកស្ដាប់របស់ខ្លួន និង ប្រធានបទរបស់ខ្លួនឲ្យបានច្រើន ។ គាត់ជាអ្នកកាត់តម្រឹមឲ្យស៊ីនឹងស្ថានការណ៍ ។ ការសុភាពទន់ភ្លន់ជាមួយមនុស្ស រាប់បញ្ចូលទាំងការយល់ដឹង និង ខំធ្វើឲ្យការស្ដាប់របស់គេបានកាន់តែងាយស្រួលឡើង ។

---

[៦៧] Ninian Smart, *Religion and the Western Mind* (Albany: State University of New York Press, 1987), 4.

នៅពេលថ្មីៗនេះ ខ្ញុំបានចូលរួមក្នុងការប្រជុំរបស់គ្រូគង្វាលនៅតាមជនបទនៃជនជាតិនៅភូមិភាគអាស៊ីដែលភាគច្រើនមិនសូវចេះអក្សរ អ្នកខ្លះមកពីនិន្នាការនយោបាយដ៏តឹងរឹង ។ មានមនុស្សជាច្រើនកំពុងស្រេកឃ្លាននូវការលើកទឹកចិត្ត ចង់បានការថ្វាយបង្គំ និង ចង់បានការបង្រៀននូវគោលជំនឿជាមូលដ្ឋាន ។ សិក្ខាសាលានេះបានរៀបចំឡើងដោយអង្គការផ្សាយដំណឹងល្អ ដែលមានស្នាក់ស្នាក់មកពីបស្ចិមប្រទេសហើយគេបានធ្វើការប្រជុំនៅកណ្តាលទីក្រុង ។ ប្រាកដអត់សង្ស័យថា គោលបំណងរបស់អង្គការនោះ គឺប្រសើរខ្ពង់ខ្ពស់មែនទែន ។ ប៉ុន្តែនៅពេលដែលចាប់ផ្តើមបើកកម្មវិធីគ្រូអធិប្បាយបាននិយាយអំពីសាខា របស់គាត់មាននៅប្រទេសនេះប្រទេសនោះ អស់រយៈពេលយ៉ាងយូរ គឺគាត់បានធ្វើឲ្យអ្នកស្តាប់មិនយល់អ្វីទាំងអស់ និង នៅតែស្រេកឃ្លានដដែល ។ តែផ្ទុយទៅវិញ បន្ទាប់ពីគាត់មានអ្នកប្រកាសដំណឹងម្នាក់ឡើងមកនិយាយប្រហែលបី ឬ បួននាទីថា៖" បងប្អូនអើយអ្នកខ្លះនៅក្នុងចំណោមបងប្អូនចេះប្រើបង្គន់ ហើយអ្នកខ្លះមិនទាន់ចេះប្រើទេ ។ ចំពោះអ្នកដែលចេះ សូមកុំសើចចំអកឲ្យអ្នកដែលមិនចេះតែត្រូវជួយណែនាំគ្នាទៅវិញទៅមក ។ នៅទីនេះគឺនៅក្នុងទីក្រុងមិនមែនជាការគួរសមឡើយក្នុងការស្តោះទឹកមាត់លើជញ្ជាំង ឬ លើឥដ្ឋក្នុងសណ្ឋាគារ ។ ខ្ញុំដឹងថាបងប្អូនខ្លះធ្លាប់ខាកស្តោះនៅឯភូមិស្រុករបស់បងប្អូន តែនៅទីនោះបើយើងខាកស្តោះមិនមែនជាទីបន្ទាល់ល្អឡើយ ។ បើបងប្អូនចង់ ខាកស្តោះ សូមចូលទៅក្នុងបន្ទប់ទឹក ឬចេញក្រៅ តែមិនត្រូវខាកស្តោះដាក់ជញ្ជាំង ឬលើកំរាលសណ្ឋាគារឡើយ ។ អ្នកអធិប្បាយទីពីរនេះ គឺគាត់ស្គាល់មជ្ឈដ្ឋាន អ្នកស្តាប់គាត់ច្បាស់ ។ ពាក្យសំដីរបស់គាត់ ទោះបីជាគាត់មិនបានរៀនជ្រៅជ្រះ និង ប្រើពាក្យល្អពិសេសដូចអ្នកទីមួយក៏ដោយ គឺគាត់បានសម្រេចដល់ទិសដៅគាត់បានច្រើនជាង ។

ព្រះជាម្ចាស់មិនគ្រាន់តែប្រាស្រ័យទាក់ទងដោយយកនិស្ស័យជាមនុស្សទេ តែព្រះអង្គធ្វើឲ្យការប្រាស្រ័យទាក់ទងរបស់ព្រះអង្គងាយយល់មិន

ស្មុគស្មាញទៀតផង ។ នេះគឺជាគោលបំណងធំនៃការមកយកកំណើតជាមនុស្ស នៅពេលដែលព្រះយេស៊ូមកផែនដីក្នុងសណ្ឋានជាសាច់ឈាម ។ គ្មាននរណាម្នាក់បានឃើញព្រះនៅក្នុងសណ្ឋានជាព្រះ និង ក្នុងសិរីរុងរឿងរបស់ព្រះអង្គ ទោះដោយប្រើភ្នែកខាងឯរូបកាយ ឬ ប្រើភ្នែកចិត្តនោះឡើយ ។ វិធីដ៏ប្រសើរបំផុតនោះ គឺព្រះអង្គដាក់យើងក្នុងក្រហែងថ្ម ហើយព្រះអង្គយកព្រះហស្តទ្រង់មកបាំងយើងរហូតព្រះអង្គយាងផុត ទើបយើងអាចរស់បាន។ បន្ទាប់មកព្រះអង្គដកព្រះហស្តទ្រង់ចេញ ដូច្នេះទើបអាច" មើល"ព្រះអង្គពីក្រោយបានគឺយើងមិនអាចមើលចំព្រះភក្ត្រទ្រង់បានឡើយ [៦៨] ។ ពីព្រោះព្រះជាម្ចាស់ធំជាងយើងសម្បើមណាស់ គឺព្រះអង្គគង់នៅក្នុងពន្លឺ" ដែលមិនចូលទៅជិតបាន"ដែលគ្មាននរណាម្នាក់អាចមើលឬឃើញព្រះអង្គបានឡើយ[៦៩] ។ ការមកចាប់កំណើតជាមនុស្សគឺជាវិធីសាស្ត្ររបស់ព្រះជាម្ចាស់ក្នុងការប្រាស្រ័យទាក់ទងរបស់ព្រះអង្គផ្ទាល់ដែលលោកអ្នកនិងខ្ញុំអាចយល់បាន ។ "ព្រះជាម្ចាស់គឺជាព្រះតែមួយគត់ដែលគង់នៅក្នុងព្រះឱរ៉ានៃព្រះបិតាទ្រង់បានសម្តែងឲ្យស្គាល់ព្រះអង្គ" [៧០] ។

ព្រះយេស៊ូបានមានព្រះបន្ទូលនូវពាក្យស្រដៀងគ្នានេះដែរគឺព្រះអង្គមានព្រះបន្ទូលពីអណ្តូង និង ទឹកជាមួយស្ត្រីនៅក្នុងស្រុក ស៊ូខារ គ្រាប់ពូជស្រង៉ែ និង ស្រូវជាមួយអ្នកស្តាប់របស់ព្រះអង្គដែលជាកសិករ។ លោកប៉ូលរៀបចំសាររបស់គាត់តាមបែបផ្សេងៗ នៅពេលដែលគាត់និយាយទៅកាន់សាសន៍យូដា និង សាសន៍ក្រេក ដោយនិយាយពាក្យដែលងាយស្រួលឲ្យក្រុម

---

*[៦៨] យ៉ូហាន ១:១៨ ; និក្ខមនំ ៣៣ :២២ -២៣*

*[៦៩] ១ ធីម៉ូថេ ៦ :១៦*

*[៧០] យ៉ូហាន ១:១៨ពាក្យដែលថា" សម្តែងឲ្យស្គាល់ " មានន័យថាពន្យល់យ៉ាងច្បាស់ផ្តល់របាយការណ៍យ៉ាងល្អិតល្អន់ ។*

និមួយៗស្តាប់[៧១] ។ ការនិយាយដោយសុភាពជាមួយមនុស្សគឺជួយភ្ជាប់រាជសាររបស់យើងឲ្យស៊ីគ្នានឹងអ្នកស្តាប់របស់យើង ។

### ការដោះស្រាយជាមួយពួកអ្នកប្រឆាំងជំទាស់

ការធ្វើការដោយប្រើមធ្យោបាយមួយដែលយើងរឹងប៉ឹងសំរាប់សេចក្តីពិត ប៉ុន្តែសុភាពជាមួយសត្រូវរបស់សេចក្តីពិតដែលហាក់ ដូចជាប្រឆាំងទាស់ទទឹង ។ ចំពោះអ្នកមិនជឿហាក់ដូចជាទំនងព្រមទទួលនូវការរឹងមាំចំពោះសេចក្តីពិតរបស់យើងទៅស៊ុមគ្រលំជាអ្នកមិនជឿទៅវិញ។ តើយើងដោះស្រាយចំពោះការទាស់ទទឹងទាំងនេះយ៉ាងណា?

### អ្នកប្រឆាំងនឹងយើងដែលមិនមែនជាគ្រីស្តបរិស័ទ

សាសនាភាគច្រើនជឿថាមានតែពួកគេតែប៉ុណ្ណោះដែលត្រឹមត្រូវ។ សូម្បីតែសាសនាទាំងនោះដូចជាបាហាយ ដែលបាននិយាយថា សាសនាទាំងអស់គឺមានតម្លៃការបដិសេធន៍ចោលមិនព្រមជឿសាសនាណាមួយនោះក៏ជាលក្ខណៈពិសេសណាស់ដែរ ការទទួលយកតែមួយនោះគឺមានសុពលភាពល្អដែរ ។ ការជឿលើព្រះគ្រីស្តតែមួយអង្គនោះនឹងប្រាកដថាមិនអាចគេចផុតពីការប៉ះទង្គិចជាមួយអ្នកដែលមានជំជឿផ្សេងទៀតដែរ ។

នៅពេលដែលការនេះកើតឡើង យើងអាចនឹកឃើញថា យើងមិនចាំបាច់តតាំងយ៉ាងខ្លាំងក្លាជាមួយជំនឿដែលមិនដូចគេក៏ដោយចុះ ។ សាដ្រាក់ មេសាក់ និងអាបេនិកោ នៅតែសម្តែងនៅក្នុងការគោរពរាប់អាន ទោះបីជាគេមិនបានថ្វាយបង្គំរូបសំណាកធ្វើអំពីមាសរបស់ស្តេចនេប៊ូកានេសាក៏ដោយ ។ ពួកគេគ្រាន់តែបង្ហាញពីការគោរពប្តូរផ្តាច់ថ្វាយបង្គំដល់ព្រះយេហូវ៉ា និងមិនព្រមក្រាបបង្គំចំពោះរូបព្រះដទៃណាឡើយ ។ បីជំពូកក្រោយមក នៅក្នុងដានីយ៉ែល

---

*៧១ ចូរប្រៀបធៀបកិច្ចការ ១៣:១៤-៤៣ ជាមួយកិច្ចការ ១៧:១៦-៣៤*

ជំពូក ៣ ដារីយ៉ូសបានចេញច្បាប់ឲ្យអធិស្ឋានបានតែចំពោះខ្លួនគាត់មួយតែប៉ុណ្ណោះ ។ ដានីយ៉ែលមិនបានចេញប្រតិកម្មតបតមកវិញជាសាធារណៈចំពោះបទបញ្ជានោះឡើយ តែគាត់គ្រាន់តែនៅតែបន្តគោរពប្រតិបត្តិចំពោះជំនឿ របស់គាត់ដោយស្មោះស្ម័គ្រដដែល ។ នៅពេលដែលព្រះតេជគុណភេស្ទុសស្រែកគំហកដាក់ប៉ូលហើយបានចោទប៉ូលថាជាមនុស្សឆ្កួតនោះ លោកប៉ូល មិនបានតបតទៅវិញដោយកំហឹងដែរ ។ គាត់គ្រាន់តែតបថា លោកមានប្រសាសន៍នោះគឺ " ពិតជាត្រឹមត្រូវ និង សមហេតុផលមែន" គឺលោកប៉ូលបានប្រើពាក្យ" ព្រះតេជគុណភេស្ទុស" [៧២] ។ មានការប្រឆាំងច្រើនមែនទែន នៅពេលដែល លោកណាម៉ានដែលបានជាពីជំងឺឃ្លង់ ហើយបានប្រកាសសុំខមាទោសទុកជាមុននៅពេលដែលគាត់គ្រាន់តែឱនបន្ទាបខ្លួនជាមួយស្តេចនៅក្នុងព្រះវិហារនៃព្រះរីម៉ូន ( តែមិនបានឱនទាំងផ្លូវចិត្តឡើយ ) ហោរាអេលីសេ ( ដែលជាមនុស្សមិនយោគយល់ប៉ុន្មាន ) បែរជាប្រាប់គាត់ថា" សូមអញ្ជើញទៅដោយសុខសាន្តចុះ" [៧៣] ។ ការមិនយល់ព្រមទាំងនេះ គឺគ្មានការជំទាស់ត្រង់ណាដែលមិនអាចធ្វើបាននោះឡើយ គឺអាចធ្វើទៅបាន ។

## អ្នកប្រឆាំងដែលជាគ្រីស្តបរិស័ទ

ផ្ទុយទៅវិញគ្រីស្តបរិស័ទគួរតែជាអ្នកដែលព្រមទទួលនូវការសុភាពទន់ភ្លន់ ដែលធ្វើឲ្យអ្នកផ្សាយដំណឹងល្អអាចមានភាពជិតស្និតទៅនឹងការស្តាប់ដែលមិនទាន់ជឿព្រះរបស់ខ្លួន ពីព្រោះគ្រីស្តបរិស័ទយល់ថាការចូលទៅកៀកជាមួយអ្នកមិនជឿតាមបែបសុភាពទន់ភ្លន់នោះ គេគិតថាជាការស៊ុមគ្រលំ

---

*[៧២] កិច្ចការ ២៦:២៥ នៅក្នុងសម័យគម្ពីរសញ្ញាថ្មី " ព្រះតេជគុណ" គឺជាពាក្យលើកកិត្តិយសដល់អ្នកធ្វើការរាជការ ។ ដើម្បីយកគំរូតាម ប៉ូល គ្រីស្តបរិស័ទសព្វថ្ងៃនេះគួរប្រើពាក្យដែលគួរសមចំពោះអ្នកដែលមិនជឿ ហើយប្រឆាំងយើង ។*

*[៧៣] ពង្សាវតារក្សត្រ ៥:១៥-១៩*

ជាមួយគេធ្វើឲ្យជំនឿគ្រីស្ទបរិស័ទចុះខ្សោយ ។ ពួកអ្នកប្រឆាំងនឹងព្រះយេស៊ូ គេបានចោទព្រះអង្គជារឿយៗថាព្រះអង្គទៅរាប់អានជាមួយពួកអ្នកទារពន្ធនិង ពួកមនុស្សមានបាបដោយភ្លេចគិតថា ពួកអ្នកទាំងនោះហើយជាអ្នកឈឺដែល ត្រូវការគ្រូពេទ្យ[៧៤] និងខកខានមិនបានយល់ពីជម្រៅនៃសេចក្ដីស្រលាញ់របស់ ព្រះជាម្ចាស់ដែលព្រះមានសំរាប់ពួកមនុស្សបាត់បង់ និង មិនដឹងពីជម្រៅ ព្រះហឫទ័យដែលចង់បានឲ្យគេបានវិលត្រលប់ជឿព្រះអង្គវិញខ្លាំងប៉ុណ្ណា នោះឡើយ[៧៥] ។ គ្រីស្ទបរិស័ទសាសន៍យូដាបានរិះគន់ដល់លោកពេត្រុស ចំពោះការដែលគាត់ទៅបរិភោគជាមួយពួកមិនកាត់ស្បែក ។ លោកសាវ័កត្រូវ ពន្យល់ឲ្យបានក្បោះក្បាយដល់ពួកគេចំពោះការច្បាស់លាស់នៃការដែលព្រះ ត្រាស់ហៅគាត់ឲ្យទៅសួរសុខទុក្ខដល់កូនីលាស និង ក្រោយមកកូនីលាស បាន កែប្រែចិត្តទទួលជឿដល់ព្រះ[៧៦] ។ ដូច្នេះវាមិនមែនជារឿងប្លែកឡើយដែល គ្រីស្ទបរិស័ទសព្វថ្ងៃនេះបានរិះគន់អ្នកខ្លះទៀត ដែលបានទៅប្រកបជិតស្និត ជាមួយអ្នកដែលមានជំនឿខុសប្លែកពីខ្លួននៅក្នុងខណៈដែលពួកគេបានព្យាយាម ផ្សាយដំណឹងល្អដល់ពួកនោះ ។

នៅពេលដែលរឿងនេះបានកើតឡើងភាគីនិមួយៗត្រូវគិតពីគំនិត ល្អនៃភាគីម្ខាងទៀត គឺត្រូវចងចាំថារឿងនេះអាចមានទំនាស់នឹងគ្នា ដូចជា រឿងរ៉ាវ ដទៃទៀតដែរ គឺថាគ្រីស្ទបរិស័ទមានជំនឿល្អតែគ្រាន់តែមានជំហរផ្សេងពីគ្នា ប៉ុណ្ណោះ។ ដរាបណាមើលឃើញច្បាស់ថា អ្នកនោះទៅស៊ុមគ្រលំជាមួយនឹង ជំនឿដទៃ ឬ មានអំពើបាបនិងប្រាសចាកពីព្រះគម្ពីរ បើពុំដូច្នោះទេ គ្រីស្ទបរិស័ទ

---

*[៧៤] ម៉ាថាយ ៩:១០-១៣*

*[៧៥] លូកា ១៥:១-២ និងរឿងប្រៀបប្រដូចទាំងបីដូចតទៅ ។*

*[៧៦] កិច្ចការ ១១:១-១៨ រឿងនេះត្រូវបានគេនិយាយប្រាប់ពីរដងពីព្រោះវា មិនមែនជាការងាយស្រួលចំពោះគ្រីស្ទបរិស័ទជនជាតិយូដានៅ ដើមសតវត្សទីមួយ ឲ្យជឿថាព្រះពិតជាស្រឡាញ់និងព្រមទទួលសាសន៍ដទៃនោះ ។*

មិនត្រូវស្អប់ ឬ ប្រកាន់ទៅដល់គ្នាទៅវិញទៅមកចំពោះអ្នកដែលមិនបានប្រព្រឹត្ត ដូចខ្លួនទាំងស្រុងនោះ ។ ម្នាក់ៗត្រូវតែឈរឆ្លើយដោះសាចំពោះអ្វីដែលខ្លួនបាន ធ្វើដោយខ្លួនឯងចំពោះព្រះគឺមិនមែនឆ្លើយចោទប្រកាន់អ្នកដទៃនោះទេ [៧៧] ។

## សរុបសេចក្តី

សុភាពទន់ភ្លន់តែមិនរឹងមាំគឺនាំឲ្យយើងបាត់បង់នូវភាពច្បាស់លាស់ ពីរាជសារដែលយើងត្រូវផ្សាយ ។ រឹងប៉ឹង តែមិនមានភាពទន់ភ្លន់ធ្វើឲ្យមាន រនាំងបាំងយើងខណ្ឌដាច់ចេញពីចិត្តនៃអ្នកស្តាប់របស់យើង ។ ព័ន្ធកិរិដែលយក គំរូតាមព្រះគម្ពីរ ដែលមានប្រសិទ្ធិភាពគឺប្រើទាំងពីររឹងមាំ ចំពោះការស្វែងយល់ពី សេចក្តីពិតការសម្រេចចិត្ត និង ការប្រព្រឹត្តិអ្វីដែលទាក់ទងទៅនឹងសេចក្តីពិត តែសុភាពទន់ភ្លន់ពេលទាក់ទងនឹងការញែកដាច់ដោយឡែក ការស្តាប់និងការ យកលំនាំតាមអ្វីមួយដើម្បីឲ្យងាយស្រួលក្នុងការផ្សាយពីសេចក្តីពិតដល់ មនុស្សផងទាំងពួង ។

---

[៧៧] រ៉ូម ១៤:១-១៥:៤

HONEYCOMB 5/1 (October 2004): 103–12



# Abigail, the Peacemaker

*Linda VEJLUPKOVÁ*

The Bible is an all-embracing tapestry, weaving together the nature and purposes of God, its strands relating how he creates, saves, and blesses. It is brim-filled with great names; lives glorious or tragic; exciting plots and impressive outcomes. Yet, as ordinary individuals, we should not be overwhelmed by the immensity of the biblical stories revealing how God works in our world. The scriptures do not demand us to live out a doctrinal system, a moral or religious code as depicted by its contents. Rather, they invite us to understand what it looks like to be human and what is needed for us to enter and mature as human beings in our stories where God is the pivotal theme. In studying biblical stories and characters, we can indeed glimpse how we should or should not live our lives. But, even more, we see how in fact we do live, how our everyday experiences are the very building blocks that God uses to work out his purposes of salvation in us and in the world.

The story of Abigail dramatically compares the character and temperament of a gracious, discerning woman with that of her surly, bigoted husband Nabal. Abigail deflected the blame for a tense state of conflict between Nabal and David, away from her husband to herself,

and, in so doing, brought calm to a situation that had had the potential of becoming a massacre of innocent people. Further, her actions not only appeased David's anger, but stopped him from taking revenge with his own hands.

## Setting the Scene

### Historical background

God had personally governed his people Israel for centuries. Throughout this theocratic rule, God used his anointed leaders to govern his people, the last leaders being called judges. Samuel was the last of the judges, and he also functioned as a prophet. The people had a leader they could trust, a leader of integrity, one on whom they could rely. However, despite Samuel's leading the people closer to God and the nation's growing in its trust of his leadership, Israel longed for a king like the nations around her. Samuel was disappointed with their request, so he brought it before the Lord. After reassuring Samuel that Israel's call for a king represented a crisis of confidence in God himself rather than their lack of trust and confidence in Samuel, God allowed the people to have their way. Through Samuel, God decided that Saul would fulfill the role, and so Saul was acclaimed by the people as their first earthly king.

In 1050 B.C., Saul began his reign as king with national trust at its highest level, the result of Samuel's faithful work rather than the effect of Saul being the new king. Samuel's decision to merge a ceremony of covenant renewal with the formal installation of Saul as king established the king as an instrument of God's covenantal rule of Israel; the king did not govern in his own right, but under the authority of God. The king only exercised authority legitimately while he remained obedient to God. However, Saul showed his true colors and made three major mistakes in which he refused to obey Samuel, subsequently leading to God's rejection of him as king. God was grieved that he had made Saul king over Israel and, again through Samuel, chose the young David to succeed him.

After being rejected by God, Saul became increasingly subject to periods of depression that sometimes verged on madness. Ironically,

David the musician was appointed to provide comfort for Saul's melancholy, and so their lives became intertwined. After David became a national hero by killing the Philistine Goliath, Saul became jealous of him and tried to kill him. David had no choice but to become an outlaw, supported by a band of fugitives who lived on the margins of Israelite society. So David knew that Saul was an irrational ruler whose days were numbered. He knew that he himself was to become king. As the story of Abigail unfolds, David had been living as an outlaw in the desert, surrounded by his six hundred fugitive men whom he had turned into a fighting force, constantly pursued by Saul's men for the last eleven or twelve years. Despite Saul's murderous attempts on his life, David had proved himself loyal and faithful to his king, refusing to retaliate.

**Social and economic background**

David and his men acted as a type of vigilante force, protecting the flocks of wealthy livestock owners from raiders and wild animals. The custom was that when the sheep were sheared, these "security guards" would be paid a gratuity, a thank-you for their protection. Sheep, and the more common goats, were a major feature of ancient Israel's rural economy, being used for food, fabric, within the sacrificial system, as a method of payment and as a measure of wealth. Tents were made with fabric spun from goat hair, as were the curtains of the tabernacle. Sheep were used in striking bargains and were also a measure of God's blessing on the owner. Annually, in springtime, the sheep would be sheared, cutting off the whole woolen coat of the animal. The lanolin contained in the fleece would be removed as a sweet-smelling, softening, thick oil used in cleansing and beauty treatments. The fleece would then be spun to make woolen clothes.

**Time and location**

1 Samuel 25 opens with the statement that Samuel died and all Israel assembled and mourned for him, burying him at his home in Ramah, some five or six kilometers northeast of Jerusalem. David

then moved into the desert of Maon,[1] about forty kilometers south of Jerusalem and just south of Carmel.

**The characters**

We have already noted the character of Israel's king-elect, David. He was in a very difficult position, being hounded by Saul who had already made many attempts on his life, banished to living in the wilderness with his band of renegades, yet knowing from Samuel that he was chosen by God to become heir to the throne. When an amazing opportunity presented itself, he had shown great restraint and understanding of God's law when he had not taken revenge on Saul.[2]

Nabal—the very name meant "Fool," and folly went with this man.[3] Folly is a lack of wisdom or contempt for wisdom, which shows itself in a lack of understanding and obedience. Scripture contrasts human foolishness with divine wisdom. Human folly is seen in rebellion against God, ignoring his way and will, a failure to understand him, encompassing moral and/or spiritual irresponsibility. Nabal was "surly and mean in his dealings."[4] His servant described him as "such a wicked man that no one can talk to him," a man who hurled insults at David's messengers as they offered him their master's greetings.[5] He was disrespectful, stingy and miserly, belligerent, obstinate, arrogant, ill-mannered, and rude. His reluctance to part with his money or possessions was foolishness indeed and, like all miserliness, led to misery.

He "was very wealthy. He had a thousand goats and three thousand sheep."[6] Ungodly people often make the possession of wealth a priority. They do not understand the true nature of wealth, and they do not realize that they will have to face God in judgment. The ungodly grow rich, often obtaining their riches unjustly, accumulating, hoarding, and trusting in their riches. However, the ungodly, like all people, must

---

[1] 1 Sam 25:1.
[2] 1 Sam 24.
[3] 1 Sam 25:25.
[4] 1 Sam 25:3.
[5] 1 Sam 25:15, 17.
[6] 1 Sam 25:2.

leave their riches to others. Lastly, Nabal was a drunk and a glutton.[7] His excessive eating and drinking represented greed, the unrestrained self-indulgence that often leads to a deeper iniquity, and represents a rejection of godly moderation.

Abigail was the antithesis of her husband. She was beautiful both physically and spiritually, bringing pleasure to those who beheld her. She was intelligent,[8] using her human cleverness to the full in God's service and to dedicating her gifts and abilities to him. She was wise and prudent, sensitive and sensible, generous and hospitable.

Outward appearance, that which is visible externally, may reveal the true person, but often it misleads instead. Here, both Nabal and Abigail had outward appearances that reflected their real characters.

### David, Nabal, and Abigail

During the winter months, in the desert of Maon, David and his men had been safeguarding the flocks of Nabal. It was now springtime. On hearing that Nabal was shearing sheep in Carmel, David sent ten of his young men to greet Nabal and ask for the gratuity payment due to them in respect of their protection of his animals and shepherds. They were to suggest to Nabal that he could check with his own servants as to their worth in doing this work and, since sheep-shearing was a festive time, to ask him to give them and their master David whatever he could find for them.

David's men showed grace in their manner of approach to Nabal, and naturally expected grace in return—grace expressed as generosity and kindness. They waited. Instead they were met with insults, prejudice, contempt, and indifference. Nabal answered, "Who is this David? Who is this son of Jesse? Many servants are breaking away from their masters these days. Why should I take my bread and water, and the meat I have slaughtered for my shearers, and give it to men coming from who knows where?"[9] In biblical times, meat was a luxury, eaten at special times such as this festival of sheep-shearing.

---

[7] 1 Sam 25:36.

[8] 1 Sam 25:3.

[9] 1 Sam 25:10–11.

Likewise, this was desert country, so water was also very precious. Nabal was certainly not going to share any hospitality with these rogues!

The ten young men turned round and went back to report every word to their master. David was furious. He commanded four hundred of his men to put on their swords, armed himself likewise, and, leaving two hundred men to stay with their supplies, set out.

Meanwhile, one of Nabal's shepherds told Abigail, Nabal's wife, what had happened. He related how David had sent his messengers to salute Nabal, but that the wealthy owner had responded by tearing into them with insults. The shepherd confirmed that David's men had protected them very well during the previous months, but, unless his mistress could do something quickly, disaster would befall them since nobody could reason with her impossible husband.

Using her intelligence and great discernment, Abigail had to think of a way to bring calm to this tense situation, a way that would appease David whilst protecting Nabal. Acknowledging David as God's anointed, she knew that his anger should be defused and he should be discouraged from carrying out revenge with his own hands. Further, she appreciated that she had to leave room for God to move in his time and in his way in her husband's life. However, Abigail recognized that her conduct must ultimately honor the Lord. She flew into action. She had a feast of bread, wine, mutton (sheep meat), roasted grain, raisin cakes, and fig cakes loaded on to some donkeys, asked her servants to go on ahead of her, and followed on her donkey. She said nothing to Nabal.

As Abigail followed the feast fit for a king, her donkey descending into a ravine, David and his men were descending into the same ravine from the opposite direction. David had just been talking with his men, bemoaning the fact that all his efforts to protect Nabal's property in the desert had been useless, had been rewarded with nothing but insults, his good being repaid with evil. He vowed to destroy every male in Nabal's household by the morning. He was out for revenge. Like Nabal, he was demonstrating folly by ignoring God's command, "Do not seek revenge or bear a grudge against one of your people, but

love your neighbor as yourself."[10] He was stooping to the depths of a Pharaoh of a previous era.[11]

Abigail and David met there on the road. Abigail quickly dismounted and fell on her knees at his feet, her face to the ground in homage, a gesture of reverence, honor, and submission before a future king appointed by God. "My lord, let me take the blame!"[12] What a gentle and sensitive spirit! Of course her husband deserved everything that was coming to him, but Abigail was prepared to shoulder the responsibility for the grave situation. She was not concerned about her own safety and reputation, but was willing to sacrifice herself to protect her husband and the innocent family members whose lives were in such danger. She was also thinking about David's future.

"Please let me speak to you. Listen to what your servant has to say. Don't dwell on what that brute Nabal did. He acts out his name: Nabal, fool—and foolishness oozes from him. I wasn't there when the young men my master sent arrived. I didn't see them. And now, my master, as God lives and as you live, God has kept you from this avenging murder—and may your enemies, all who seek my master's harm, end up like Nabal! Now take this gift that I your servant girl, have brought to my master, and give it to the young men who follow in the steps of my master.

"Forgive my presumption! But God is at work in my master, developing a rule solid and dependable. My master fights God's battles! As long as you live no evil will stick to you.

> If anyone stands in your way,
>     if anyone tries to get you out of the way,
> Know this: Your God-honored life is tightly bound
>     in the bundle of God-protected life;
> But the lives of your enemies will be hurled aside
>     as a stone is thrown from a sling.

"When God completes all the goodness he has promised my master and sets you up as prince over Israel, my master will not have

---

[10] Lev 19:18.

[11] Ex 7–11.

[12] 1 Sam 25:24a.

this dead weight in his heart, the guilt of an avenging murder. And when God has worked things for good for my master, remember me."[13]

Abigail was seeking David's forgiveness for her audacity in approaching him and speaking to him in this way. She was admitting negligence for not being around, for not offering hospitality when David's messengers had arrived. Likewise, she was apologizing for her husband's appalling behavior. Far more imperative, however, was her recognition of David as God's appointed servant and future leader of Israel, a man who fought God's battles. She was declaring the urgency of averting his desire for revenge, the potential guilt of which would have been "on his conscience" as a "staggering burden of needless bloodshed or of having avenged himself."[14] With careful discernment, avoiding rash behavior or speech, and showing tact and wisdom in her relationship with David, Abigail's prudence had averted disaster. A lowly "servant," she had counseled a future king!

David responded by praising God for having sent Abigail to intervene. He asked the Lord to bless her for her good judgment and for keeping him from becoming guilty of bloodshed or of avenging himself, rather than leaving revenge to the Lord. He then accepted the gifts she had brought on the donkeys, telling her to return home in peace. He had acknowledged her words and promised to grant her request.

When Abigail reached home, Nabal was holding his own "king's banquet" and was very drunk. She deferred telling him what she had done until he had sobered up in the morning. On hearing the whole story, he had a heart attack and fell into a coma. Some ten days later, he died. David, learning of Nabal's demise, again praised the Lord, this time for upholding his cause against Nabal, for keeping him from an evil act, and for bringing Nabal's wrongdoing down on his own head. He then sent his servants to Abigail in Carmel, telling her that David had sent them to take her to become his wife. Still true to character, Abigail bowed down to them, with her face to the ground, saying she was ready to serve them and wash their feet—expressing,

---

[13] 1 Sam 25:24b–31 from *The Message*, by E. H. Peterson.

[14] 1 Sam 25:31.

once more, hospitality and servanthood. She quickly mounted a donkey and, attended by her five maids, went with the messengers and became David's wife.

## Reflections

This short, concise saga of human behavior in the face of crisis offers us profound models of godly and ungodly characteristics. We should not, however, attempt to mold ourselves to fit the godly virtues, to "think like this in order to live well." Rather we must read in it the very humanness of the characters, their strengths and weaknesses, their relationships to each other and, ultimately, their relationship with God. And then we can begin to perceive ourselves, our own humanity. Human life, other than mere biology, must deal with God. We need to constantly and prayerfully ask ourselves, "Where does God fit into this? Is he central, or have I placed him on the periphery, or have I omitted him altogether?"

Undoubtedly, Abigail was a noble and virtuous woman, comparable to the later "wife of noble character."[15] She had God at the center of her life: He was her Lord, her King, and her Master. Her thinking and her actions revolved around God. She was sensitive, having deep feelings for others and sympathy for their needs, leading to appropriate action on their behalf.

David also was sensitive, though here he was oversensitive to Nabal's rejection, and this led to his hasty reaction of seeking revenge. It is interesting to consider why David should react in this way in this story, when he had previously chosen not to take revenge against Saul,[16] and would again spare Saul's life in a subsequent encounter.[17] Why was God a central consideration when David was dealing with Saul, but was somehow missing from the equation when it came to Nabal? Could it have been because of the difference in status of the two men? In the situation with Nabal, in his haste did he forget God's commandment?

---

[15]Prov 31:10–31.
[16]1 Sam 24.
[17]1 Sam 26.

It is mine to avenge; I will repay.
    In due time their foot will slip;
their day of disaster is near
    and their doom rushes upon them.[18]

Whatever the reason, David's reaction to Nabal's insults was to take revenge—to kill him and all the male members of his household before the next dawn. How often do we do that, flare up in anger, seeking retaliation against someone for some offense, getting the situation out of all proportion? Yet, if God is truly at the center of our lives, he will answer our prayer: "And lead us not into temptation, but deliver us from the evil one."[19] He will use other people, events, or situations to stop us sinning. He used Abigail to stop David.

As we study the characters in this and other Bible stories, may we prayerfully ask the Holy Spirit to work in us a desire for such godly characteristics as displayed by Abigail: generosity, hospitality, prudence, virtue, patience, wisdom, sensitivity, discernment, and peacemaking. May we ask for these in the words of James: "If any of you lacks wisdom, he should ask God, who gives generously to all without finding fault, and it will be given to him. But when he asks, he must believe and not doubt."[20]

---

[18]Deut 32:35.
[19]Matt 6:13.
[20]Jas 1:5–6a.

សំណុំនិកឃ្មុំ ៥/១ (តុលា ២០០៤)៖ ១១៣-២៩



# អប៊ីកែល
# អ្នកចងស្ពានមេត្រី

*អ្នកស្រី លីនដា វេលូបកូវ៉ា*

ព្រះគម្ពីរគឺជាគ្រឿងប៉ាក់ដែលត្បាញបញ្ចូលគ្នានូវនិស្ស័យលក្ខណៈ និង គោលបំណងរបស់ព្រះជាម្ចាស់ការនោះគឺបង្ហាញអំពីការបង្កបង្កើតការសង្គ្រោះ និង ការប្រទានព្រះពរផ្សេងៗរបស់ព្រះជាម្ចាស់ ។ ព្រះគម្ពីរមានពេញទៅដោយឈ្មោះដ៏អស្ចារ្យជាច្រើន អ្នកមានជីវិតរស់នៅដោយភាពរុងរឿង ឬ រស់នៅក្នុងភាពខ្លោចផ្សាលាយឡំនឹងផែនការសំងាត់ដ៏រំភើប និង ការជាប់ចិត្តទៅលើលទ្ធផលនៃការប្រព្រឹត្តិទាំងឡាយ ។ ទោះបីយ៉ាងនោះក៏ដោយក្នុងឋានៈយើងជាបុគ្គលធម្មតា យើងមិនត្រូវមានការរំភើបខ្លាំងពេក ដោយសាររឿងនៅក្នុងព្រះគម្ពីរដែលមានភាពធំមហិមាដែលបើកសំដែងពីរបៀបដែលព្រះជាម្ចាស់ធ្វើការនៅក្នុងលោកនេះ។ ព្រះគម្ពីរមិនបានបញ្ជាយើងឲ្យរស់នៅក្រៅប្រព័ន្ធគោលលិទ្ធិសីលធម៌ ឬ របៀបរបបសាសនាដូចដែលបានបរិយាយនៅក្នុងមាតិការបស់ព្រះគម្ពីរនោះទេ ។ ប៉ុន្តែប្រាប់យើងឲ្យយល់អំពីថាតើធ្វើជាមនុស្សមានសភាពយ៉ាងណា តើអ្វីទៅដែលជាសេចក្តីត្រូវការរបស់យើងដើម្បីឲ្យ

អាចចូលក្នុងលក្ខណៈ និងមានសភាពពេញវ័យជាមនុស្សភាពនៅក្នុងរឿងរបស់យើងដែលព្រះជាម្ចាស់ជាផ្ទៃរឿងដ៏សំខាន់ ។ នៅក្នុងការសិក្សារឿងទាំងឡាយ និងលក្ខណៈសម្បត្តិនៅក្នុងព្រះគម្ពីរនោះយើងពិតជាអាចមើលត្រួសៗពីរបៀបនៃជីវិតដែលយើងគួររស់នៅ និង មិនគួររស់នៅបែបណានោះ ។ ប៉ុន្តែជាងនោះទៅទៀតយើងឃើញការពិត នៃរបៀបដែលយើងរស់នៅបទពិសោធន៍នៃជីវិតរស់នៅប្រចាំថ្ងៃរបស់យើង គឺជាផ្នែកដ៏សំខាន់ដែលព្រះជាម្ចាស់ប្រើដើម្បីធ្វើការសម្រេចពីគោលដៅនៃការសង្គ្រោះរបស់ព្រះអង្គដែលមាននៅក្នុងជីវិតយើង និងនៅក្នុងពិភពលោកយើងនេះ ។

រឿងរបស់អប៊ីកែលជាការប្រៀបធៀបពីលក្ខណៈសម្បត្តិ និង ការមានអធ្យាស្រ័យល្អ និងមានអំណោយទានយល់ដឹងសភាពការណ៍ចេះសង្កេតរបស់ស្ត្រីម្នាក់ដែលពិតជាស្ត្រីដែលជាជំនួយដ៏ប្រសើរដល់ប្តី ឈ្មោះណាបាលដែលមានភាពគម្រិះគម្រុះគិតថាខ្លួនគ្រាន់បើ ។ អប៊ីកែលបានបង្វែរភ្លើងជម្លោះដែលមានភាពតានតឹងយ៉ាងខ្លាំងរវាងណាបាល និង ដាវីឌ គឺបានបង្វែរចេញពីប្តីរបស់ខ្លួន ហើយទទួលកំហុសនោះទៅដាក់លើខ្លួនឯង តាមរយៈការនេះហើយដែលធ្វើឲ្យហេតុការណ៍មានសភាព ស្ងប់ស្ងាត់ទៅវិញ គេចផុតពីការកាប់សម្លាប់យ៉ាងសាហាវដែលអាចកើត មានឡើងដល់មនុស្សដែល មិនដឹងអីនោះនៅក្នុងផ្ទះរបស់ណាបាលទាំងមូល ។ ជាងនោះទៅទៀតសកម្មភាព របស់នាងមិនមែនគ្រាន់តែរំលត់ កំហឹងរបស់ដាវីឌប៉ុណ្ណោះទេ ប៉ុន្តែអាចបញ្ឈប់គាត់ចេញពីការសងសឹក ដោយផ្ទាល់ដៃរបស់គាត់ទៀតផង ។

## ការរៀបចំឆាក

### សាវតារប្រវត្តិសាស្ត្រ

ព្រះជាម្ចាស់គ្រប់គ្រងរាស្ត្រអ៊ីស្រាអែល គឺជារាស្ត្ររបស់ព្រះអង្គដោយផ្ទាល់ជាច្រើនសតវត្សរ៍កន្លងមកហើយ ។ តាមរយៈការគ្រប់គ្រងតាមបែប

ទេវាធិប្បតេយ្យព្រះជាម្ចាស់ប្រើអ្នកដឹកនាំដែលព្រះអង្គបានចាក់ប្រេងតាំងដើម្បីឲ្យគ្រប់គ្រងដល់រាស្ត្ររបស់ព្រះអង្គអ្នកដឹកនាំចុងក្រោយគេដែលគេបានហៅថាពួកចៅហ្វាយ ។ សាំយូអែលជាអ្នកចុងក្រោយក្នុង ចំណោមពួកចៅហ្វាយហើយមានតួនាទីជាហោរាផងដែរ ។ ពួកបណ្តាជនមានអ្នកដឹកនាំដែលពួកគេអាចទុកចិត្តបានជាអ្នកដឹកនាំដែលសុចរិតជាមនុស្សដែលគេអាចពឹងពាក់បាន ។ ទោះបីយ៉ាងណាក៏ដោយថ្វីបើ សាំយូអែលដឹកនាំមនុស្សចូលទៅកៀកនឹងព្រះជាម្ចាស់ និង ប្រជាជាតិមានការរីកចំរើនក្នុងការទុកចិត្តទៅលើអ្នកដឹកនាំរបស់ខ្លួនកាន់តែខ្លាំងឡើង តែជនជាតិអ៊ីស្រាអែល បែរជាទាមទារឲ្យមានស្តេចដូចជាប្រជាជាតិដែលនៅជុំវិញខ្លួនទៅវិញ ។ សាំយូអែលមានការអស់សង្ឃឹមចំពោះសេចក្តីសំណូមរបស់គេ ដូច្នេះគាត់ក៏នាំរឿងនេះទៅទូលដល់ព្រះជាម្ចាស់ ។ បន្ទាប់ពីព្រះជាម្ចាស់បានបញ្ជាក់អះអាងដល់សាំយូអែលថា ការដែលអ៊ីស្រាអែលអំពាវនាវចង់បានស្តេចនោះ គឺតំណាងឲ្យវិបត្តិនៃការមិនទុកចិត្តដល់ព្រះជាម្ចាស់ផ្ទាល់ជាជាងការខ្វះការទុកចិត្តទៅលើសាំយូអែល ហេតុដូច្នេះហើយបានជាព្រះជាម្ចាស់អនុញ្ញាតឲ្យពួកគេធ្វើតាមចិត្តរបស់ពួកគេ ។ តាមរយៈសាំយូអែលព្រះជាម្ចាស់បានសម្រេចព្រះហឫទ័យថាសូលអាចបំពេញនូវតួនាទីនេះ ដូច្នេះហើយបណ្តាជនបានប្រកាសទទួលយកសូលធ្វើជាស្តេចទីមួយនៅលើផែនដី ។

នៅក្នុងឆ្នាំ ១០៥០ មុនគ្រីស្តសករាជស្តេចសូលចាប់ផ្តើមសោយរាជ្យជាស្តេចដោយមានការទុកចិត្តពីប្រជាជាតិ ក្នុងកំរិតមួយយ៉ាងខ្ពស់បំផុតលទ្ធផលនៃការងារស្មោះត្រង់របស់សាំយូអែលនោះ គឺប្រសើរជាងស្តេចសូលដែលបានក្លាយស្តេចថ្មីនោះទៅទៀត ។ ការសំរេចចិត្តរបស់ សាំយូអែល ដើម្បីដាក់ពិធីតាំងសញ្ញាឡើងវិញបញ្ចូលគ្នាជាមួយការតែងតាំងស្តេចសូលជាផ្លូវការទុកជាផ្នែកមួយរបស់ព្រះជាម្ចាស់ដែលព្រះអង្គ ប្រើដើម្បីគ្រប់គ្រងលើរាស្ត្រអ៊ីស្រាអែល គឺស្តេចមិនមែនគ្រប់គ្រងប្រជារាស្ត្រដោយសិទ្ធិអំណាចផ្ទាល់ខ្លួនឡើយ ប៉ុន្តែដឹកនាំដោយស្ថិតនៅក្រោមអំណាចរបស់ព្រះជាម្ចាស់ ។

ស្តេចអាចអនុវត្តសិទ្ធិអំណាចដោយស្របច្បាប់បាននោះ លុះត្រាណាស្តេចស្ថិតនៅក្រោមការស្តាប់បង្គាប់ដល់ ព្រះជាម្ចាស់ ។ ទោះបីយ៉ាងណាក៏ដោយ ស្តេចសូលបានបង្ហាញពីពណ៌សម្បុរពិតរបស់ខ្លួន និង បានប្រព្រឹត្តកំហុសឆ្គងបីយ៉ាងសំខាន់ៗដែលទ្រង់បានបដិសេធន៍មិនព្រមស្តាប់បង្គាប់ដល់ សាំយូអែលដែលជាហេតុនាំឲ្យព្រះជាម្ចាស់បដិសេធន៍មិនទទួលសូលជាស្តេចតទៅទៀត ។ ព្រះជាម្ចាស់មានការសោកស្តាយយ៉ាងខ្លាំង ដែលព្រះអង្គបានតែងតាំងឲ្យសូលធ្វើជាស្តេចនៃរាស្ត្រអ៊ីស្រាអែល ហើយតាមរយៈសាំយូអែលម្តងទៀត ព្រះជាម្ចាស់បានជ្រើសរើសក្មេងដាវីឌឲ្យធ្វើជាស្តេចជំនួសបន្ទាប់ពីស្តេចសូល ។

បន្ទាប់ពីព្រះជាម្ចាស់លែងទទួលស្គាល់ស្តេចសូលជាស្តេចតទៅទៀតនោះ សូលចាប់ផ្តើមមានការតប់ប្រមល់យ៉ាងខ្លាំង រហូតដល់ពេលខ្លះមានកំហឹងឆេះឆួលយ៉ាងខ្លាំង ។ ដោយសារមានភាពតានតឹងបែបនោះ ហើយទើបគេបានចាត់តាំងឲ្យដាវីឌដែលជាតន្ត្រីករម្នាក់ មកលេងភ្លេង ដើម្បីកំសាន្តចិត្តដល់ភាពសោកសៅរបស់ស្តេចសូល ដោយព្រោះហេតុ ដូច្នេះហើយ ជីវិតរបស់គេទាំងពីរបានវេញបញ្ចូលគ្នាយ៉ាងស្និតស្នាល ។ បន្ទាប់ពីស្តេចដាវីឌក្លាយទៅជាវីរៈបុរសជាតិ ពេលដែលគាត់បានសម្លាប់ កូលីយ៉ាតជាសាសន៍ភីលីស្ទីនរួចមកស្តេចសូលចាប់ផ្តើមច្រណែនដាវីឌ ហើយមានបំណងចង់សម្លាប់ដាវីឌចោល ។ ដាវីឌគ្មានជម្រើសឡើយ គឺ ក្លាយទៅជាជនរស់នៅក្រៅច្បាប់ដែលមានការជួយគាំទ្រពីមនុស្សមួយក្រុមដែលរស់នៅក្នុងសហគមន៍ អ៊ីស្រាអែលគេមិនសូវរាប់រក ។ ដូច្នេះ ដាវីឌដឹងថាស្តេចសូលជាអ្នកគ្រប់គ្រងដែលគ្មានការពិចារណាហើយរង់ចាំតែថ្ងៃធ្លាក់ពីអំណាចនោះ ។ គាត់បានដឹងយ៉ាងច្បាស់ថាខ្លួនគាត់ថ្ងៃមួយ នឹងក្លាយទៅជាស្តេចម្តង ។ ដូចដែលរឿងរបស់អ័ប៊ីកែលត្រូវបានលាតត្រដាងឡើងឲ្យយើងបានដឹង ដាវីឌបានរស់នៅជាជនក្រៅច្បាប់នៅឯវាលរហោស្ថានដែលមានមនុស្សស្មោះត្រង់នៅជុំវិញគាត់ចំនួន៦០០នាក់ ហើយអ្នកទាំងនោះក្រោយមកក្លាយជាអ្នកប្រយុទ្ធដ៏ស្និតស្នាញដោយសារតែមានការដេញ

តាមពីសំណាក់ទាហានរបស់ស្ដេចសូលឥតឈប់ជាបន្តបន្ទាប់នៅក្នុងរយៈពេល ១១ ឬ ១២ ឆ្នាំចុងក្រោយនេះ ។ យ៉ាងណាមិញស្ដេចសូលបានប៉ុនប៉ងធ្វើឃាតលើជីវិតដាវីដជាច្រើនលើកច្រើនសា ដាវីឌនៅតែបង្ហាញពីខ្លួនឯងថាស្មោះត្រង់នៅចំពោះស្ដេចរបស់ខ្លួនជានិច្ចដោយមិនបានឆក់យកឱកាសសងសឹកអ្វីឡើយ ។

## ប្រវត្តិសាស្ត្រនៃសង្គម និងសេដ្ឋកិច្ច

ដាវីឌនិងពួកទាហានរបស់គាត់ដើរតួជាអ្នកយាមល្បាតដោយប្រុងប្រយ័ត្នការពារហ្វូងចៀមរបស់បុរសម្នាក់ដ៏មានស្ដុកស្ដម្ភកុំឲ្យមានចោរព្រៃមកឆក់ប្លន់ និង សត្វសាហាវផ្សេងៗមកបំផ្លាញបានឡើយ ។ តាមទំនៀមទំលាប់នៅពេលដែលគេកាត់រោមចៀមម្ដងៗ ត្រូវគេត្រូវបង់ថ្លៃការពារឲ្យអ្នកការពារដើម្បីសម្ដែងនូវការអរគុណចំពោះ " អ្នកការពារ " ចៀមទាំងនេះ ។ សត្វចៀម និង សត្វពពែគឺជាពពួកសត្វដ៏សាមញ្ញដែលជាសេដ្ឋកិច្ចសំខាន់របស់ពួកអ្នកដែលរស់នៅជនបទនៃប្រទេសអ៊ីស្រាអែលពីបុរាណ គឺពួកគេប្រើសត្វទាំងនោះសំរាប់ធ្វើជាអាហារ ធ្វើជាសរសៃអំបោះសំរាប់ត្បាញ ធ្វើអាវពាក់ប្រើនៅក្នុងប្រព័ន្ធនៃការធ្វើយញ្ញបូជាទុកប្រើក្នុងរូបមន្តនៃការចំណាយនៃការជួញដូរផ្សេងៗ និងប្រើជារង្វាស់នៃការវាស់ពីទ្រព្យសម្បត្តិរបស់មនុស្សថាអ្នកនោះមាន ឬ ក្រ ដោយសារមានសត្វទាំងនោះច្រើនឬតិច ។ សំពត់តង់សម័យនោះគេបានធ្វើឡើងដោយត្បាយចេញពីរោមពពែដូចជា វាំងននដែលគេប្រើនៅក្នុងរោងឧបោសថក៏គេត្បាញពីរោមចៀមដែរ ។ ចៀមត្រូវបានប្រើនៅក្នុងការតថ្លៃចំពោះការដេញថ្លៃអ្វីមួយ ហើយក៏គេប្រើជារង្វាស់នៃព្រះពរដែលព្រះជាម្ចាស់បានផ្ដល់ឲ្យម្ចាស់វាដែរ ។ ជារៀងរាល់ឆ្នាំនៅក្នុងនិទាឃរដូវចៀមត្រូវបានកាត់រោមកាត់រោមដែលនៅជុំវិញខ្លួនវាទាំងមូល ។ ជាតិខ្លាញ់ដែលមាននៅក្នុងរោមចៀមត្រូវបានគេយកចេញយ៉ាងស្អាត នៅពេលនោះរោមចៀមមានក្លិនឈ្ងុយគេបាន

ធ្វើឲ្យមាន ភាពស្រទន់ខ្លាញ់ដែលខាប់គេប្រើសំរាប់សំអាត និង ធ្វើរោមចៀមមានសោភ័ណភាពយ៉ាងល្អ ។ បន្ទាប់មករោមចៀមត្រូវបានគេយកទៅវៃបង្កើតជាក្រណាត់ ។

## ពេលវេលា និងទីកន្លែង

១សាំយូអែល២៥ ចាប់ផ្តើមឡើងដោយសេចក្តីថ្លែងអំពីការស្លាប់របស់សាំយូអែលហើយជនជាតិអ៊ីស្រាអែលទាំងអស់មកប្រមូលផ្តុំគ្នានិងបានកាន់ទុក្ខចំពោះសពរបស់គាត់ ដែលគេបានបញ្ចុះនៅក្នុងរ៉ាម៉ាជាស្រុកកំណើតរបស់គាត់ ដែលមានចំងាយប្រហែល៥ ឬ ៦ គីឡូម៉ែត្រផ្នែកខាងជើងប៉ែកខាងកើតនៃក្រុងយេរូសាឡឹម ។ បន្ទាប់មកដាវីឌចេញទៅក្នុងវាលរហោរស្ថានម៉ាអូន[១] ប្រហែលជា ៤០ គីឡូម៉ែតខាងត្បូងនៃក្រុងយេរូសាឡឹម និង ខាងត្បូងនៃកើមែល។

## លក្ខណៈសម្បត្តិ

យើងបានកត់សំគាល់ហើយអំពីលក្ខណៈសម្បត្តិរបស់ស្តេចនៃប្រទេសអ៊ីស្រាអែលគឺព្រះបាទដាវីឌដែលត្រូវបានជ្រើសរើសឲ្យមកធ្វើជាស្តេច ។ ព្រះបាទដាវីឌស្ថិតនៅក្នុងមុខតំណែងដ៏ពិបាកបំផុត ដោយសារស្តេចសូលបានប៉ុនប៉ងប្រហារជីវិតរបស់ទ្រង់ជាច្រើនដងមកហើយដែលត្រូវនិរទេសរត់គេចទៅរស់នៅវាលរហោរស្ថាន ជាមួយក្រុមរបស់គាត់តែទ្រង់ក៏បានដឹងដែរ តាមរយៈហោរាសាំយូអែលថាទ្រង់គឺជាម្នាក់ដែលព្រះជាម្ចាស់បានជ្រើសរើសឲ្យក្លាយទៅជាអ្នកស្នងក្នុងរាជបល្ល័ង្ក ។ នៅពេលដែលឱកាសដ៏អស្ចារ្យផ្តល់មកឲ្យទ្រង់នោះ ទ្រង់បានបង្ហាញជំហរយ៉ាងអស្ចារ្យ និង ការយល់

---

[១] *១សាំយូអែល ២៥:១*

ដឹងពីក្រឹត្យវិន័យរបស់ព្រះជាម្ចាស់គឺទ្រង់មិនបានឆ្លៀតឱកាសសងសឹកដល់ស្ដេចសូលឡើយ [២]។

ណាបាល ឈ្មោះនេះមានន័យថា " ចំកួតហើយអ្នកចំកួតទៅជាមួយគាត់ដែរ "[៣]។ ចំកួតគឺជាការខ្វះប្រាជ្ញា ឬការមើលងាយប្រាជ្ញាដែលបង្ហាញពីការខ្វះការយល់ដឹងនិងការស្ដាប់បង្គាប់ ។ បទគម្ពីរបង្ហាញពីភាពចំកួត របស់មនុស្សតាមរយៈការទាស់ប្រឆាំងទៅនឹងព្រះជាម្ចាស់ ។ អំពើចំកួតរបស់មនុស្សបង្ហាញឲ្យឃើញការបះបោរប្រឆាំងនិងព្រះជាម្ចាស់មិនអើពើចំពោះផ្លូវរបស់ព្រះជាម្ចាស់ និង បំណងព្រះហឫទ័យរបស់ព្រះអង្គ គឺបរាជ័យក្នុងការស្វែងយល់អំពីព្រះអង្គមិនមានការទទួលខុសត្រូវទាំងខាងផ្នែកសីលធម៌និងខាងវិញ្ញាណ ។ ណាបាល " ពិតជាប្រព្រឹត្តនូវអំពើកម្រិះកម្រុះ និង កាច "[៤]។ អ្នកបំរើរបស់គាត់បានពិពណ៌នាអំពីគាត់ថា " ជាមនុស្សអាក្រក់ដែលគ្មានមនុស្សណាម្នាក់អាចនិយាយរកគាត់បានទេ" ជាមនុស្សដែលប្រមាថដល់អ្នកនាំសាររបស់ដាវីឌនៅពេលដែលពួកគេជូនពាក្យជំរាបសួររបស់ចៅហ្វាយពួកគេ [៥]។ គាត់ជាមនុស្សដែលខ្វះការ គោរព កំណាញ់ និងទុរគត៌ ល្មោភសង្គ្រាម ចចេស ក្រអឺតក្រអោង ចរិតអាក្រក់ ច្រងេងច្រងាង ។ ការស្ទាក់ស្ទើរក្នុងការចែករំលែកលុយកាក់ ឬទ្រព្យសម្បត្តិរបស់គាត់នោះគឺជាអំពើឆ្កួតល្ងីល្ងើបំផុត ហើយភាពកំណាញ់ទាំងអស់នោះនាំគាត់ទៅរកការឈឺចាប់ ។

គាត់ " ជាមនុស្សដែលមានស្ដុកស្ដម្ភ ។ គាត់មានពពែមួយពាន់ និងចៀមបីពាន់ "[៦]។ មនុស្សដែលមិនកោតខ្លាចព្រះគេតែងតែយកទ្រព្យសម្បត្តិ

---

[២] *១សាំយូអែល ២៤*

[៣] *១សាំយូអែល ២៥:២៥*

[៤] *១សាំយូអែល ២៥:៣*

[៥] *១សាំយូអែល ២៥:១៤ ; ១៧*

[៦] *១សាំយូអែល ២៥:២*

របស់គេធ្វើជាអាទិភាពនៃជីវិតរបស់គេ ។ ពួកគេមិនបានដឹងពីភាពពិតនៃទ្រព្យសម្បត្តិនោះទេហើយពួកគេក៏មិនបានដឹងថាថ្ងៃមួយពួកគេនឹងទៅជួបព្រះជាម្ចាស់នៅក្នុងសេចក្តីជំនុំជំរះ ។ អ្នកដែលមិនកោតខ្លាចព្រះ ក្លាយជាអ្នកមានហើយតែងតែប្រមូលទ្រព្យសម្បត្តិរបស់ខ្លួនមកដោយ អំពើអយុត្តិធម៌ និង កាន់តែរីកចំរើនឡើងតំកល់ទុកទាំងចិត្តតែទៅលើទ្រព្យសម្បត្តិរបស់គេទៀតផង ។ ទោះបីយ៉ាងណាក៏ដោយដូចជាមនុស្ស ទាំងអស់ត្រូវតែលះបង់ទ្រព្យសម្បត្តិរបស់គេដល់អ្នកដទៃ ។ ចុងក្រោយ ណាបាលជាមនុស្សប្រមឹកនិងល្មោភស៊ី[៧]។ ការដែលស៊ី និង ផឹកហួសហេតុពេកតំណាងឲ្យភាពលោភលន់ ការបណ្តែតបណ្តោយខ្លួនដែលនាំទៅរកកំហុសយ៉ាងធ្ងន់ធ្ងរ និងជាតំណាងដល់ការបដិសេធន៍ភាពសមរម្យ ក្នុងនាមជាអ្នកកោតខ្លាចព្រះជាម្ចាស់ ។

អ័ប៊ីកែលគឺជាមនុស្សដែលមានភាពផ្ទុយពីប្តីរបស់ខ្លួន ។ នាងមានភាពស្អាតស្អំទាំងខាងរាងកាយ និងខាងវិញ្ញាណនាំភាពត្រេកអរដល់អស់អ្នកដែលកត់សំគាល់សង្កេតមើលនាង ។ នាងជាមនុស្សដែលមានភាព វៃឆ្លាត[៨] ប្រើប្រាជ្ញាក្នុងភាពជាមនុស្សរបស់នាងដើម្បីបំពេញកិច្ចការព្រះហើយថ្វាយអំណោយទាន និង សមត្ថភាពរបស់នាងដល់ព្រះ ។ នាងជាមនុស្សដែលមានប្រាជ្ញា ហើយឆ្លាតរហ័សដឹងខ្លួន និងសមហេតុសមផលចិត្តល្អនិងរួសរាយរាក់ទាក់ ។

អ្វីដែលលេចឡើងនៅខាងក្រៅដែលយើងមើលឃើញផ្នែកនោះអាចបង្ហាញពីអត្តចរិកមនុស្សពិត ប៉ុន្តែជារឿយៗវាអាចនាំឲ្យយើងយល់ខុសទៅវិញ ។ នៅទីនេះណាបាល និង អ័ប៊ីកែលមានសភាពលេចឡើងនៅខាងក្រៅដែលឆ្លុះបញ្ចាំងពីលក្ខណៈសម្បត្តិពិតប្រាកដរបស់ពួកគេ ។

---

[៧] *១សាំយូអែល ២៥:៣៦*

[៨] *១សាំយូអែល ២៥:៣*

## ដាវីឌ ណាបាល និងអប៊ីកែល

នៅសិសិររដូវ នៅឯវាលរហោស្ថានម៉ាអូន ដាវីឌ និងមនុស្សរបស់គាត់បានកំពុងថែររក្សាហ្វូងចៀមរបស់ណាបាល ។ ឥលូវនេះវាជារដូវស្លឹកឈើលាស់ ។ នៅពេលដែលឮថាណាបាលកំពុងកាត់រោមចៀមនៅ ឯកើមែល ដាវីឌបានបញ្ជូនមនុស្សកំលោះរបស់គាត់១០នាក់ឲ្យទៅជំរាបសួរណាបាល ហើយសូមប្រាក់ឧបត្ថម្ភខ្លះមកពីគាត់ដោយយល់ដល់ការដែលពួកគេ និង ដាវីឌ បានការពារហ្វូងសត្វ និង ចៀមរបស់គាត់ ។ ពួកគេបានប្រាប់ដល់ណាបាលថាគាត់អាចសួរតាមរយៈអ្នកបំរើរបស់ លោកអំពីតំលៃដែលពួកគេបានធ្វើការ ហើយដោយព្រោះការកាត់រោមចៀមគឺជាពេលវេលាបុណ្យត្រូវពេលសុំដើម្បីឲ្យលោកជួយពួកគេ និងចៅហ្វាយពួកគេ គឺដាវីឌ តាមការដែលលោកអាចជួយបាន ។

មនុស្សរបស់ដាវីឌបង្ហាញពីរបៀបសមរម្យក្នុងការទៅជួប ណាបាល ហើយជាធម្មតាតែងតែសង្ឃឹមចង់បាននូវភាពសមរម្យទាំងនោះមកវិញតាមរយៈចិត្តល្អនិងសប្បុរស ។ ពួកគេរង់ចាំយ៉ាងយូរ ។ តែផ្ទុយទៅវិញពួកគេជួបនូវការប្រមាថ ភាពប្រកាន់ការមើលងាយ និង ភាពព្រងើយកន្តើយ ។ ណាបាលបានឆ្លើយថា " តើដាវីឌជាអ្វី ? ហើយកូនអ៊ីសាយអ្វី ? សព្វថ្ងៃនេះមានបាវជាច្រើនដែលរត់ចោលពីចៅហ្វាយរបស់ខ្លួនទៅ ។ ដូច្នេះតើត្រូវឲ្យអញយកនំបុ័ងរបស់អញព្រមទាំងទឹក និង សត្វដែលអញបានសំលាប់សំរាប់ពួកជាងកាត់រោមចៀម ទៅចែកដល់ពួកមនុស្សដែលអញមិនដឹងថា មកពីណាផងឬអី?"[៩]។ នៅក្នុងសម័យព្រះគម្ពីរ សាច់គឺជាភាពប្រណិតដែលគេបរិភោគនៅពេលពិសេស ដូចជាពេលបុណ្យកាត់រោមចៀមនេះអ៊ីចឹងដែរ ។ ដូចគ្នាដែរនេះជាប្រទេសដែលពេញទៅដោយវាលរហោស្ថាន ដូច្នេះទឹកក៏មានសារៈសំខាន់ខ្លាំងណាស់ដែរ ។ ណាបាល ប្រាកដជាមិនចែកចាយនូវភាពស្វាគមន៍រាក់ទាក់របស់ខ្លួនដល់មនុស្សប៉ុនសន្ធរឿងទាំងអស់នេះទេ!

[៩] ១ សាំយូអែល ២៥:១០-១១

មនុស្សកំលោះទាំង១០នាក់នេះបានត្រលប់ថយក្រោយ ហើយវិលត្រលប់ទៅរាយការណ៍នូវគ្រប់ទាំងពាក្យពេចន៍ប្រមាថទាំងនេះ ដល់ចៅហ្វាយរបស់ខ្លួនវិញ ។ ដាវីឌមានកំហឹងយ៉ាងខ្លាំង ។ គាត់បានបញ្ជាមនុស្សរបស់គាត់៤០០នាក់ឲ្យក្រវាត់ដាវគ្រប់គ្នាឡើងនោះគេក៏ក្រវាត់ដាវរៀងៗខ្លួន ហើយទុកមនុស្ស ២០០នាក់ទៀតនៅថែរក្សាអីវ៉ាន់ ។

ក្នុងពេលជាមួយគ្នានោះ មានម្នាក់ជាអ្នកគង្វាលចៀមរបស់ ណាបាល បានឮរឿងនេះហើយបានប្រាប់ទៅ អ័ប៊ីកែលដែលជាប្រពន្ធរបស់ ណាបាល នូវអ្វីដែលបានកើតមានឡើង ។ គេបានប្រាប់ពីអ្វីដែល ដាវីឌ បានបញ្ជូនមនុស្សរបស់គាត់ឲ្យទៅជំរាបសួរដល់ណាបាល ប៉ុន្តែម្ចាស់ដ៏ស្កុកស្គម្នាក់នោះ បែរជាឆ្លើយទៅវិញនូវពាក្យប្រមាថមើលងាយ ។ អ្នកគង្វាលចៀមនោះបានបញ្ជាក់ថែមទៀតថា មនុស្សរបស់ដាវីឌបានការពារ ពួកគេបានយ៉ាងល្អក្នុងរយៈពេលប៉ុន្មានខែមុននេះ បើសិនជាលោកស្រី មិនមានសកម្មភាពឲ្យឆាប់រហ័សទេ នោះគ្រោះថ្នាក់នឹងកើតមកដល់លោកម្ចាស់ និង គ្រួរបស់លោក ពីព្រោះគ្មាននរណាម្នាក់អាចទៅឲ្យហេតុផល ដល់ប្ដីរបស់លោកស្រីបានឡើយ ។

ដោយប្រើប្រាជ្ញា និង ការយល់ដឹងរបស់នាង អ័ប៊ីកែល បានគិតរកមធ្យោបាយយ៉ាងណា ដើម្បីឲ្យជម្លោះនៅក្នុងហេតុការណ៍នេះមានភាពស្ងប់ស្ងាត់ជាមធ្យោបាយដែលធ្វើឲ្យដាវីឌស្ងប់ចិត្ត ហើយការពារប្ដីរបស់ខ្លួន ។ ការទទួលស្គាល់ដាវីឌថាជាអ្នកដែលព្រះបានចាក់ប្រេងតាំង នាងបានដឹងថាកំហឹងទាំងនេះនឹងត្រូវស្ងប់ទៅ ហើយនាងនឹងមិនលើកទឹកចិត្តឲ្យនាំការសងសឹកទុកនៅក្នុងដៃរបស់គាត់នោះទេ ។ ជាងនោះទៅទៀតនាងបានសរសើរថា នាងនឹងទុកឱកាសឲ្យព្រះធ្វើការនៅក្នុងពេលរបស់ព្រះអង្គនិងក្នុងមធ្យោបាយរបស់ព្រះអង្គនៅក្នុងជីវិតប្ដីរបស់នាង ។ ទោះបីយ៉ាងណាក៏ដោយ អ័ប៊ីកែល ទទួលស្គាល់ថាសកម្មភាពទាំងឡាយ របស់នាងត្រូវតែថ្វាយកិត្តិយសទៅព្រះជាម្ចាស់ ។ នាងក៏ធ្វើសកម្មភាពភ្លាម ។ នាងក៏ចាប់ផ្ដើមចាត់ចែងនំបុ័ង

ស្រា និងសាច់ចៀម លាជ ផ្លែទំពាំងបាយជូរក្រៀម និង ផ្លែល្វាក្រៀមផ្ទុកលើសត្វលានាំទៅ ហើយប្រាប់ឲ្យបាវបំរើរបស់នាងដើរមុខនាង ។ នាងមិនបានប្រាប់អ្វីដល់ប្តីរបស់នាងទេ ។

ក្នុងខណៈពេលដែលអ័ប៊ីកែល នាំជំនូនទៅឲ្យស្តេចសោយដោយជិះលើខ្នងលាចុះតាមច្រកភ្នំចំនឹងមុខទ័ពដាវីឌ និង មនុស្សរបស់លោកមកតាមច្រកនោះដែរទល់មុខគ្នា ។ ដាវីឌទើបតែនិយាយជាមួយមនុស្សរបស់លោកថាដែលអញបានថែរក្សាទ្រព្យរបស់ទាំងប៉ុន្មាននៃមនុស្សនេះ ឲ្យគង់វង្សនៅបានក្នុងទីរហោស្ថានឥតមានបាត់អ្វីណាមួយឡើយនោះពិតប្រាកដជាឥតប្រយោជន៍សោះ វាបានប្រព្រឹត្តការអាក្រក់ស្នងនឹងការល្អដល់អញវិញ ។ លោកបានស្បថថានៅពេលព្រឹកនេះលោកនឹងសំលាប់កូនប្រុសៗទាំងអស់របស់ណាបាល ។ លោកចេញមកដើម្បីសងសឹក ។ មនុស្សដូចជា ណាបាល នេះបានបង្ហាញពីភាពឆ្កួតលីលើដោយបដិសេធន៍ព្រះរាជបញ្ញារបស់ព្រះដែលថា " មិនត្រូវសងសឹក ឬ ចងគំនុំគុំគួន និង កូនចៅរបស់សាសន៍ឯងឡើយ គឺត្រូវស្រឡាញ់អ្នកជិតខាងដូចខ្លួនឯងវិញអញនេះជាព្រះយេហូវ៉ា "[១០] ។ លោកបានអោនទៅលើជម្រៅនៃសម័យកាលមុនរបស់ស្តេចផារោន[១១] ។

អ័ប៊ីកែល និង ដាវីឌបានជួបគ្នាតាមផ្លូវនៅទីនោះ ។ អ័ប៊ីកែលបានសម្រូតចុះយ៉ាងលឿនពីលើខ្នងលា ហើយលុតជង្គង់ក្រាបទៀបជើងលោកដោយផ្កាប់មុខចុះដល់ដីនៅក្នុងអភិវន្ទនាការនៃកាយវិការគោរពផ្តល់កិត្តិយសនិងការចុះចូលទៅ ចំពោះស្តេចនៅពេលអនាគតដែលព្រះជាម្ចាស់បានចាក់ប្រេងតាំងជ្រើសឡើង ។ " ឱលោកម្ចាស់ខ្ញុំអើយ សូមឲ្យទោសនោះធ្លាក់មកលើរូបខ្ញុំម្ចាស់វិញចុះ "[១២] យី ! នាងមានវិញ្ញាណសុភាព និង ឆាប់ដឹងខ្លួនល្អណាស់

---

[១០] *លេវីវិន័យ ១៩:១៨*

[១១] *និក្ខមនំ ៧-១១*

[១២] *១សាំយូអែល ២៥:២៤*

ហ្នំ ! ពិតហើយប្ដីនាងគួរតែទទួលអ្វីៗទាំងអស់មកលើខ្លួនរបស់គាត់ ប៉ុន្តែ អប៊ីកែល បានរៀបចំទទួលអំរែកបន្ទុកនៃការទទួលខុសត្រូវសំរាប់ហេតុការណ៍ធ្ងន់ធ្ងរហួតដល់បាត់បង់ជីវិតទាំងគ្រួនេះ ។ នាងមិនបានគិតគូរពីសុវត្ថិភាព និង កេរ្តិ៍ឈ្មោះរបស់ខ្លួនឡើយ ប៉ុន្តែស្ម័គ្រចិត្តលះបង់សេចក្តីសុខផ្ទាល់ខ្លួនដើម្បីការពារប្តី និង សមាជិកគ្រួសារដែលមិនដឹងអីដែលកំពុងជួបនូវគ្រោះថ្នាក់ ។ នាងក៏បានគិតអំពីអនាគតរបស់ដាវីឌដែរ ។

" សូមឲ្យខ្ញុំជាបាវស្រីរបស់លោកជំរាបជូនលោកស្ដាប់សិនហើយ សូមស្តាប់ពាក្យបាវស្រីលោកសិន ។ កុំឲ្យលោកម្ចាស់តាំងចិត្តចំពោះ ណាបាលជាមនុស្សកំណាចនោះឡើយ ត្បិតគាត់ដូចជាឈ្មោះគាត់ពិតមែនគឺគាត់ឈ្មោះណាបាលហើយក៏មានសេចក្ដីចំកួតនោះឯង ឯខ្ញុំជាបាវបំរើស្រីរបស់លោកខ្ញុំឥតបានឃើញពួកកំលោះរបស់លោកម្ចាស់ដែលបានចាត់ទៅនោះទេ ដូច្នេះឱលោកម្ចាស់ខ្ញុំអើយខ្ញុំស្បថដោយនូវព្រះយេហូវ៉ា ដ៏មានព្រះជន្មរស់នៅ ហើយដោយនូវព្រលឹងលោកដែរថាពួកខ្មាំងសត្រូវរបស់លោកម្ចាស់នៃខ្ញុំ ព្រមទាំងអស់អ្នកដែលរករឿងបង្កើតការអាក្រក់ ដល់លោកនឹងបានដូចណាបាលនោះឯង ដោយព្រោះព្រះយេហូវ៉ាឃាត់លោកមិនឲ្យកំចាយឈាម ហើយមិនឲ្យសងសឹកដោយដៃលោកឡើយ រីឯជំនូននេះដែលខ្ញុំម្ចាស់ជាអ្នកបំរើរបស់លោកបាននាំយកមកជូននោះសូមចែកឲ្យដល់ពួកកំលោះដែលតាមលោកម្ចាស់នៃខ្ញុំមកនោះចុះ ។

" សូមអត់ទោសសេចក្ដីរំលងនេះ ដល់បាវស្រីរបស់លោកផង ! ដ្បិតព្រះយេហូវ៉ានឹងតាំងជំនួរវង្សរបស់លោកម្ចាស់នៃខ្ញុំឲ្យមាំមួនឡើងជាពិតប្រាកដ ពីព្រោះលោកម្ចាស់នៃខ្ញុំតែងធ្វើសង្គ្រាមដែលព្រះយេហូវ៉ា តម្រូវឲ្យលោក ហើយនឹងគ្មានឃើញសេចក្ដីអាក្រក់ណានៅក្នុងលោកម្ចាស់ឡើយគ្រប់មួយជីវិតរបស់លោក ។

មួយទៀតបើមានមនុស្ស លើកដេញតាមរកប្រហារជីវិតរបស់លោក ក៏ដោយគង់តែជីវិតលោកម្ចាស់នៃខ្ញុំ នឹងបានចងជាប់ក្នុងបាច់នៃជីវិត ជាមួយនឹងព្រះយេហូវ៉ាជាព្រះរបស់លោកដែរ ឯជីវិតរបស់ពួកខ្មាំងសត្រូវរបស់លោកនឹងត្រូវបាត់ទៅដូចជា បាញ់ចេញពីខ្សែដង្ហក់វិញ ។

" រួចកាលព្រះយេហូវ៉ាបានប្រោសលោកម្ចាស់នៃខ្ញុំ តាមគ្រប់ទាំងសេចក្ដីល្អដែលទ្រង់បានមានបន្ទូលពីដំណើរលោក ព្រមទាំងតាំងលោកឡើងឲ្យគ្រប់គ្រងលើសាសន៍អ៊ីស្រាអែល ហើយនោះដំណើរនេះមិនបានជាហេតុឲ្យលោកតូចចិត្តស្តាយដោយ លោកកំចាយឈាមគេដោយឥត ហេតុ ឬបានសងសឹកដល់គេដោយខ្លួនលោកឡើយ ហើយកាលណា ព្រះយេហូវ៉ា បានប្រោសសេចក្ដីល្អដល់លោកម្ចាស់ នោះសូមទាននឹកចាំពីខ្ញុំជាបាវស្រីរបស់លោកផង "[១៣] ។

អប៊ីកែលបានសុំការអត់ទោសពីដាវីឌ នៅក្នុងការជួបជាមួយនឹងលោក ដោយក្លាហាននិងនិយាយទៅចំពោះលោកក្នុងមធ្យោបាយនេះ ។ នាងបានទទួលកំហុសពីភាពអវត្តមានរបស់នាង ដែលមិនបានផ្ដល់ការរាក់ទាក់នៅពេលដែលមនុស្សរបស់ដាវីឌបានមកដល់ ។ ដូច្នេះបានជានាងធ្វើការសូមទោសជំនួសប្ដីរបស់នាងចំពោះអត្តចរិតមិនល្អ ។ ចាំបាច់ជាងនេះទៅទៀត ទោះបីយ៉ាងណាក៏ដោយគឺនាងបានទទួលស្គាល់ថា ដាវីឌគឺជាអ្នកបំរើដែលព្រះបានចាក់ប្រេងតាំងឲ្យធ្វើជាអ្នកដឹកនាំនៃប្រទេស និង ជាមនុស្ស ដែលប្រយុទ្ធក្នុងសមរភូមិដែលព្រះជាម្ចាស់ប្រទានឲ្យ ។ នាងបានប្រកាសពីបំណងសងសឹកយ៉ាងឆាប់រហ័សរបស់លោកដែលជាកំហុសដ៏មានសក្ដានុពល " មាននៅក្នុងមនសិការរបស់លោក " ទុកដូចជា បន្ទុកមួយដែល ត្រូវការកំចាយឈាម ឬ

---

[១៣] *១សាំយូអែល ២៥:២៨*

ចេញពីការសងសឹកដោយខ្លួនលោកផ្ទាល់"[១៩] ។ ជាមួយការស្វែងយល់ដោយប្រុងប្រយ័ត្នជៀសចេញពីអត្តចរិត និង ការនិយាយលឿនជ្រុលពេកនោះព្រមទាំងបង្ហាញពីភាពប៉ិនប្រសព្វ និងប្រាជ្ញានៅក្នុងការទំនាក់ទំនង របស់នាងជាមួយដាវីឌ ភាពវៃឆ្លាតរបស់អ័ប៊ីកែលបានស្តារស្ថានភាពគ្រោះថ្នាក់ឲ្យត្រឡប់សុខសាន្តវិញ ។ ក្នុងឋានៈជា " អ្នកបំរើ" យ៉ាងតូចទាប នាងបានជួយគំនិតដល់ស្តេចនៅពេលអនាគត ។

ដាវីឌបានតបឆ្លើយដោយសរសើរតំកើងព្រះជាម្ចាស់ ដែលបានបញ្ជូនអ័ប៊ីកែលឲ្យមកជួយធ្វើអន្តរាគមន៍ ។ លោកបានសូមព្រះឲ្យប្រទានព្រះពរដល់នាងសំរាប់ការមានសុភវិនិច្ឆ័យយ៉ាងល្អរបស់នាង ហើយបានជួយទប់លោកចេញពីការក្លាយទៅជាអ្នកមានកំហុសនៃការកំចាយឈាម ឬ សងសឹកដោយខ្លួនឯងជាជាងទុកការសងសឹកនេះថ្វាយដល់ព្រះអម្ចាស់វិញ ។ បន្ទាប់មកលោកបានទទួលជំនួនដែលនាងបាននាំមកនៅផ្ទុកលើខ្នងលានោះ ហើយប្រាប់នាងឲ្យវិលទៅផ្ទះវិញដោយសុខសាន្ត ។ លោកបានទទួលស្គាល់ ពាក្យសំដីរបស់នាង ហើយសន្យាទទួលអ្វីដែល នាងសំណូមពរ ។

ពេលដែលអ័ប៊ីកែលបានមកដល់ផ្ទះណាបាលបានធ្វើ " ពិធីជប់លៀងយ៉ាងធំមួយ " ដោយខ្លួនឯងហើយគាត់ស្រវឹងស្រាយ៉ាងខ្លាំង ។ នាងមិនបានប្រាប់នូវអ្វីដែលនាងបានធ្វើ រហូតដល់ណាបាលស្វាងស្រានៅពេលព្រឹកឡើង ។ នៅពេលដែលពរឿងទាំងអស់នោះរួចមក ពេលនោះលោកក៏ភ័យឡើងគាំងបេះដូង ហើយក៏សន្លប់រឹងស្តូកទៅ ។ ប៉ុន្មានជាដប់ថ្ងៃក្រោយមកលោកក៏ស្លាប់ទៅ ។ ដាវីឌបានដឹងពីមរណៈភាពរបស់ ណាបាល ដាវីឌបានសរសើរតំកើងព្រះជាម្ចាស់ម្តងទៀត ដោយព្រោះទ្រង់បានទំលាក់ទោសទៅលើណាបាលវិញដោយមិនឲ្យលោកប្រព្រឹត្តការអាក្រក់ឡើយ ហើយនាំនូវកំហុសរបស់ណាបាល ចុះនៅលើក្បាលរបស់ខ្លួនផ្ទាល់ ។ បន្ទាប់មកលោក

---

[១៩] ១សាំយូអែល២៥:៣១

បញ្ជូនបាវរបស់លោក ទៅឯអប៊ីកែល នៅឯ កើមែលដោយ ប្រាប់នាងថា ដាវីឌ បានបញ្ជូនពួកគេមកឲ្យទទួលនាងធ្វើជាប្រពន្ធរបស់លោក ។ នៅតែពិតចំពោះអត្តចរិតរបស់នាងអប៊ីកែលក្រាប ចុះនៅចំពោះពួកគេដល់ដី ដោយនិយាយថា នាងប្រុងប្រៀបជាស្រេចដើម្បីបំរើពួកគេ និង លាងជើងឲ្យពួកគេនាងបង្ហាញម្តងទៀតនូវភាពរាក់ទាក់និងភាពជាអ្នកបំរើ ។ នាងបានឡើងលើខ្នងលាជាមួយអ្នកបំរើរបស់នាងប្រាំនាក់ទៀតទៅជាមួយអ្នកនាំសាររបស់ដាវីឌ ហើយក៏ក្លាយទៅជាប្រពន្ធរបស់ដាវីឌតទៅ ។

## ការសញ្ជឹងគិតពិចារណា

រឿងដ៏ខ្លីដែលមានអត្ថន័យនៃអត្តចរិតរបស់មនុស្សចំពោះការជួបប្រទះនិងវិបត្តិផ្តល់ឲ្យយើងនូវគំរូយ៉ាងល្អ អំពីលក្ខណៈសម្បត្តិរបស់មនុស្សដែលបង្ហាញពីកោតខ្លាចព្រះនិងមិនកោតខ្លាចព្រះ ។ ទោះបីយ៉ាងណាក៏ដោយយើងមិនត្រូវដាក់ខ្លួនរបស់យើងទាំងស្រុងចូលទៅក្នុងតំលៃនៃការកោតខ្លាចព្រះដោយ " គិតដូចនេះថានឹងអាចរស់ក្នុងជីវិតល្អនោះឡើយ " ។ ផ្ទុយទៅវិញយើងត្រូវអានរឿងនេះ ដោយពិចារណាពីភាពជាមនុស្សដែលមានលក្ខណៈសម្បត្តិចំណុចខ្លាំង និង ចំណុចខ្សោយពីទំនាក់ទំនងរវាងគ្នាទៅវិញទៅមក និង ពិតប្រាកដហើយទំនាក់ទំនងជាមួយព្រះជាម្ចាស់របស់នោះឯងសំខាន់ ។ បន្ទាប់មកយើងនឹងចាប់ផ្តើមមើលមកខ្លួនយើងភាពជាមនុស្សផ្ទាល់របស់យើង ។ ជីវិតមនុស្សវាមិនគ្រាន់តែជាជីវសាស្ត្រប៉ុណ្ណោះទេត្រូវតែទាក់ទងជាមួយព្រះ។ យើងត្រូវតែបន្ត ហើយអធិស្ឋានជានិច្ចដោយសួរខ្លួនឯងថា " តើកន្លែងណាដែលព្រះអាចធ្វើការបាន ? " តើទ្រង់ជាអ្នកដឹកនាំជីវិត ឬខ្ញុំដាក់ព្រះអង្គ នៅក្នុងបរិមណ្ឌល ឬក៏ខ្ញុំលុបព្រះអង្គចោលតែម្តង?"។

គ្មានការសង្ស័យឡើយអប៊ីកែលជាអ្នកដែលមានប្រាជ្ញ និង ស្ត្រីដែលមានតំលៃក្រោយមកប្រៀបធៀបទៅនឹង " ប្រពន្ធដែលមានលក្ខណៈសម្បត្តិ

ថ្លៃថ្នូរ "[១៥]។ នាងមានព្រះទុកជាចំណុចកណ្តាលនៃជីវិតរបស់នាងទ្រង់ គឺជាព្រះអម្ចាស់ជាស្តេច និងជាចៅហ្វាយរបស់នាង ។ ការគិត និង សកម្មភាពរបស់នាងគឺនៅជុំវិញព្រះជានិច្ច ។ នាងងាយដឹង ហើយមានជំរៅចិត្តយល់ពីអារម្មណ៍អ្នកដទៃ និង រួមចំណែកឈឺឆ្អាលនឹងសេចក្តីត្រូវការរបស់ពួកគេដឹកនាំពួកគេឆ្ពោះទៅរកសកម្មភាពដ៏ត្រឹមត្រូវ ។

ដាវីឌក៏ជាមនុស្សឆាប់រវាសរវៃដែរ ទោះបីជាលោកមានអារម្មណ៍ឆាប់ខឹងយ៉ាងខ្លាំងទៅលើការបដិសេធន៍របស់ណាបាល ហើយការនេះនាំគាត់ទៅរកសកម្មភាពអាក្រក់ ដែលស្វែងរកការសងសឹក ។ វាជាការគួរឲ្យចាប់អារម្មណ៍ក្នុងការពិចារណាថាហេតុអ្វីបានជាដាវីឌបញ្ចេញសកម្មភាពយ៉ាង ដូច្នេះនៅក្នុងរឿងនេះនៅពេលដែលលោកបានសម្រេចកាលពីមុននោះ ដែលលោកមិនបានឆក់យកឱកាសសងសឹកដល់ស្តេចសូល [១៦] ហើយមិនត្រឹមតែប៉ុណ្ណោះជួយរក្សាជីវិតស្តេចសូលទៀតផង នៅក្នុងរឿងជួបប្រទះដូចគ្នា [១៧]។ ហេតុអ្វីបានជាព្រះទ្រង់គឺជាម្ចាស់ជីវិតរបស់ដាវីឌ នៅពេលដែលអនុវត្តជាមួយស្តេចសូល ប៉ុន្តែដូចជាមានការបាត់បង់សភាពនោះនៅពេលដែលអនុវត្តជាមួយណាបាល ? តើដោយព្រោះតែមនុស្សពីរនាក់នោះមានឋានៈខុសគ្នាឬ ? នៅក្នុងហេតុការណ៍ជាមួយ ណាបាលភាពរួសរាន់របស់លោកបានភ្លេចព្រះរាជបញ្ជារបស់ព្រះឬ?

គឺសេចក្តីសងសឹកនឹងសេចក្តីសងគុណនោះគឺស្រេចនូវអញក្នុងកាលដែលយើងគេរអិលភ្លាត ដ្បិតថ្ងៃដែលគេត្រូវអន្តរាយ នោះជិតមកដល់ ហើយការដែលត្រូវមកលើគេនោះជិតមកដល់ហើយ [១៨] ។

---

[១៥] *សុភាសិត ៣១:១០-៣១*

[១៦] *១សាំយូអែល ២៤*

[១៧] *១សាំយូអែល ២៦*

[១៨] *ចោទិ ៣២:៣៥*

ទោះបីជាមានហេតុផលយ៉ាងណាក៏ដោយការឆ្លើយរបស់ដាវីឌទៅចំពោះការប្រមាថរបស់ណាបាលគឺត្រូវតែសងសឹកសំលាប់គាត់ និង មនុស្សប្រុសៗទាំងអស់នៅក្នុងគ្រួសាររបស់គាត់មុននឹងថ្ងៃរះឡើង។ តើយើងតែងតែធ្វើយ៉ាងដូច្នេះ ជារឿយៗប៉ុណ្ណាពុះកញ្ជ្រោលឡើងក្នុងសេចក្តីកំហឹងស្វែងរកការតបស្នងវិញ ប្រឆាំងទៅនឹងនរណាម្នាក់ដែលប៉ះពាល់ដល់ យើងសងទៅតាមអ្វីដែលគេវាយមកឲ្យយើង? តែប្រសិនបើ ព្រះជាចំណុចកណ្តាលនៃជីវិតរបស់យើងនោះ ទ្រង់នឹងឆ្លើយសេចក្តីអធិស្ឋានយើង " កុំនាំយើងខ្ញុំទៅក្នុងសេចក្តីល្បួងឡើយ តែសូមប្រោសយើងខ្ញុំឲ្យរួចពីសេចក្តីអាក្រក់វិញ"[១៩]។ ទ្រង់នឹងប្រើមនុស្សផ្សេងទៀត ហេតុការណ៍ផ្សេងទៀតដើម្បីបញ្ឈប់មិនឲ្យយើងធ្វើបាប ។ ទ្រង់ប្រើ អ័ប៊ីកែលដើម្បីបញ្ឈប់ដាវីឌ ។

ដូចដែលយើងសិក្សាពីលក្ខណៈសម្បត្តិនៅក្នុងរឿងនេះក៏ដូចជានៅក្នុងរឿងផ្សេងៗទៀតនៅក្នុងព្រះគម្ពីរ ចូរឲ្យយើងសូមព្រះវិញ្ញាណបរិសុទ្ធធ្វើការនៅក្នុងជីវិតយើងដែលមានបំណងចង់បានលក្ខណៈសម្បត្តិដែល កោតខ្លាចព្រះដែលបង្ហាញឲ្យឃើញ នៅក្នុងជីវិតរបស់នាង អ័ប៊ីកែល ភាពសប្បុរសរួសរាយ វៃឆ្លាត គុណធម៌ អត់ធ្មត់ ប្រាជ្ញា ភាពឆាប់ដឹងសង្កេត យល់ខាងឯវិញ្ញាណ និង ការបង្កើតសន្តិភាព ។ ចូរឲ្យយើងសូមការទាំងអស់នេះតាមរយៈពាក្យរបស់យ៉ាកុប " តែបើអ្នករាល់គ្នាណាខ្វះប្រាជ្ញាមានតែសូមដល់ព្រះដែលទ្រង់ប្រទានដល់មនុស្ស ទាំងអស់ដោយសទ្ធាឥតបន្ទោសផងនោះទ្រង់នឹងប្រទានឲ្យតែត្រូវឲ្យអ្នកនោះសូមដោយចិត្តជឿឥតសង្ស័យអ្វីសោះ"[២០]។

---

[១៩] *ម៉ាថាយ ៦:១៣*

[២០] *យ៉ាកុប ១:៥-៦*

HONEYCOMB 5/1 (October 2004): 130–32

# Fiction or Fact?



*Russell H. BOWERS, Jr.*

I recently read the best-selling novel *The Poisonwood Bible*. It imagines the story of an American missionary family in the Congo during its 1960 struggle for independence.

Endorsed as it is by Oprah's Book Club, *The Poisonwood Bible* predictably paints a pessimistic picture. The missionary husband and father, Nathan Price, is ignorant, bigoted, chauvinistic, proud, harsh, self-centered, insensitive, and irrelevant. The family isolates itself from the villagers, who in turn ignore the father's skewed and jingoistic "gospel." Price's wife and four daughters at first fear and then loathe the man.

Although critics wax rhapsodic about the beauty and incisiveness of the story, it is actually a threadbare litany of popular stereotypical misconceptions of what believing Christian people are like. Nothing novel in this novel. And not only is it not new, it is arguably not true. Barbara Kingsolver in her Author's Note thanks her parents "for being different in every way from the parents I created for the narrators of this tale." She is right—she created them. They are also "different in every way" from the flesh-and-blood missionary people I know.

An example? Not long ago I crossed the Mekong River with Jeff and Heather Williams and my wife Glenna to a poor village opposite Kompong Cham. We went to conduct tuberculosis screening among the children. The other three were doing the work; I just watched. Jeff and Heather had become alarmed over the extent of TB infection there, and were pushing to enroll its children in a government-sponsored treatment program. To qualify they first needed to have a health professional perform screening injections, so Glenna had come to help with that.

In the weeks preceding our visit, Heather had painstakingly surveyed the village's households, enrolling each child by name and age. Now we walked the winding ways from house to house. Jeff and two Cambodian associates kept records, Glenna injected serum, and Heather explained the process to skeptical children and then comforted them after their shots.

I cannot imagine a contrast greater than that between the fictional Price and the living Williams families. Jeff and Heather chatted with villagers about everyday concerns as they strolled from house to house. Heather modeled love and patience as she cradled each child, explained the test, and calmed their fears (well, the fears of most—two or three out of the one hundred twenty-seven we tested that afternoon remained terrified.). As I watched her talking heart-to-heart with naked boys and cuddling scabies-infested girls, I pictured the busy and important Jesus taking children into his arms and blessing them.

Sure, Jeff and Heather would like to introduce these people to Jesus. But last Sunday afternoon I don't remember hearing his name mentioned. Last Sunday was instead devoted to loving these people and providing essential health care for them that they could not get for themselves. No one forced the Williams to do that; they took it on themselves out of the kind of genuine concern that prompts practical deeds.

No one will write a *New York Times* bestseller and Oprah Book Club selection about Jeff and Heather Williams on a sunny Sunday afternoon near Kompong Cham. Too many readers prefer ill-informed and indignant poisonwood fiction.



*Heather Williams comforts a Cham girl who has just received an injection*

សំណុំឆឹកឃ្មុំ ៥/១ (តុលា ២០០៤): ១៣៣-៣៦



# រឿងប្រឌិត ឬ ហេតុការណ៍ពិត?

*បណ្ឌិត រ៉ាស់សែល បាវរ៉ើស៍*

ពេលថ្មីៗនេះ ខ្ញុំបានអានប្រលោមលោកដ៏ល្បីមួយអំពីគម្ពីរ ពយសិនវូត *" Poisonwood Bible"* ។ ដែលពិពណ៌នាពីរឿងគ្រួសារនៃបេសកកម្មរបស់អាមេរិចកាំងមួយនៅក្នុងប្រទេសកុងកូ ក្នុងកំលុងពេលឆ្នាំ ១៩៦០ ដែលមានបញ្ហាខាងឯករាជ្យភាព។

យោងតាមក្លិបនៃសៀវភៅអូប្រាព្រះគម្ពីរពយសិនវូត បានផាត់រូបជាមុននូវរូបភាពទុទិដ្ឋិនិយម ។ បេសកជនដែលជាប្ដី និងជាឪពុកឈ្មោះណាថាន់ប្រៃ គឺជាអ្នកដែលអវិជ្ជាមានចិត្តចង្អៀតចង្អល់ស្នេហាជាតិហួសអំនួត ក្លាហាន គិតតែប្រយោជន៍ផ្ទាល់ខ្លួន ល្អិតល្អន់ មិនចុះសំរុងគ្នា ។ គ្រួសារនេះបានញែកខ្លួនគេដាច់ដោយឡែកចេញពីអ្នកភូមិ ក្រោយមកគេមិនអើពើចំពោះការមិនពេញចិត្ត ថែមទាំងស្អប់ដំណឹងល្អរបស់ឪពុកក្នុងគ្រួសារ

នោះ ។ ប្រពន្ធរបស់ប្រែ និង កូនស្រីទាំងបួននាក់ កាលពីមុនកោតខ្លាចតែក្រោយមកក៏ស្អប់ខ្ពើមឪពុករបស់ខ្លួន។

ទោះបីការសរសេរមានភាពរិះគន់ពីសំរស់ និងភាពច្បាស់លាស់នៃរឿងនេះក៏ដោយ តាមការពិតទៅវាឆ្លុះបញ្ចាំងអោយឃើញពីប្រភេទនៃការយល់ខុសរបស់គ្រិស្ទានមួយចំនួន ។ គ្មានអ្វីថ្មីហើយប្លែកជាងនៅក្នុងប្រលោមលោកនេះទេ ។ ហើយក៏មិនមែនមិនគ្រាន់តែថ្មីតែប៉ុណ្ណោះទេគឺវាមិនពិតទៀតផង ។ នៅក្នុងការសរសេររបស់យីងស៊ុលវ៉របាបារ៉ា នាងអរគុណាឪពុកម្តាយរបស់នាង "មានភាពខុសប្លែកគ្នាគ្រប់ផ្លូវទាំងអស់ចេញពី ឪពុកម្តាយដែលខ្ញុំបង្កើតឡើងសំរាប់អ្នកនិទានរឿងនេះ" ។ នាងគិតនោះត្រូវ ហើយនាងបង្កើតរឿងនេះរឿងនោះ ។ ពួកគេ "ពិតជាខុសគ្រប់ផ្លូវទាំងអស់" ប្លែកពីបេសកជន សាច់ឈាមដែលស្គាល់ខ្ញុំនោះ។

ខ្ញុំសូមលើកឧទាហរណ៍៖ មិនយូរប៉ុន្មាននៅពេលដែលខ្ញុំឆ្លងកាត់ទន្លេមេគង្គ ជាមួយចេហ្វ និង ហីតឌ័រ វៀលលាម និង ប្រពន្ធរបស់ខ្ញុំ ក្លេនណា ធ្វើដំណើរទៅភូមិដ៏ក្រីក្រមួយទល់មុខទីរួមខេត្តកំពង់ចាម ។ យើងទៅធ្វើការសង្កេតអំពីជំងឺរបេងក្នុងចំណោមក្មេងៗ ។ បីនាក់ទៀតកំពុងធ្វើការចំណែកខ្ញុំគ្រាន់តែមើលពួកគេ ។ ចេហ្វ និង ហីតធើរ ពិតជាមានការយកចិត្តទុកដាក់ចំពោះការកើតជំងឺ របេងនៅទីនោះ ហើយព្យាយាមបញ្ចូលក្មេងៗទាំងអស់នោះទៅក្នុងកម្មវិធីជំនួយព្យាបាលរបស់រាជរដ្ឋាភិបាល ។ ដើម្បីអោយគេអាចទទួលនូវការនេះបានលុះត្រាតែធ្វើការស្រាវជ្រាវដែលមានអ្នកជំនាញខាងសុខភាពដើម្បីចាក់ថ្នាំបង្ការ ដូច្នេះ ក្លេនណា ក៏ទៅជួយនៅក្នុងការងារនោះ។

ប៉ុន្មានសប្តាហ៍ក្រោយពីយើងទៅទីនោះ ហីតឌ័រ ពិតជាធ្វើការស្រាវជ្រាវយ៉ាងលំបាកដល់គ្រួសារនៅក្នុងភូមិនោះដោយកត់ឈ្មោះ និង អាយុនៃក្មេងនីមួយៗ ។ ឥលូវយើងដើរកាច់ចុះកាច់ឡើងពីផ្ទះមួយទៅផ្ទះមួយតាមផ្លូវក្ខិក្ខក់។ ចេហ្វ និង សហការីជនជាតិខ្មែរពីរនាក់ទៀតជួយកត់ត្រាក្នុងបញ្ជី ចំណែក

ក្លែនណា ជាអ្នកចាក់ថ្នាំ ហើយ ហ៊ីតឌ័រ ពន្យល់ក្មេងៗដែលមិនយល់ព្រមអោយចាក់ថ្នាំយល់ បន្ទាប់មកលើកទឹកចិត្តពួកគេក្រោយពីបានចាក់ថ្នាំរួច ។

ខ្ញុំមិនអាចធ្វើការស្រមៃបានពីភាពផ្ទុយគ្នាដ៏អស្ចារ្យរវាងរឿងប្រឌិតរបស់លោកប្រៃ និង ការរស់នៅពិតរបស់គ្រួសារលោកវៀលលាម ។ ចេហ្វ និង ហ៊ីតឌ័រ ជជែកជាមួយអ្នកភូមិអំពីការខ្វល់ខ្វាយប្រចាំថ្ងៃ នៅពេលដែលពួកគេធ្វើដំណើរពីផ្ទះមួយទៅផ្ទះមួយទៀត ។ ហ៊ីតឌ័រ ជាគំរូពីសេចក្តីស្រឡាញ់ និង ការអត់ធ្មត់ក្នុងខណៈពេលដែលគាត់ជួយក្មេងម្នាក់ៗពន្យល់ពីការចាក់ថ្នាំធ្វើតេស្តនោះ ហើយបានលួងកុំឲ្យភ័យខ្លាច ( ការភ័យខ្លាចបំផុតគឺ ក្នុងក្មេង ២-៣ នាក់ ក្នុងចំណោម ១២៧ ដែលយើងចាក់ថ្នាំធ្វើតេស្តនៅពេលរសៀលនោះ គឺនៅភ័យខ្លាចនៅឡើយ )។ នៅពេលដែលខ្ញុំសំលឹងទៅលើគាត់ដែលធ្វើការដោយចេញពីចិត្តស្រឡាញ់ជាមួយក្មេងដែលគ្មានខោអាវ និង ក្មេងស្រីៗដែលកើតរមាស់ត្របុលចូលជិតគាត់ធ្វើអោយខ្ញុំនឹកឃើញពីរូបភាពព្រះយេស៊ូដែលកំពុងរវល់ហើយយកចិត្តទុកដាក់ចំពោះកុមារៗព្រមទាំងលើកក្មេងមកពរ ហើយប្រទានព្រះពរដល់ពួកគេ។

ពិតប្រាកដហើយចេហ្វ និង ហ៊ីតឌ័រ ចង់ណែនាំមនុស្សទាំងអស់នេះឲ្យស្គាល់ព្រះយេស៊ូ ។ ប៉ុន្តែកាលពីរសៀលថ្ងៃអាទិត្យមុនខ្ញុំមិនបានឮគេនិយាយពីឈ្មោះរបស់គាត់ទេ ។ កាលពីថ្ងៃអាទិត្យមុនបែរជាឮពីការលះបង់ផ្តល់សេចក្តីស្រឡាញ់ដល់មនុស្សទាំងនេះហើយផ្តល់នូវការថែទាំផ្នែកខាងសុខភាពសំរាប់ពួកគេដែលពួកគេមិនទទួលបានដោយខ្លួនឯង ។ គ្មាននរណាម្នាក់បង្ខំអោយវៀលលាម ធ្វើយ៉ាងដូច្នេះទេ គឺពួកគាត់ធ្វើដោយខ្លួនគាត់ផ្ទាល់ដែលចេញពីការយកចិត្តទុកដាក់ដ៏ពិតប្រាកដដែលធ្វើឲ្យមានការប្រព្រឹត្តិជាក់ស្តែងសម្តែងពីសេចក្តីស្រឡាញ់។

គ្មាននរណាម្នាក់សរសេរពីសកម្មភាពនៅក្នុងទស្សនាវដ្តី *New York Times* ដែលលក់ដាច់បំផុត និង *Oprah Book Club* អំពីចេហ្វ និង ហ៊ីតឌ័រ

វៀលលាមទេនៅរសៀលថ្ងៃអាទិត្យក្រោមកំដៅថ្ងៃជិតទីរួមខេត្តកំពង់ចាម ។ មានអ្នកអានជាច្រើនចូលចិត្តដំណឹងដែលមិនច្បាស់លាស់ និង រឿងដែលប្រឌិតរបស់ ពយសិនវូត *Poisonwood* ។



*ហីតឌ័រ វៀលលាម នាងកំពុងលួងលោមក្មេងស្រីជនជាតិចាមម្នាក់ ដែលនាងទើបតែបានចាក់ថ្នាំរួច*

HONEYCOMB 5/1 (October 2004): 137–47



*Brian MAHER*

# Meet Molly Yos



*Molly YOS*

Molly Yos was born in Prey Veng province in 1960. She was the ninth of twelve children, only two of whom were boys. Her father, an official in the Ministry of Agriculture, supervised three provinces.

The family relocated to Phnom Penh in 1967 upon his promotion to Supervisor of Provincial Agriculture in Cambodia. Molly enrolled in Phnom Penh schools where she made friends with a girl named Young Setha—whom they called "Eang"—from Arey Ksach, the village directly across the river from the Royal Palace. Eang and Molly, both young teenagers in 1973, heard about a free English class. Phnom Penh during the sixties and early seventies was the hub of Southeast Asia and in touch with the pulse of both the region and the world. Molly and Eang did not want to be Cambodian teenagers who would

be referred to as "frogs in wells" or *boun cheroong* (square), so they were very interested in studying English. The classes were offered at the OMF Youth Center near Olympic Stadium. Molly and Eang found the place and enrolled to study English in their spare time. From the posted schedule they could choose their study topic from teachers Don Cormack, Alice Compain, Ruth Patterson, Rose Ellen Chancey, Andrew Way and Andrew Butler. Mr. Triev Sary was the Cambodian in charge. Both Eang and Molly first studied English from the gospels with Ruth Patterson. Then, when Rose Ellen Chancey came later, they studied English from the book of Genesis. They both bought English and Khmer Bibles to ensure they understood clearly.

Meanwhile, while Molly was studying her English, Molly's older brother Antipo had come to faith in Christ—the only Christian in the family. Molly was not much interested at the time, but sure took notice when her uncle beat him up after he preached the gospel to the family. As Molly was learning English from the Bible, Antipo was leading the youth group in the Bethany church.

Molly found the book of Genesis interesting and relevant because it answered many life questions about which she had wondered since childhood. The Buddhist religion posits neither a creation epic nor a creator God. Molly found the concept of a God who created her and knew her before she was born very comforting. As Molly studied Genesis, she gradually began to believe in this creator God and his son Jesus, and sometime in early 1974 gave her life to Christ. She began to attend Bethany church, led by Chhirc Taing (an officer in the army of Lon Nol's Republic and the older brother of Rev. Taing Vek Houng of Campus Crusade) and Mien Tien Voan (at that time Country Director of World Vision). Both Chhirc and his cousin Voan were later most likely martyred.[1]

Molly continued her study of English and the Khmer Bible at the Youth Center with Triev Sary on weekdays, and faithfully attended Bethany church on Sundays. During 1974, Molly began to help out at

---

[1]Helen Penfold mentions in *Remember Cambodia* that witnesses saw them clubbed to death by men clad in black shortly after the Khmer Rouge invaded in the city of Neak Loung.

the Youth Center, organizing the place and learning how to be a Bible study cell group leader. On Sundays after church, Molly, Rose Ellen Chancey, and her friends from church went out to share the gospel and hand out gospel tracts in the Tumnop Tek area of Phnom Penh, on the southeast rim of the city. Molly remembers selling tracts and Christian literature at the Olympic stadium when Dr. Stan Mooneyham preached in a large crusade.

Molly brought her younger sisters Sokun and Sotheavy to church with her, but it wasn't so easy convincing her parents to let them tag along. The fact that Sokun and Sotheary had become sponsor children of World Vision helped ease the concerns of her Buddhist parents who knew World Vision was a Christian organization. Through Molly's bringing them to church, both Sokun and Sotheavy became Christians and learned to work with the children in the church. Their parents even began to transport them back and forth from church activities. Molly's younger sister Sokun grew up to become a schoolteacher in the eighties, and worked for FEBC radio in the nineties. She currently works for World Vision Cambodia as a community development worker and has a great Christian witness.

In late 1974, Antipo's sharing his faith with Molly's two older sisters, Yos Im Sithan and Yos Sangkany, began to show some fruit. As Khmer Rouge artillery began to pound the city, these two older sisters gave their lives to Christ.

Treiv Sary, the director and manager of the Youth Center, realized that though he had evangelized and discipled these young people, other churches were using their gifts but not appreciating what he had done for them. In addition, churches like Bethany and Bethlehem were already overcrowded as more and more refugees daily arrived in Phnom Penh. So he decided to organize church services at the Youth Center on Sundays. Molly and Antipo stayed at Bethany and helped with smaller churches like Noah's Ark Church, an abandoned house boat stuck on the western bank of the Mekong. Noah's Ark was owned by a new believer from Bethlehem church, and Takmau Bible College students preached and ran the services there.

The Khmer Rouge were getting close, and there was fighting on the outskirts of the city. Eang, whose village was directly affected

by the fighting between Lon Nol's troops[2] and the Khmer Rouge, fled to the city and her family bought a house near the Olympic Market. Eang and Molly did everything together after that. Antipo, Sithan and Sangkany sold vegetables at Dam Tkeov market near the Tumnup Tek area. Sometime during 1974, Molly joined in a large baptism hosted by the Takmau Bible College. She remembers being encouraged to pray for the salvation of her parents by her youth pastor, Mr. Ngeth Samawn (Setha).

When Christmas rolled around, they celebrated the holiday with Rose Ellen and Alice at their home, together with other churches around Phnom Penh. All the expatriate missionaries in House #72 were packing their bags to leave, since it appeared to be only a matter of time before the Khmer Rouge would overrun the city. Molly's missionary friends warned her to not allow the Khmer Rouge to catch her with English books or a Khmer Bible.

On April 17, 1975, the Khmer Rouge entered Phnom Penh. They immediately began to execute Lon Nol's soldiers and others who had been a part of his government. Many soldiers buried their uniforms and joined the enforced mass exodus of the citizenry. Phnom Penh residents who were evacuated to the provinces came to be known as "new people." Many of these former city dwellers were to be systematically starved or worked to death. Others were simply taken away, never to be seen again.

In this mass exodus of over two million people, Molly and her family headed toward their home village in Prey Veng. They crossed the Mekong at Neak Loung, and made it to the town of Kompong Trabaek. Further into the countryside, they built a little house of bamboo and palm fronds. After arriving in Prey Veng province, most of the family contracted malaria. During this time of sickness, Molly's parents asked her to lead them to Christ. Molly and her mother were the sickest members of the family, and were taken to a rudimentary Khmer Rouge health clinic. The clinic had no medicine, and some patients were taken away to be killed.

---

[2]FANK—Forces Army National Kampuchea, the troops of Lon Nol's Republic.

After a few months Molly recovered, but her mother deteriorated. Those running the clinic were about to send Molly's mother home to die when she slipped into a three-day coma. In her coma she saw hairy demons chasing her, and soon became exhausted trying to flee from them. Two women came alongside her, each grabbing an arm, lifting it up, and supporting her. They encouraged her to keep going. In the distance loomed a white church. The two women took her past the white church and told her that it was a religious temple. She saw another church, this one was blood red and situated on the far side of a big ocean. The demons continued to chase her. They swam, but she was able to walk across on the water. As she arrived on the shore and set her foot on the steps leading into the church, the demons caught up to her. At that point, she yelled out, "Jesus, help me!" She saw Jesus coming out of the church saying; "I am Jesus Christ and this is Judgment Day." Upon hearing this, the demons fled. Molly's mother—in the real world—began moving her toe—a sign that she was still alive.

Soon after she returned from the clinic in good health. The family began to secretly read the Bible, but soon the situation became more repressive and they buried the Bible for fear of death from the Khmer Rouge. Even so, Molly's mother's faith began to blossom. But tests also came: Sotheary, the youngest in the family, suffered without medical care from dengue fever for seven days, and then died.

Molly was forced to plant rice and build paddy dikes in return for one bowl of watery gruel with a few rice kernels in the bottom. Seeing a dog run by made her mouth water as she thought about roasted dog meat. Because of lack of food and intense labor, Molly became ill. She had constant diarrhea, and quickly became dehydrated and malnourished. The authorities sent her to rest at another rudimentary clinic.

The Khmer Rouge were getting ready to conduct a mass marriage in Molly's village. Her mother insisted that Molly return from clinic and take part in this ceremony, thinking that if Molly married a villager, she might end up living close by. Molly was not thrilled with this idea at first, but eventually went along with her mother's wishes

and married Pot Sopharong in a group marriage ceremony in 1978. Her sister Yos Im Sithan was married in the same ceremony. .

. Ten days later, the Khmer Rouge forced the married couples to relocate to Pursat province in northwest Cambodia. Her mother, father, and sister decided to go too, and walked west all the way to Neak Luong. From there they were shipped north by truck to Phnom Penh, which was devoid of people. From Phnom Penh they took the train north to Pursat. During those difficult times under the Khmer Rouge, Molly's husband shared what food he had with her, and he carried her things when they were forced to move. She had a bad infection in her arm, and she is convinced that because of his help she remained alive and was able to survive the arduous journey

Antipo had been missing since they left Phnom Penh, as he was visiting his girlfriend when the Khmer Rouge entered the city. He had been relocated to Battambang, Cambodia's second largest urban center in the northwest, close to the border of Thailand. Molly remembers him recounting that three times the Khmer Rouge rounded him up for execution, but all three times the trucks were so filled that not even one more emaciated person could fit on the truck. After his third reprieve, Antipo fled to Thailand and joined the former Prime Minister of the sixties, Son Sanne, and the KPNLF (Free Khmer) to fight against the Khmer Rouge. He was the accountant for the KPNLF, until accused of pilfering funds and sent to the front where he was badly shot. He went to a Thai hospital to recover, then lived with a Thai family until he recuperated.

1978 was an extremely difficult year for Cambodians in terms of food security, as the Khmer Rouge exported a large percentage of rice to China and stored the rest in their mountain hideouts. Devastating floods also hit Cambodia's rice bowl that year, wiping out any rice that poor starving Cambodians might depend on.

On Christmas Day, 1978, Vietnamese forces entered Cambodia after the Khmer Rouge relentlessly attacked and massacred Vietnamese citizens living inside the Cambodian-Vietnamese border, especially in the Kampuchea Krom and Mekong Delta area. On January 7, 1979, Vietnamese troops victoriously entered Phnom Penh. From there they pushed the Khmer Rouge leadership into the

mountainous northwest along the Thai border, where they were safe in their Thai-protected border enclaves.

Vietnamese troops allowed Molly and her family to leave Pursat, but did not permit them to return to Phnom Penh. Instead they went to Prey Veng. They fortunately were able to go back to the family plot in their home village of the sixties, rather than the village where they lived during the Pol Pot regime. It was rice harvest time, but the fleeing, wounded, black-clad Khmer Rouge had torched the rice fields, poisoned wells, and destroyed roads and houses. Molly's family had little food, so were forced to beg from their neighbors. They worked out an arrangement under which Molly and her family worked long hours plowing and planting in the neighbor's rice fields, exchanging labor for rice to eat. For that whole year, they had little means for procuring food of any type. Six hundred thousand people died of starvation during the first year of the Vietnamese occupation. Under the Vietnamese K-5 program, any Cambodians suspected of not supporting the regime were sent to clear jungle and fortify areas against the DK[3] in mountainous regions of Battambang.

The new government—the Peoples' Republic of Kampuchea, led by Heng Samrin, Chea Sim, and Hun Sen (all having ties with the Vietnamese)—recalled Molly's father to his government agricultural position and to further studies. At the end of one year on the Prey Veng homestead they moved back to Phnom Penh, and Molly went to work for the Ministry of Agriculture. Her husband also went to work there, and made a lot of new friends who had a bad influence on him. He was soon squandering what little salary he earned on drinking and gambling. When their first child was born in 1981, he no longer took much interest in Molly or helping her raise the family. Molly tried her best to get him to change his ways but she could not, and resigned herself to care for her child without his help, depending on her mother and sisters for food and money to help pay the bills.

Sometime in the very early eighties Molly met up again with Eang. Eang was secretly worshipping at the underground Takmau church and invited Molly to join them, but Molly's father said "No"

---

[3]DK: Democratic Kampuchea, Khmer Krahom, or Khmer Rouge.

because it was too dangerous. Molly had enjoyed little conscious spiritual activity since 1975. But in 1988 her father began to succumb to the effects of high blood pressure, so Molly went to find Eang. Eang brought Molly to her pastor, Seing Ang, who prayed over Molly's father and anointed him with oil. He died months after that and went to be with the Lord.

Since the whole family wanted to bury their father according to Christian tradition rather than cremating him as in the Buddhist tradition, they called Pastor Seing Ang back to lead the funeral. That was in July of 1988. They didn't even bother to get permission from the government but went ahead with the funeral. There was a huge turnout. All the government friends of her father came, as well as friends of Molly, Sithan, and the other children. The underground church came out at this funeral for the first time. They all sang and worshipped God. Many pre-1975 Christians, many of whom came to Christ at the Stan Mooneyham Crusades, came out for the funeral. Attending were Pastor Im Chhorn, Pastor Muth Bunthy, Miss Yorng Setha, Mrs. Ngeth Sambo, Miss Srey Heim, and Heim's mother, as well as Molly and her family. Molly remembers the funeral procession being miles long.

An unexpected problem arose: "Where do we bury him?" A Vietnamese-Cambodian Christian, Paul Ba, helped contact the Catholic church, which allowed Molly's father to be buried in a Catholic Vietnamese cemetery in Kean Svay District, just over the river toward the southeast, off of Route One.

Through the funeral, Molly became aware of other believers who were meeting in secret locations around town. In 1989 it was estimated that there were no more than two hundred Christians in Phnom Penh.

Molly recounts, "One day not too long after the first public baptism in the Kantoeut River, west of Phnom Penh (done surreptitiously with about fifty believers), I saw my sister Sithan hold a paper in her hand. She was asking other key Christians to sign it. She had about ten signatures on what apparently was a petition of some sort. My sister was working at that time in the Ministry of Education, and was respected by her colleagues. She submitted that petition to an important man in the government who sent it through the system; it eventually

arrived on the desk of the Minister of Cults and Religion." Fortunately, Sithan had a longtime friend who turned out to be the wife of this minister and was able to arrange an audience with him. Molly and her sister met with the man and implored him: "Under this regime we have no right to worship in the tradition of our faith, no place to bury our dead according to our tradition, no rights at all. This isn't right. What can you do for us?"

The three Yos sisters, Molly, Sithan, and Sokun, bicycled to the minister's house every afternoon for more than three months. He wanted to learn more about Christianity in order to make an informed presentation of their case to the government. Each afternoon they sang hymns, worshipped, taught from the Bible, and listened to worship songs on cassette. The minister even borrowed cassettes to listen in his car going back and forth from work. He asked many questions, which they answered.

During this time, Molly had dreamed that she and her family were running around the nearby Olympic Stadium, shouting joyfully to everyone in hearing distance: "Bravo Jesus, Bravo!" She felt God was telling her that they would be given a decisive victory that would break Satan's strong grip over her beloved land.

Meanwhile, Molly's father's funeral had spurred local Christian leaders to form a provisional church committee comprised of ten members (four of them women), and headed by Pastor Siang.[4] Molly's sister Yos Im Sithan was on that council. It was June of 1989, and Christians were hoping for changes in the new state constitution showing more tolerance toward Christianity. That June, the Council of Ministers permitted Christians to express their faith in worship, but did not permit evangelism.

While Yos Sithan, Molly, Sokun, and others continued to meet with the minister, the Cambodian church was invited to attend the Lausanne II World Conference in the Philippines. They could not attend, but did send a report about their situation. This mobilized those

---

[4]Don Cormack, *Killing Fields Living Fields: An Unfinished Portrait of the Cambodian Church—the Church that Would Not Die* (Crowborough, East Sussex: OMF, 1997), 391.

attending to pray fervently for official freedom of religion for the church in Cambodia.

On the last day the sisters met with the minister, he asked them if Christians got involved in politics. Molly explained from Romans 13 that God ordains leaders of a country and Christians are encouraged to submit to and pray for their leaders. She reassured him that Christians in Cambodia only wanted freedom to worship, not stir up unrest in an already unstable country. The next day he called them back, quite shaken up about something one of his superiors might have said. He asked them again to explain to him very clearly about the political part. Molly explained once again that Christianity would not intentionally cause problems for the government; they only wanted freedom to follow their religious tradition legally. The minister went back to make his second appeal to the government. The very next Sunday, April 7, 1990, ten months after Lausanne, during a worship service in Molly's house, the Cambodian Government formally announced its recognition of the Christian Church. The next week, in the presence of government representatives, 1,500 Christians—Catholic and Protestant, Cambodian and Vietnamese—celebrated their new freedom together in Phnom Penh's largest auditorium.

The government remained wary of Christians; Molly and Sithan were among those followed by spies. Since Sithan was the primary mover and shaker in obtaining freedom for Christianity, the government wanted her to keep a tight lid on things to ensure that the church did not abuse its newfound freedom. Tight restraint was impossible after Christianity began to grow rapidly and missionaries and denominations arrived from all over the world. It was a Texas-based evangelist Mike Evans who almost lost freedom for Christianity in November 1994 in his ill-conceived Olympic Stadium crusade. Many missionaries in Cambodia had advised him against coming, but he came anyway because he thought God told him to. The crusade was a disaster. The advertising promised that everyone who attended would be healed, and that did not happen. The church experienced blatant persecution for the first time since it had gained freedom.

Yos Molly, Yos Im Sithan, Yos Sokun, Young Setha (Eang) and Pastor Seang Ang played critical roles in obtaining freedom for

Christianity under Hun Sen's Cambodia. That freedom has been enjoyed by the church, Christian organizations, Christian NGOs, missionaries, and the Cambodian people to this day.

In October 1991, as Molly was applying to World Vision Cambodia, her husband continued to gamble. Molly's application was accepted, so she bore the burden of her husband's gambling and supported her three children with her own salary. On occasion, her husband would attempt to change, but such changes were short lived. He sometimes didn't come home at night, and even gambled away a motorbike or two that Molly had bought with her earnings. At World Vision she began as a receptionist and inventory clerk, but was soon promoted to assist in the Operations Support Unit, then Staff Development and Spiritual Nurture, two different entities under Human Resources. Under the Spiritual Nurture Department she helped create the World Vision Cambodia Holistic Witness Policy Paper, organized pastor fellowships, translated World Vision's core values into Khmer, led staff Bible studies, coordinated Friday chapel and Tuesday Bible forum, arranged retreats, and was responsible for the orientation of new staff. In February 1998 she was transferred to the Kompong Thom Operation. Kompong Thom is a three-hour drive north of Phnom Penh. In Kompong Thom, Molly led the Spiritual Nurture and Leadership and Staff Development programs, really two full-time jobs. One year later Molly was promoted to Operations Manager. In February 2002, for the sake of her family, she has returned to Phnom Penh to take a less demanding position as an Area Development Program capacity builder. Molly's husband did recently leave her, and she now continues to look after three children, a boy and two girls.

សំណុំធីកឃ្មុំ ៥/១ (តុលា ២០០៤): ១៤៨-៦៤



# ជួបជាមួយលោកស្រី យស់ មូល្លី

*លោក ប្រាយអិន ម៉ាហ៊ើ*



*លោកស្រី យស់ មូល្លី*

យស់ មូល្លី កើតក្នុងឆ្នាំ ១៩៦០ នៅខេត្តព្រៃវែង ។ អ្នកស្រីជាកូន ទី៩ នៅក្នុងគ្រួសារដែលមានកូន១២នាក់ ហើយមានតែកូនប្រុស ២នាក់ ទេ នៅក្នុងគ្រួសារនោះ ។ ឪពុករបស់អ្នកស្រីជាមន្ត្រីផ្នែកក្រសួងកសិកម្ម ដែលទទួលខុសត្រូវមើលបីខេត្ត ។

គ្រួសារគាត់បានមករស់នៅទីក្រុងភ្នំពេញនៅក្នុងឆ្នាំ ១៩៦៧ គឺនៅពេលដែលឪពុកគាត់ត្រូវបានគេចាត់តាំងឲ្យធ្វើជាទីប្រឹក្សាកសិកម្មថ្នាក់ខេត្តនៅក្នុងប្រទេសកម្ពុជា ។ មូល្លី បានចូលរៀនសាលានៅភ្នំពេញ នៅពេលនោះឯងដែលអ្នកស្រីបានបង្កើតមិត្តភាពជាមួយនារីម្នាក់ឈ្មោះ យ៉ង់ ស៊ីថា ដែលគេតែងតែហៅថា " អៀង " មកពីអរិយក្សត្រគឺជាភូមិមួយនៅត្រើយម្ខាងទន្លេទល់មុខព្រះបរមរាជវាំង ។ អៀង និង មូល្លី គឺនៅជា យុវជននៅឡើយ នៅក្នុងឆ្នាំ ១៩៧៣

ពេលមួយពួកគេបានឮដំណឹងពីការបង្រៀនអង់គ្លេសដោយឥតយកលុយ ។ កាលពីកំលុងឆ្នាំ១៩៦០និងដើមឆ្នាំ ១៩៧០ ទីក្រុងភ្នំពេញ គឺជាចំណុចកណ្តាលនៃអាស៊ីអាគ្នេយ៍ដែលមានសន្ទុះទាំងក្នុងតំបន់ និងក្នុងពិភពលោក ។ មូលី និង អៀង មិនចង់ក្លាយជាយុវវ័យកម្ពុជាដែលគេតែងហៅថា " កង្កែបក្នុង អណ្តូងទេ " ឬ មនុស្សបួនជ្រុងនោះទេដូច្នេះពួកគេទាំងពីរមានការចាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការរៀនភាសាអង់គ្លេស ។ ផ្លាក់ទាំងអស់បើកឡើងនៅឯមជ្ឈមណ្ឌលយុវជន OMF ជិតស្តាតអូឡាំពិច ។ មូលី និង អៀង បានរកឃើញ ហើយចុះឈ្មោះចូលរៀនអង់គ្លេសក្នុងម៉ោងទំនេររបស់ពួកគេ ។ តាមរយៈកាលវិភាគដែលបានបិទ ពួកគេអាចជ្រើសរើសមុខវិជ្ជាដែលត្រូវរៀនជាមួយលោកគ្រូ ដន ខូម៉ាក អាលីសកុំប៉ាំង រូថប៉ាត័រសាន់ រូសអេឡែនឆែនស៊ុី អែនទ្រូវ៉េ និង អែនទ្រូបាត់ល័រ ។ លោក ទ្រាវសានី គឺអ្នកទទួលខុសត្រូវជនជាតិខ្មែរ ។ អៀង និង មូលី ទាំងពីរនាក់រៀនភាសាអង់គ្លេសតាមដំណឹងល្អទាំងបួនជាមួយរូថបាត័រសាន់ ។ បន្ទាប់មក រូស អេឡែនឆែនស៊ុីបានមកតាមក្រោយ ពួកគេសិក្សាភាសាអង់គ្លេសតាមសៀវភៅលោកុប្បត្តិ ។ ពួកគេទិញព្រះគម្ពីរខ្មែរ និង ភាសាអង់គ្លេសមកដើម្បីបញ្ជាក់ឲ្យដឹងថាពួកគេពិតជាយល់បានច្បាស់ល្អ ។

ក្នុងខណៈពេលដែលអ្នកស្រីមូលី កំពុងរៀនភាសាអង់គ្លេស បងប្រុសរបស់អ្នកស្រី មូលី ឈ្មោះ អាន់ទីប៉ូ បានជឿលើព្រះយេស៊ូគ្រីស្ទ គឺមានតែគាត់តែម្នាក់ឯងគត់ដែលជាគ្រីស្ទាន នៅក្នុងគ្រួសាររបស់គាត់ ។ អ្នកស្រីមូលីមិនទាន់មានការចាប់អារម្មណ៍ចំពោះរឿងព្រះនៅពេលនោះទេ ប៉ុន្តែអ្នកស្រីមានការកត់សំគាល់នៅពេលដែលឪពុកធំរបស់គាត់បានវាយបងប្រុសគាត់ គឺនៅពេលដែលគាត់ផ្សាយដំណឹងល្អដល់គ្រួសារគាត់ ។ នៅពេលដែលអ្នកស្រី មូលី កំពុងរៀនភាសាអង់គ្លេសពីព្រះគម្ពីរ ចំណែកលោក អាន់ទីប៉ូពេលនោះ គឺជាអ្នកដឹកនាំយុវជននៅក្រុមជំនុំបេថានី ។

ម៉ូលីយល់ឃើញថាកណ្ឌគម្ពីរលោកុប្បត្តិមានការចាប់អារម្មណ៍ ហើយសមទៅនឹងហេតុការណ៍ ពីព្រោះវាបានឆ្លើយនូវសំណួរជាច្រើន អំពីជីវិតដែលអ្នកស្រីធ្លាប់ឆ្ងល់តាំងពីអ្នកស្រីនៅក្មេង ។ សាសនាព្រះពុទ្ធ មិនបាននិយាយអំពីការបង្កបង្កើតពិភពលោក ឬ ព្រះអាទិករឡើយ ។ មូលី្ល បានរកឃើញពីការយល់ដឹងអំពីព្រះដែលបង្កើតអ្នកស្រីហើយស្គាល់ អ្នកស្រីតាំងពីអ្នកស្រីមិនទាន់កើត ។ នៅពេលដែលអ្នកស្រីរៀននៅក្នុង ព្រះគម្ពីរលោកុប្បត្តិ អ្នកស្រី ចាប់ផ្តើមជឿទៅលើព្រះដែលបង្កបង្កើត និង ព្រះរាជបុត្រាព្រះយេស៊ូគ្រីស្ទ ហើយ ប្រហែលជានៅក្នុងឆ្នាំ ១៩៧៤ អ្នកស្រី បានថ្វាយជីវិតនាងទៅព្រះគ្រីស្ទ ។ អ្នកស្រីបានចាប់ផ្តើមចូលរួមថ្វាយបង្គំ នៅព្រះវិហារបេថានី ដែលដឹកនាំដោយ លោកគ្រូ តាំង ឈៀក ( ដែលជា មន្ត្រីនៅក្នុងនាយទាហានសាធារណរដ្ឋ លន់ ណុល ហើយជាបងប្រុស លោកគ្រូ តាំងវេកហួង នៃអង្គការនិស្សិត និង ប្រជាជនថ្វាយព្រះគ្រីស្ទ ) និង លោក មៀន ធានវ៉ន ( ដែលនៅពេលនោះជានាយកប្រចាំប្រទេសរបស់អង្គការ ទស្សនៈពិភពលោក ) ។ ទាំងលោកគ្រូ ឈៀក និង លោក វ៉ន ក្រោយមកត្រូវ បាន សំលាប់ ដោយព្រោះតែជំនឿរបស់ខ្លួន [១] ។

អ្នកស្រីមូលី្ល នៅបន្តរៀនភាសាអង់គ្លេស និង ព្រះគម្ពីរជាភាសាខ្មែរ នៅឯមជ្ឈមណ្ឌលយុវជន ជាមួយ ទ្រាវ សារី ក្នុងចុងសប្តាហ៍ ហើយចូលរួម ថ្វាយបង្គំយ៉ាងស្មោះត្រង់ នៅថ្ងៃអាទិត្យក្នុងព្រះវិហារបេថានី ។ នៅក្នុងឆ្នាំ ១៩៧៤ អ្នកស្រីមូលី្ល បានចាប់ផ្តើមជួយការងារនៅក្នុងមជ្ឈមណ្ឌលយុវជនខាងផ្នែក រៀបចំកន្លែង និងជួយក្នុងការរៀនឲ្យទៅជាអ្នកដឹកនាំបង្រៀនគម្ពីរក្នុងក្រុមតូច ។ បន្ទាប់ពីទៅព្រះវិហារនៅថ្ងៃអាទិត្យរួចមក អ្នកស្រីមូលី្ល រ៉ូស អេឡៃនឆេនស៊ី

---

*[១] ហេឡិន ផិនហួល បានលើកឡើងមកនិយាយនៅក្នុងសៀវភៅ ឈ្មោះ Remember Cambodia ដែលបានឃើញពួកគេត្រូវពួកទាហានខ្មែរ ក្រហមសម្លាប់ ពេលដែលពួកទាហានអាវខ្មៅទេះលុកលុយនៅក្នុងទី ក្រុងអ្នកលឿង ។*

និង មិត្តសម្លាញ់របស់គាត់ដែលនៅក្នុងក្រុមជំនុំជាមួយគ្នាបាននាំគ្នាចេញទៅផ្សាយដំណឹងល្អ និង ចែកខិត្តប័ណ្ណនៅក្នុងតំបន់ទំនប់ទឹកនៃទីក្រុងភ្នំពេញដែលនៅ ខាងភាគអាគ្នេយ៍នៃទីក្រុង ។ អ្នកស្រីមូលី នឹងចាំបានចំពោះការលក់ខិត្តប័ណ្ណនៅក្នុងពហុកីឡាដ្ឋានអូឡាំពិក នៅពេលដែលលោក បណ្ឌិត ស្ដែន ម៉ូនីហាំ អធិប្បាយក្នុងយុទ្ធនាការផ្សាយដំណឹងល្អយ៉ាងធំមួយនោះ ។

អ្នកស្រីមូលី បាននាំប្អូនស្រីរបស់គាត់ឈ្មោះសុគន្ធ និង សុធារី ទៅព្រះវិហារជាមួយគាត់ ប៉ុន្តែមិនមែនជាការងាយស្រួលទេក្នុងការដែលធ្វើឲ្យឪពុកម្ដាយរបស់គាត់យល់ ហើយព្រមអនុញ្ញាតឲ្យគាត់នាំគេទៅព្រះវិហារជាមួយគាត់នោះឡើយ ។ ហេតុការណ៍ដែលធ្វើឲ្យឪពុកម្ដាយរបស់គាត់ដែលជាអ្នកជឿព្រះពុទ្ធសាសនានោះ បានធូរស្រាលពីការព្រួយបារម្ភគឺនៅពេលដែល សុគន្ធ និងសុធារីបានទទួយការគាំទ្រពីកម្មវិធីជួយគាំទ្រកុមាររបស់អង្គការទស្សនៈពិភពលោក ទើបឪពុកម្ដាយរបស់គាត់បានស្គាល់ថាអង្គការទស្សនៈពិភពលោកជាអង្គការគ្រីស្ទាន ។ តាមរយៈការនាំចូលព្រះវិហាររាល់អាទិត្យ របស់អ្នកស្រីម៉ូលី ពេលនោះ សុគន្ធ និង សុធារីបានក្លាយជាអ្នកជឿព្រះយេស៊ូដែរ និងរៀនធ្វើការជាមួយកុមារនៅក្នុងព្រះវិហារ ។ ឪពុកម្ដាយក៏ចាប់ផ្ដើមជូនពួកគេទៅមកពីផ្ទះទៅព្រះវិហារបន្ទាប់ពីគេបញ្ចប់ការងារនៅព្រះវិហារ ។ សុគន្ធជាប្អូនស្រីរបស់អ្នកស្រីមូលីបានក្លាយជាគ្រូបង្រៀន នៅឆ្នាំ ១៩៨០ ហើយក្រោយមក សុគន្ធបានធ្វើការជាមួយវិទ្យុអេហ្វ អ៊ី ប៊ី ស៊ី នៅក្នុងឆ្នាំ១៩៩០ ។ ឥឡូវនេះ សុគន្ធ ធ្វើការជាមួយអង្គការទស្សនៈពិភពលោកកម្ពុជាក្នុងឋានៈជាបុគ្គលិកផ្នែកអភិវឌ្ឍន៍សហគមន៍ និងបានធ្វើទីបន្ទាល់ពីគ្រីស្ទបរិស័ទបាន យ៉ាងល្អប្រសើរ ។

នៅចុងឆ្នាំ ១៩៧៤ អាន់ទីប៉ូ បានផ្សាយដំណឹងពីព្រះគ្រីស្ទដល់ បងស្រីពីរនាក់ទៀតរបស់មូលី ឈ្មោះ យស់ ឯមស៊ីថាន និង យស់ សាំងកានីពេលនោះពួកចាប់ផ្ដើមបង្ហាញពីផលផ្លែដែលគេបានឮដំណឹងល្អ។ នៅពេល

ដែលពួកខ្មែរក្រហមបានផ្ដើមបាញ់ផ្លោងចូលមកក្នុងទីក្រុងបងស្រីទាំងពីរក៏សម្រេចចិត្តថ្វាយជីវិតរបស់គេទៅព្រះគ្រីស្ទ ។

ទ្រាវ សារី ដែលជានាយក និង ជាអ្នកចាត់ចែងការនៅក្នុងមជ្ឈមណ្ឌលយុវជនបានយល់ឃើញថាទោះបីជាគាត់ខំផ្សាយដំណឹងល្អ និង បង្ហាត់គេឲ្យទៅជា សិស្សយ៉ាងណាក៏ដោយ បែរជាក្រុមជំនុំដទៃទៅវិញទេ ដែលបានប្រើយុវជនទាំងអស់នោះហើយគេមិនដែលអរគុណចំពោះការដែលគាត់ខំបង្ហាត់បង្រៀនគេឡើយ ។ លើសពីនោះទៅទៀតនោះក្រុមជំនុំជាច្រើន ដូចជាក្រុមជំនុំ បេថានី និង ក្រុមជំនុំបេថ្លេហិមមានក្រុមជំនុំ កើនឡើងច្រើនកាន់តែច្រើនឡើងៗជារៀងរាល់ថ្ងៃដោយព្រោះមានជនភៀសខ្លួនកើនឡើងហូរចូលក្រុងភ្នំពេញជារៀងរាល់ថ្ងៃ ។ ដូច្នេះលោក ទ្រាវសារី បានសម្រេចចិត្តរៀបចំឲ្យមានការថ្វាយបង្គំព្រះនៅឯមជ្ឈមណ្ឌលយុវជន នៅថ្ងៃអាទិត្យ ។ មូល្លី និង អាន់ទីប៉ូបានស្នាក់នៅក្រុមជំនុំបេថានី ហើយជួយក្រុមជំនុំតូចៗដូចជាព្រះវិហារទូករបស់លោក ណូអេ ជាផ្ទះទូកដែលគឿងជាប់នៅច្រាំងខាងលិចនៃទន្លេមេគង្គ ។ ទូកលោក ណូអេ ជាកម្មសិទ្ធិរបស់អ្នកជឿថ្មីម្នាក់ចេញពីក្រុមជំនុំ បេថ្លេហិម ហើយសិស្សនៃមហាវិទ្យាល័យព្រះគម្ពីរតាខ្មៅដែលបានអធិប្បាយ និង បានដឹកនាំកម្មវិធីនៅទីនោះ ។

ខ្មែរក្រហមកាន់តែខិតមកជិត និង មានការបាញ់ប្រហារគ្នានៅតាមតំបន់ជាយក្រុង ។ អៀង ដែលភូមិរបស់គាត់បានទទួលរងនូវការបាញ់ប្រហារគ្នារវាងទាហានលន់ណុល[២] និង ទាហានខ្មែរក្រហម អៀង បានរត់ភៀសខ្លួនចូលទៅក្នុងទីក្រុងភ្នំពេញ ហើយគ្រួសារគាត់បានទិញផ្ទះមួយនៅជិតផ្សារអូឡាំពិច។ អៀង និង មូល្លី ធ្វើការគ្រប់យ៉ាងទាំងអស់ជាមួយគ្នាបន្ទាប់ពីនោះមក ។ អាន់ទីប៉ូ ស៊ីថាន និង សង្ហានី លក់បន្លែនៅផ្សារដើមថ្កូវម្ដុំទំនប់ទឹក ។ ពេលមួយ

---

*[២] កងទ័ពជាតិកម្ពុជា ដែលជាទាហានរដ្ឋាភិបាលសាធារណរដ្ឋ លន់ ណុល*

នៅក្នុងឆ្នាំ ១៩៧៤ មូល្លី បានចូលរួមក្នុងពិធីបុណ្យជ្រមុជទឹកដ៏ធំមួយដែលធ្វើឡើងដោយមហាវិទ្យាល័យព្រះគម្ពីរតាខ្មៅ ។ អ្នកស្រីបានចងចាំពីសេចក្ដីក្លាហានអធិស្ឋាន សំរាប់សេចក្ដីសង្គ្រោះដល់ឪពុកម្ដាយរបស់អ្នកស្រី ដោយគ្រូគង្វាលយុវជនម្នាក់ឈ្មោះលោក ង៉ែត សាម៉ន ហៅ ស៊ីថា។

ពេលដែលបុណ្យណូអែលចូលមកដល់ពួកគេបានអបអរសាទរថ្ងៃបុណ្យណូអែលនោះជាមួយ រូស អេវ៉្លេន និង អាលីស នៅឯផ្ទះរបស់ពួកគេជាមួយក្រុមជំនុំដទៃទៀតជុំវិញភ្នំពេញ ។ បេសកជនបរទេសទាំងអស់នៅផ្ទះលេខ៧២ កំពុងរៀបចំវ៉ាលីសរបស់ពួកគេដើម្បីចាកចេញពីព្រោះនេះជាឱកាសរបស់ពួកគេហើយមុនពេលដែលខ្មែរក្រហមចូលដល់ទីក្រុង ។ បេសកជនដែលជាមិត្តរបស់ម៉ូលីប្រាប់គាត់ថាកុំឲ្យខ្មែរក្រហមចាប់បានសៀវភៅអង់គ្លេសនិង ព្រះគម្ពីរខ្មែរនៅជាមួយគាត់ឲ្យសោះ ។

នៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ខ្មែរក្រហមបានចូលក្នុងទីក្រុងភ្នំពេញពួកគេចាប់ផ្ដើមសម្លាប់ទាហានលន់ណុលនិងអ្នកដទៃទៀត ដែលធ្វើការជាមួយរដ្ឋាភិបាល ។ មានទាហានជាច្រើនបានយកឯកសណ្ឋានរបស់ខ្លួនទៅកប់ ហើយបានចូលរួមការជម្លៀសខ្លួនយ៉ាងធំចេញពីទីក្រុង ។ អ្នកដែលរស់នៅទីក្រុងភ្នំពេញទាំងអស់ដែលជម្លៀសទៅតាមបណ្ដាខេត្តផ្សេងៗត្រូវបានហៅថា " ប្រជាជនថ្មី " ។ មានអ្នកទីក្រុង ជាច្រើនបានទទួលនូវការអត់ឃ្លាន និង ធ្វើការជាទម្ងន់រហូតដល់ស្លាប់ ។ អ្នកខ្លះក៏ត្រូវគេចាប់ខ្លួនយកទៅបាត់ហើយបាត់ខ្លួនជារៀងរហូត ។

ដំណើរភៀសខ្លួនដ៏ធំនេះដែលមានមនុស្សកកកុញជាង ២ លាន នាក់ មូល្លី និង គ្រួសាររបស់គាត់ធ្វើដំណើរឆ្ពោះទៅភូមិកំណើតរបស់ពួកគេនៅខេត្តព្រៃវែង ។ ពួកគេឆ្លងទន្លេមេគង្គតាមអ្នកឡើងហើយទៅដល់ភូមិមួយឈ្មោះកំពង់ត្របែក ។ នៅក្នុងភូមិនោះ ពួកគេបានសង់ខ្ទមមួយដែលធ្វើពីឫស្សីនិង ស្លឹកត្នោត ។ បន្ទាប់ពីបានមកដល់ខេត្តព្រៃវែងសមាជិកភាគច្រើននៅក្នុង

គ្រួសារកើតជំងឺគ្រុនចាញ់ ។ ក្នុងអំឡុងពេលដែលមានជំងឺយ៉ាងដូច្នេះ ឪពុកម្ដាយ មូលី្ល ក៏សូមឲ្យនាងនាំពួកគាត់ឲ្យស្គាល់ព្រះគ្រីស្ទដែរ ។ មូលី្ល និង ម្ដាយរបស់នាងមានជំងឺធ្ងន់ជាងគេ ហើយត្រូវបានគេនាំទៅអង្គការសុខភាព របស់ខ្មែរក្រហម ។ មណ្ឌលសុខភាពនោះគ្មានថ្នាំពេទ្យទេ ហើយអ្នកជំងឺខ្លះ ត្រូវបានយកចេញទៅសម្លាប់ចោល ។

បន្ទាប់ពីប៉ុន្មានខែក្រោយមកម៉ូលីបានជាពីជំងឺ ប៉ុន្ដែម្ដាយរបស់គាត់ កាន់តែយ៉ាប់យ៉ឺនឡើង ។ អ្នកដែលនៅមណ្ឌលសុខភាពទាំងអស់ចង់បញ្ជូន ម្ដាយរបស់គាត់ទៅស្លាប់នៅឯផ្ទះនៅពេលដែលគាត់សន្លប់បាត់ស្មារតីរហូតដល់ ៣ ថ្ងៃ ។ នៅក្នុងខណៈដែលគាត់សន្លប់ ៣ ថ្ងៃគាត់បានឃើញខ្មោចដែលមានសក់ យ៉ាងច្រើនកំពុងដេញគាត់ គាត់មានការអស់កំលាំងយ៉ាងខ្លាំងក្នុងការរត់គេច ខ្មោចទាំងនោះ ។ ស្រាប់តែមានស្ដ្រី ២ នាក់មកតាមគាត់ម្នាក់បានលើកដៃគាត់ ឡើងហើយជួយគាត់ ។ ស្ដ្រីនោះបានប្រាប់គាត់ឲ្យខំប្រឹងទៀត ។ នៅពីចំងាយ មានព្រះវិហារសមួយ ។ ស្រីទាំងពីរនាក់នាំគាត់ឆ្លងកាត់ព្រះវិហារសនោះហើយ ប្រាប់គាត់ថានោះគឺជាព្រះវិហាររបស់សាសនា ។ គាត់បានឃើញព្រះវិហារ មួយទៀតមួយនេះមានឈាមក្រហម ហើយនៅយ៉ាងឆ្ងាយឯនាយសមុទ្រ យ៉ាងធំ ។ ខ្មោចចេះតែបន្ដដេញចាប់គាត់ ។ ពួកវាហែលទឹកប៉ុន្ដែគាត់អាចដើរ លើទឹកបាន ។ ក្នុងខណៈពេលដែលគាត់បានមកដល់ច្រាំងហើយ បោះជំហាន គាត់ទៅព្រះវិហារហើយខ្មោចនោះបានចាប់គាត់បាន ។ នៅក្នុងពេលនោះស្រាប់ តែគាត់ស្រែកឡើងថា" ព្រះយេស៊ូជួយខ្ញុំផង" ។ គាត់ក៏ឃើញព្រះយេស៊ូនេះ គឺជាថ្ងៃជំនុំជំរះ ។ នៅពេលដែលឮយ៉ាងដូច្នេះខ្មោចក៏រត់គេចបាត់ទៅ ។ ម្ដាយរបស់មូលី្ល ក្រោយពីពេលនោះមកចាប់ផ្ដើមកំរើកមេជើងជាសញ្ញាឲ្យ ដឹងថាគាត់នៅមានជីវិតនៅឡើយ ។

មិនយូរប៉ុន្មានបន្ទាប់ពីគាត់វិលត្រឡប់មកពីមណ្ឌលសុខភាពរួចមក គាត់ក៏មានសុខភាពល្អ ។ ក្រុមគ្រួសារចាប់ផ្ដើមអានព្រះគម្ពីរដោយសំងាត់

ប៉ុន្តែក្រោយមកហេតុការណ៍កាន់តែធ្ងន់ធ្ងរទៅ ហើយពួកគេក៏កប់ព្រះគម្ពីរ ដោយព្រោះខ្លាចស្លាប់ដោយខ្មែរក្រហម ។ ទោះបីយ៉ាងដូច្នេះក៏ដោយក៏ជំនឿរបស់ម្តាយមូលី នៅតែលូតលាស់ល្អ ។ ប៉ុន្តែការល្បងលក៏មកដល់ គឺថាសុធារី ដែលជាកូនពៅនៅក្នុងគ្រួសាររងទុក្ខដោយគ្មានថ្នាំព្យាបាលដោយជំងឺគ្រុនឈាម អស់រយៈពេល ៧ ថ្ងៃ ហើយក៏បាត់បង់ជីវិតទៅ ។ មូលី ត្រូវបង្ខំដោយស្ទូងស្រូវ និង លើកភ្លឺស្រែដែលទទួលបានតែបបរាវតែមួយផ្តិលដែលមានអង្ករតែបន្តិចនៅបាតចាន ។ នៅពេលដែលឃើញសត្វឆ្កែរត់ធ្វើឲ្យនាងស្រក់ទឹកមាត់នឹកឃើញពីសាច់ឆ្កែអាំងដែលគួរឲ្យឆ្ងាញ់ ។ ពីព្រោះតែខ្វះអាហារ ហើយធ្វើការយ៉ាងធ្ងន់ធ្ងរ មូលី ក៏ធ្លាក់ខ្លួនឈឺ ។ គាត់មានជំងឺរាករហូត ហើយក៏មានការខ្សោះជាតិទឹកយ៉ាងឆាប់រហ័ស ហើយទទួលនូវការរងឈឺចាប់ដោយពុំបានទទួលអាហារគ្រប់គ្រាន់ ។ អង្គការបានបញ្ជូនគាត់ទៅសំរាកនៅឯមណ្ឌលសុខភាព ។

ខ្មែរក្រហមប្រុងប្រៀបធ្វើពិធីរៀបការយ៉ាងធំមួយនៅភូមិរបស់មូលី។ ម្តាយរបស់នាងទាមទារឲ្យមូលីវិលពីមន្ទីរពេទ្យ ហើយមកចូលរួមពិធីនេះដែរ ដោយគាត់គិតថាប្រសិនបើមូលី រៀបការជាមួយអ្នកភូមិនេះនោះម៉ូលីនឹងបានរស់នៅជិតគាត់ ។ ពីដំបូងមូលី អត់សប្បាយនឹងគំនិតនេះទេ ប៉ុន្តែក្រោយមកក៏យល់ព្រមទៅនឹងសេចក្តីប្រាថ្នារបស់ម្តាយគាត់ ហើយក៏រៀបការជាមួយពុត សាផារុង នៅក្នុងក្រុមរៀបការទាំងអស់ក្នុង ឆ្នាំ ១៩៧៨ ។ បងស្រីរបស់គាត់ យស់ អែមស៊ីថាន បានរៀបការក្នុងថ្ងៃតែមួយនោះដែរ ។

១០ថ្ងៃក្រោយមក បានបង្ខំគូរៀបការទាំងអស់ឲ្យប្តូរទីតាំងទៅខេត្តពោធិសាត់ នៅប៉ែកពាយ័ព្យនៃប្រទេសកម្ពុជា ។ ម្តាយឪពុក និង ប្អូនស្រី របស់គាត់ក៏សំរេចចិត្តទៅទីនោះជាមួយគ្នាដែរ ហើយក៏ធ្វើដំណើរទៅអ្នកលឿងត្រើយខាងលិច ។ ចាប់ពីកន្លែងនោះពួកគេបានជិះរថយន្តឆ្ពោះទៅខាងជើងទីក្រុងភ្នំពេញដែលគ្មានមនុស្សរស់នៅ ។ ពីភ្នំពេញពួកគេជិះរថភ្លើងឆ្ពោះទៅខាងជើងទៀតតំរង់ទៅពោធិសាត់ ។ ក្នុងកំលុងពេលដ៏ពិបាកនៅក្រោមខ្មែរក្រហមប្តីរបស់

គាត់បានចែកចាយអាហារអ្វីដែលខ្លួនមានដល់គាត់ ហើយជួយលើរបស់របរគាត់នៅពេលដែលពួកខ្មែរក្រហមបង្ខំឲ្យចាកចេញ ។ គាត់មានជំងឺបៅក្លាយលើដៃរបស់គាត់យ៉ាងធ្ងន់ធ្ងរ ហើយគាត់ដឹងយ៉ាងច្បាស់ថាដោយសារតែប្តីរបស់គាត់ជួយលើ សែងឥវ៉ាន់ ទើបគាត់អាចរស់នៅបាន ហើយអត់ទ្រាំក្នុងការធ្វើដំណើរយ៉ាងលំបាកនេះទៅមុខរួច ។

អាន់ទីប៉ូបាត់ដំណឹងសូន្យតាំងពីបែកភ្នំពេញនៅពេលដែលគាត់ទៅលេងសង្សាររបស់គាត់ចំពេលដែលខ្មែរក្រហមវាយចូលទីក្រុង។ គាត់ត្រូវគេបញ្ជូនទៅបាត់ដំបងគឺជាទីក្រុងធំ ទីពីររបស់ប្រទេសកម្ពុជានៅ ប៉ែកពាយ័ព្យនៅជិតនឹងព្រំដែនថៃ ។ ម៉ូលីនៅចាំបានថាពេលដែល អាន់ទីប៉ូ បាននិយាយប្រាប់ថាពួកខ្មែរក្រហមចងគាត់ដើម្បីយកទៅសម្លាប់បីដង ប៉ុន្តែ ៣ ដង នោះឡានដែលដឹកអ្នកទោសយកទៅសម្លាប់នោះពេញទាំងអស់ដែល សូម្បីតែម្នាក់ទៀតក៏មិនអាចញាត់ចូលឡាននោះបាន ។ បន្ទាប់ពីលើកទី៣ អាន់ទីប៉ូ បានរត់គេចទៅប្រទេសថៃហើយបានចូលរួមក្នុងចលនាតស៊ូដែលដឹកនាំដោយអតីតនាយករដ្ឋមន្ត្រី កាលពីក្នុងអំឡុង ឆ្នាំ ១៩៦០ គឺ លោកតា សឺនសាន KPNLF ( ខ្មែរឥស្សរៈ ) ក្នុងរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរដែលប្រយុទ្ធប្រឆាំងនឹងខ្មែរក្រហម ។ គាត់ធ្វើការជាគណនេយ្យករសំរាប់ KPNLF រហូតដល់គេចោទគាត់ថា គាត់លួចលុយ ហើយគេបញ្ជូនគាត់ទៅសមរភូមិមុខ ហើយគាត់បានត្រូវបាញ់ត្រូវរបួសយ៉ាងធ្ងន់ធ្ងរ ។ គាត់បានទៅសំរាកព្យាបាល នៅមន្ទីរពេទ្យក្នុងប្រទេសថៃ រួចក៏បានជាសះពីមុខរបួស ហើយរស់នៅប្រទេសថៃជាមួយគ្រួសារជនជាតិថៃ រហូតដល់គាត់បានជាសះស្បើយមែនទែន ។

ក្នុងឆ្នាំ ១៩៧៨ គឺជាឆ្នាំដែលមានការពិបាកខ្លាំងណាស់សំរាប់ប្រទេសកម្ពុជាព្រោះមានការខ្វះខាតអាហារ ពីព្រោះខ្មែរក្រហមដឹកស្រូវអង្ករចេញយ៉ាងច្រើនទៅប្រទេសចិន និងមួយចំនួនទៀតគេបានយកទៅលាក់ទុក នៅក្នុងរូងភ្នំ ។ ទឹកជំនន់បានបំផ្លាញផលស្រូវឆ្នាំនោះយ៉ាងធ្ងន់ធ្ងរដែលធ្វើឲ្យមាន

អំណាត់ប៉ះទង្គិចយ៉ាងខ្លាំងដល់ប្រជាជនក្នុងឆ្នាំនោះ ព្រោះប្រជាជនមានតែស្រូវអង្ករ នោះហើយដែលត្រូវពឹងអាង ។

ក្នុងថ្ងៃបុណ្យណូអែលឆ្នាំ ១៩៧៨ កំលាំងទ័ពវៀតណាមបានចូលក្នុងប្រទេសកម្ពុជា បន្ទាប់ពីខ្មែរក្រហមបានកាប់សម្លាប់ជនជាតិវៀតណាមដែលរស់នៅតាមព្រំដែនកម្ពុជាវៀតណាម ជាពិសេសនៅកម្ពុជាក្រោម និង តាមដីសណ្តនៃទន្លេមេគង្គ ។ នៅថ្ងៃទី ៧ មករា ១៩៧៩ កងទ័ពវៀតណាមបានទទួលជ័យជំនះ ហើយបានចូលមកគ្រប់គ្រងទីក្រុងភ្នំពេញទាំងស្រុង ។ ចាប់ពីពេលនោះមកគេបានបណ្តេញអ្នកដឹកនាំខ្មែរក្រហមឲ្យទៅលាក់ខ្លួននៅតាមដងភ្នំប៉ែកពាយ័ព្យតាមព្រំដែនថៃកន្លែងនោះហើយ ដែលពួកគេរស់នៅយ៉ាងសុខសាន្តក្រោមការការពាររបស់ពួកទាហានថៃនៅតាមព្រំដែន ។

ទាហានវៀតណាមបានអនុញ្ញាតឲ្យមូល្លី និង គ្រួសាររបស់គាត់ធ្វើដំណើរចាកចេញពីខេត្តពោធិសាត់ ប៉ុន្តែមិនអនុញ្ញាតឲ្យវិលត្រឡប់ចូលទៅភ្នំពេញវិញឡើយ ។ ពួកគេក៏ធ្វើដំណើរទៅព្រៃវែងវិញ ។ សំណាងល្អដែលពួកគេអាចវិលត្រឡប់ទៅឯកន្លែងដែលគេធ្លាប់រស់នៅក្នុងឆ្នាំ១៩៦០ គឺ មិនបានទៅកន្លែងដែលគេរស់នៅកាលពីសម័យ ប៉ុល ពត នោះឡើយ ។ ពេលនោះជារដូវចំរូត ប៉ុន្តែពួកខ្មែរក្រហមដែលរងរបួសហើយបានរត់គេចពីការដេញតាមរបស់ពួកទាហានវៀតណាមនោះបានដុះបំផ្លាញស្រូវនៅវាលស្រែដាក់ថ្នាំបំពុលក្នុងអណ្តូងទឹកបំផ្លាញផ្លូវថ្នល់ និង ផ្ទះសម្បែងជាច្រើនត្រូវខូចខាត ។ គ្រួសាររបស់មូល្លី មានអាហារតែបន្តិចបន្តួចតែប៉ុណ្ណោះ ហេតុដូច្នេះហើយបានជាត្រូវបង្ខំចិត្តឲ្យសុំអាហារពីអ្នកជិតខាងរបស់ខ្លួន ។ ពួកគេធ្វើការជាច្រើនម៉ោងក្នុងការភ្ជួររាស់ និង ដកស្ទូងស្រូវក្នុងស្រែរបស់អ្នកជិតខាងដើម្បីយកកម្លាំងទៅដូរអាហារ និង ស្រូវដើម្បីឲ្យបានបរិភោគ ។ សំរាប់ពេញមួយឆ្នាំនោះគេមានអាហារបំរុងទុកតែបន្តិចបន្តួចប៉ុណ្ណោះដើម្បីទុកបរិភោគ ។ មានមនុស្ស ៦សែននាក់បានស្លាប់ដោយសារការអត់ឃ្លាននៅក្នុងឆ្នាំទី១ ដែលវៀតណាមចូលកាន់កាប់ ។

នៅក្រោមកម្មវិធី ក៥ របស់វៀតណាមប្រជាជនកម្ពុជាណាម្នាក់ដែលគេរកឃើញថាមិនគាំទ្ររបបនោះនឹងត្រូវបញ្ជូនទៅកាប់ព្រៃ និង សង់លេណដ្ឋានការពារប្រឆាំងនឹងខ្មែរក្រហមដែលនៅតាមដងភ្នំនៅក្នុងខេត្តបាត់ដំបង [៣]។

រដ្ឋាភិបាលថ្មី គឺសាធារណរដ្ឋប្រជាមានិតកម្ពុជាដឹកនាំដោយ លោក ហេង សំរិន ជា ស៊ីម និង ហ៊ុន សែន ( ទាំងអស់មានសម្ព័ន្ធភាពជាមួយវៀតណាម ) បានហៅឪពុករបស់មូលី្ល ឲ្យចូលមកបំរើក្នុងរដ្ឋាភិបាលវិញ ដោយមានឋានៈជាអ្នកកសិកម្ម និង ផ្តល់ការរៀនសូត្របន្ត ។ នៅចុងឆ្នាំគំរប់មួយឆ្នាំនៃការរស់នៅក្នុងភូមិកំណើតរបស់ខ្លួននៅព្រៃវែង ពួកគេក៏ធ្វើដំណើរត្រឡប់ទៅរស់នៅឯភ្នំពេញវិញ ហើយមូលី្ល ក៏បានធ្វើដំណើរទៅធ្វើការនៅក្រសួងកសិកម្ម ។ ប្តីរបស់អ្នកស្រីក៏ធ្វើដំណើរទៅធ្វើការនៅទីនោះដែរ ហើយគាត់មានមិត្តភក្តិជាច្រើនដែលជះឥទ្ធិពលអាក្រក់ទៅលើគាត់ ។ ទីបំផុតក៏ចាប់ផ្តើមចាយលុយប្រាក់ខែដ៏តិចតួចទៅផឹកស្រា និង លេងល្បែង ។ នៅពេលដែលកូនទី ១ ចាប់ផ្តើមកើត នៅក្នុងឆ្នាំ ១៩៨១ គាត់មិនបានយកចិត្តទុកដាក់ដល់ការមើលថែមូលី្ល ទេ ឬ ក៏ជួយថែទាំគ្រួសារឡើយ ។ មូលី្ល ព្យាយាមយ៉ាងអស់ពីចិត្តធ្វើយ៉ាងណា ដើម្បីផ្លាស់ប្តូរអត្តចរិតរបស់ប្តីគាត់ ប៉ុន្តែអ្នកស្រីធ្វើមិនបានឡើយ ហើយ អ្នកស្រីក៏សំរេចសុំឈប់ធ្វើការងារមកចិញ្ចឹមកូនដោយខ្លួនឯងដោយគ្មានការជួយពីប្តីគាត់ទេ អ្នកស្រីពឹងផ្អែកទៅលើម្តាយ និង បងប្អូនស្រីៗរបស់អ្នកស្រីសំរាប់ជួយផ្តល់អាហារ និងថវិកាផ្សេងៗសំរាប់បង់ការចាយវាយរាល់ថ្ងៃ ។ ពេលមួយក្នុងដើមឆ្នាំ ១៩៨០ ម៉ូលីបានជួបអៀងម្តងទៀត ។ អៀងកំពុងថ្វាយបង្គំលួចលាក់នៅក្រោមជំនុំតាខ្មៅ ហើយគាត់ក៏អញ្ជើញ ម៉ូលីឲ្យចូលរួមជាមួយគាត់ដែរ ប៉ុន្តែឪពុករបស់មូលី្ល និយាយថា " ទេ ! វាគ្រោះថ្នាក់ណាស់ " ។ មូលី្ល មានការរីករាយពីកិច្ចការខាងឯព្រះវិញ្ញាណ តែបន្តិចបន្តួចតែប៉ុណ្ណោះ

[៣] *កម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហម*

កាលពីឆ្នាំ១៩៧៥ ។ ប៉ុន្តែក្នុងឆ្នាំ ១៩៨៨ ឪពុក របស់អ្នកស្រីចាប់ផ្តើមមានជំងឺលើសឈាម ដូច្នេះមូល្លី ក៏ទៅរកអៀងដើម្បីនាំគាត់ទៅរកគ្រូគង្វាលរបស់គាត់ឈ្មោះ លោកគ្រូ សៀងអង់ដែលអធិស្ឋានឲ្យឪពុកមូល្លី ហើយលាបប្រេងឲ្យគាត់ ។ បន្ទាប់ពីប៉ុន្មានខែក្រោយមកគាត់ក៏អនិច្ចកម្មទៅ ហើយបានទៅនៅជាមួយព្រះអម្ចាស់ ។

ដោយព្រោះគ្រួសារទាំងមូលចង់បញ្ចុះសពឪពុកគាត់តាមរបៀបគ្រីស្ទបរិស័ទជាជាងធ្វើពិធីបូជាដូចជាអ្នកកាន់សាសនាព្រះពុទ្ធនោះ ដូច្នេះពួកគេក៏បានអញ្ជើញលោកគ្រូ សៀង អង់ ឲ្យមកធ្វើពិធីបុណ្យសព ។ ពេលនោះគឺជាខែកក្កដា ឆ្នាំ ១៩៨៨ ។ ពួកគេមិនចាំបាច់ទៅសុំច្បាប់រដ្ឋអំណាចអ្វីទេហើយក៏ធ្វើបុណ្យសពតែម្តង ។ ការធ្វើពិធីបុណ្យនោះធ្វើឡើងធំដុំមែនទែន ។ មិត្តភក្តិជាច្រើនរបស់ឪពុកគាត់មកពីក្រសួងរដ្ឋាភិបាលបានមកចូលរួមក្នុងពិធីនោះដែរ ដូចជាមិត្តភក្តិរបស់ មូល្លី ស៊ីថាន និង កូនៗរបស់ពួកគេដែរ ។ ក្រុមជំនុំដែលលាក់ខ្លួនបានលេចចេញក្រៅជាលើកដំបូងនៅក្នុងពិធីសពនេះ ។ ពួកគេទាំងអស់គ្នាច្រៀងហើយថ្វាយបង្គំព្រះ ។ មានគ្រីស្ទបរិស័ទ មុនឆ្នាំ ១៩៧៥ ជាច្រើន និង អ្នកខ្លះទៀតទទួលព្រះគ្រីស្ទតាមរយៈការផ្សាយដំណឹងល្អរបស់ស្ទែនមូនីហាម ក៏មកចូលរួមក្នុងពិធីបុណ្យសពនោះដែរ ។ ក្នុងនោះមានលោកគ្រូអ៊ឹម ជ្រេន លោកគ្រូ មុត ប៊ុនធី កញ្ញា យង់ សេដ្ឋា លោកស្រី ង៉ែត សំបូរ កញ្ញា ស្រី ហែម និងម្តាយរបស់គាត់ក៏ដូចជាមូល្លី និងក្រុមគ្រួសាររបស់គាត់ ។ មូល្លី និង ម្តាយរបស់គាត់ចងចាំពីក្បួនដង្ហែសពមានក្បួនហែយ៉ាងវែងដែលគាត់ចាំមិនភ្លេចឡើយ ។

ខណៈនោះស្រាប់តែមានបញ្ហាកើតឡើង ដោយមិនគិតជាមុន " តើយើងកប់នៅកន្លែងណា ? " មានគ្រីស្ទបរិស័ទខ្មែរវៀតណាមម្នាក់ ឈ្មោះ លោក ប៉ុល បា បានជួយទាក់ទងព្រះវិហារកាតូលិក ដែលអនុញ្ញាតឲ្យសពឪពុកមូល្លីកប់នៅទីនោះបាន គឺនៅក្នុងទីបញ្ចុះសពកាតូលិកវៀតណាមនៅក្នុងស្រុក

កៀនស្វាយ ដោយគ្រាន់តែឆ្លងស្ទឹងទៅទិសពាយ័ព្យនៃផ្លូវជាតិលេខ ១ ។

តាមរយៈបុណ្យសពនេះ ធ្វើឲ្យមូល្លី ដឹងថាមានអ្នកជឿដែលកំពុងជួបជុំគ្នាដោយសំងាត់នៅជុំវិញក្រុង ។ នៅក្នុងឆ្នាំ ១៩៨៩ បានស្រង់ស្ថិតិថាមានគ្រីស្ទបរិស័ទមិន លើសពី ២០០នាក់ទេដែលថ្វាយបង្គំនៅជុំវិញទីក្រុងភ្នំពេញ ។

មូល្លី បាននិយាយថា " មានថ្ងៃមួយមិនយូរប៉ុន្មានក្រោយពិធីបុណ្យជ្រមុជទឹកជាសាធារណៈនៅស្ទឹងកន្ទួតខាងលិចភ្នំពេញ ( ដែលគេបានធ្វើដោយលួចលាក់នោះ ដែលមានអ្នកជឿប្រហែលជា ៥០ នាក់ ) ខ្ញុំបានឃើញបងស្រីខ្ញុំ ស៊ីថាន បានកាន់ក្រដាសនៅនឹងដៃគាត់ ។ គាត់បានសូមឲ្យគ្រីស្ទបរិស័ទដទៃទៀតចុះហត្ថលេខា ។ នាងមានហត្ថលេខា ១០ សំរាប់សុំការអនុញ្ញាតអ្វីមួយ ។ ពេលនោះបងស្រីគាត់ ធ្វើការនៅក្រសួង អប់រំជាតិ ហើយគាត់មានការគោរពរាប់អានពីអ្នករួមការងារជាមួយគ្នា ។ គាត់បានដាក់ពាក្យសុំទៅមនុស្សសំខាន់ម្នាក់នៅក្នុងជួររដ្ឋាភិបាលដែលបញ្ជូនតទៅទៀតតាមលំដាប់ទីបំផុតពាក្យសុំនោះបានទៅដល់ការិយាល័យក្រសួងធម្មការ និងកិច្ចការសាសនា ។ សំណាងល្អ ស៊ីថាន មានមិត្តដ៏យូរអង្វែងម្នាក់ដែលត្រូវជាប្រពន្ធរបស់មន្ត្រីម្នាក់នៅក្នុងក្រសួងនោះ ហើយគាត់ក៏ជួយសម្រួលឲ្យមានឱកាសក្នុងការចូលទៅជួបប្តីរបស់គាត់ ។ មូល្លី និង បងស្រីរបស់គាត់បានទៅជួបបុរសដែលជារដ្ឋមន្ត្រី នោះហើយនិយាយស្មាបស្ទង់ចិត្តគាត់ថា ៖ " នៅក្នុងរបបនេះយើងគ្មានសិទ្ធិក្នុងការថ្វាយបង្គំតាមប្រពៃណីរបស់យើងឡើយ យើងគ្មានកន្លែងបញ្ចុះសពគ្នាយើង យើងគ្មានសិទ្ធិអ្វីទាំងអស់ តើវាជាការមិនត្រឹមត្រូវមែនដែរឬអត់? តើលោកអាចធ្វើអ្វីម្យ៉ាងសំរាប់យើងបានឬទេ?"

បងប្អូនស្រីត្រកូលយស់ទាំងបី មូល្លី ស៊ីថាន និង សុគន្ធ ជិះកង់ ទៅផ្ទះរដ្ឋមន្ត្រីនោះជារៀងរាល់ថ្ងៃរសៀលអស់រយៈពេលជាង៣ខែ ។ គាត់ចង់រៀនថែមទៀតអំពីជំជឿលើព្រះគ្រីស្ទដើម្បីឲ្យគាត់អាចលើកយកករណីនេះផ្តល់ជាដំណឹងដល់រដ្ឋាភិបាល ។ ជារៀងរាល់ថ្ងៃរសៀលពួកគេច្រៀងទំនុកតំកើងថ្វាយ

បង្គំព្រះបង្រៀនព្រះគម្ពីរ ហើយស្ដាប់ចំរៀងថ្វាយបង្គំតាមកាសែត ។ មន្ត្រីនោះថែមទាំងបានខ្ចីកាសែតចំរៀងស្ដាប់តាមឡានរបស់គាត់ទៅធ្វើការនឹងត្រលប់ពីធ្វើការមកវិញ ។ គាត់បានសួរសំណួរជាច្រើនដែលពួកគេបានឆ្លើយ ។

ក្នុងពេលនោះមូលី បានយល់សប្ដិថាគាត់និងគ្រួសារគាត់កំពុងរត់ជុំវិញស្ដាតអូឡាំពិកស្រែកយ៉ាងរីករាយទៅគ្រប់គ្នាដែលពួនៅពីចំងាយថា៖ " ជយោព្រះយេស៊ូ ! ព្រះយេស៊ូ ! " គាត់មានអារម្មណ៍ថាព្រះមានបន្ទូលមកគាត់ថា ៖ ពួកគេនឹងបានត្រូវផ្ដល់ជ័យជំនះដែលនឹងបំបាត់អំណាចដ៏ខ្លាំងរបស់សាតាំងនៅលើទឹកដីដ៏ជាទីស្រឡាញ់របស់ពួកគេនេះ ។

ក្នុងខណៈនោះបុណ្យរបស់ឪពុកមូលី បានជំរុញឲ្យអ្នកដឹកនាំគ្រីស្ទបរិស័ទក្នុងស្រុកបង្កើតគណៈកម្មាធិការបណ្ដោះអាសន្នមួយដែលមានសមាជិក១០នាក់ (បួននាក់ជានារី ) ដែលដឹកនាំដោយគ្រូគង្វាលស៊ាង[៤] ។ បងស្រីរបស់មូលី យស់ អែមស៊ីថានជាសមាជិកនៃក្រុមប្រឹក្សានោះ ។ ពេលនោះជាខែ មិថុនា ឆ្នាំ ១៩៨៩ ហើយគ្រីស្ទបរិស័ទកំពុងរង់ចាំការផ្លាស់ប្ដូរនៅក្នុងរដ្ឋធម្មនុញ្ញដែលផ្ដល់នូវការអត់អោនយោគយល់ដល់គ្រីស្ទបរិស័ទ ។ នៅក្នុងខែមិថុនា នោះ ដែលប្រឹក្សារបស់រដ្ឋមន្ត្រីអនុញ្ញាតឲ្យគ្រីស្ទបរិស័ទមានសេរីភាពក្នុងការថ្វាយបង្គំដោយជំនឿ ប៉ុន្ដែមិនអនុញ្ញាតឲ្យផ្សាយដំណឹងល្អទេ ។

ក្នុងខណៈពេលដែល យស់ ស៊ីថាន ម៉ូលី និង សុគន្ធ និង អ្នកដទៃទៀតកំពុងនៅតែបន្តជួបជាមួយមន្ត្រីរូបនោះនៅឡើយក្រុមជំនុំកម្ពុជាបានត្រូវគេអញ្ជើញឲ្យទៅចូលរួមសន្និសីទពិភពលោកក្រុងឡូសាន II នៅ ប្រទេសហ្វីលីពីន ។ ពួកគេមិនអាចទៅចូលរួមបាន ប៉ុន្ដែបានបញ្ជូនរបាយការណ៍ពីហេតុការណ៍ដែលកំពុងជួបប្រទះ ។ នេះគឺជាការជូនដំណឹងមួយដល់អស់អ្នក

---

[៤]Don Cormack, *Killing Fields Living Fields: An Unfinished Portrait of the Cambodian Church—the Church that Would Not Die* (Crowborough, East Sussex: OMF, 1997), 391.

ដែលចូលរួមសន្និសីទអធិស្ឋានឲ្យប្រទេសកម្ពុជាមានសេរីភាពជាផ្លូវការសំរាប់សិទ្ធិសាសនា ។

នៅក្នុងថ្ងៃចុងក្រោយ បងប្អូនទាំងបីជួបមន្រ្តីរូបនោះ លោកសួរថា តើពួកគ្រីស្ទបរិស័ទមានធ្វើនយោបាយឬអត់ ? មូលី្ល ពន្យល់ចេញពីគម្ពីរម ជំពូក ១៣ ថាព្រះរើសតាំងអ្នកដឹកនាំប្រទេស ហើយគ្រីស្ទបរិស័ទត្រូវចុះចូល និង អធិស្ឋានសំរាប់អស់លោកទាំងនោះ ។ ពួកគាត់ប្រាប់បញ្ជាក់ថា គ្រីស្ទបរិស័ទ នៅក្នុងប្រទេសកម្ពុជាចង់បានតែសេរីភាពក្នុងការថ្វាយបង្គំមិនចង់រំខាន នៅក្នុងប្រទេសដែលកំពុងតែមិនមានស្ថានភាពនឹងនរនេះទេ ។ ថ្ងៃបន្ទាប់មក លោកបានហៅពួកគាត់ត្រឡប់ទៅម្តងទៀតប្រហែលជាមានអ្វីប្លែកហើយ ដោយព្រោះអ្នកដែលនៅថ្នាក់លើគាត់បាននិយាយអ្វីម្យ៉ាង ហើយមើលទៅ ។ លោកបានសូមពួកគេឲ្យពន្យល់លោកម្តងទៀតឲ្យបានច្បាស់អំពីផ្នែកខាងធ្វើនយោបាយ ។ មូលី្ល បានពន្យល់ម្តងទៀតថា គ្រីស្ទបរិស័ទនឹងគ្មានបំណងបង្កបញ្ហាដល់រដ្ឋាភិបាលឡើយ ។ នៅថ្ងៃអាទិត្យបន្ទាប់នោះគឺ ថ្ងៃទី ៧ ខែ មេសា ឆ្នាំ ១៩៩០ ក្រោយមក១០ខែ បន្ទាប់ពីសន្និសីទឡូសាន ក្នុងកំឡុងពេលថ្វាយបង្គំនៅផ្ទះរបស់ មូលី្ល រដ្ឋាភិបាលកម្ពុជាបានប្រកាសជាផ្លូវការអំពីការទទួលស្គាល់ក្រុមជំនុំគ្រីស្ទបរិស័ទ ។ មួយសប្តាហ៍ក្រោយមកមានវត្តមានតំណាងគ្រីស្ទបរិស័ទ ១៥០០ នាក់បានបង្ហាញមុខចំពោះរដ្ឋាភិបាលក្នុងនោះមានរួមទាំង កាតូលិក និង ប្រូតេស្តង់ទាំងជនជាតិខ្មែរ និង វៀតណាម បានធ្វើពិធីបុណ្យមួយអបអរសាទរសេរីភាពថ្មីជាមួយគ្នានៅក្នុងរោងប្រជុំដ៏ធំជាងគេមួយ នៅក្នុងទីក្រុងភ្នំពេញ ។

រដ្ឋាភិបាលនៅតែបន្តប្រយ័ត្នចំពោះគ្រីស្ទបរិស័ទ មូលី្ល និងស៊ីថាន គឺជាមនុស្សក្នុងចំណោមមនុស្សដទៃទៀតដែលមានគេស៊ើបអង្កេត និង តាមដាន ។ ដោយព្រោះស៊ីថាន គឺជាអ្នកដំបូងគេដែលធ្វើចលនាក្នុងការសុំឲ្យមានសេរីភាពសំរាប់គ្រីស្ទបរិស័ទ រដ្ឋាភិបាលឲ្យគាត់រក្សាភាពប្រុងប្រយ័ត្នយ៉ាងខ្លាំង

ចំពោះការណាមួយក៏ដោយដើម្បីបញ្ជាក់ថាពួកជំនុំមិនធ្វើខុសចំពោះសេរីភាពដែលទើបតែទទួលបាន ។ ការក្តាប់ឲ្យណែនពិតជាមិនអាចទៅរួចបន្ទាប់ពីគ្រីស្តបរិស័ទចាប់ផ្តើមរីកចំរើនយ៉ាងលឿន ហើយបេសកជន និង គ្រប់និកាយបានមកពីប្រទេសផ្សេងៗបានចូលមកប្រទេសកម្ពុជា ។ មានអ្នកផ្សាយដំណឹងល្អម្នាក់មកពីរដ្ឋតិចសាស់ ឈ្មោះ ម៉ៃ អ៊ីវែន ដែលធ្វើឲ្យមានកំហុសឆ្គងសឹងតែនឹងបាត់សេរីភាពម្តងទៀត សំរាប់គ្រីស្តបរិស័ទ នៅក្នុងខែវិច្ឆិកា ឆ្នាំ ១៩៩៤ នៅក្នុងការផ្សាយដំណឹងល្អជាទ្រង់ទ្រាយ ធំមួយខាងផ្នែកប្រោសជំងឺនៅស្តាតអូឡាំពិច ។ មានបេសកជននៅប្រទេសកម្ពុជាជាច្រើនបានផ្តល់គំនិតដល់គាត់មិនឲ្យគាត់ចូលមកទេ ប៉ុន្តែគាត់នៅតែមកពីព្រោះគាត់គិតថាព្រះជាម្ចាស់បានមានបន្ទូលប្រាប់គាត់ឲ្យមក ។ ការផ្សាយដំណឹងល្អនោះ គឺទទួលរងនូវការបរាជ័យដែលមិនបានធ្វើរហូតដល់ចប់តាមការគ្រោងទុក ។ ការផ្សព្វផ្សាយដំណឹងតាមប្រព័ន្ធឃោសនាបានសន្យាថាអស់អ្នកណាដែលចូលរួមនឹងត្រូវប្រោសជាប៉ុន្តែអ្វីដែលបាននិយាយនោះមិនបានកើតឡើងឡើយ ដែលជាហេតុធ្វើឲ្យក្រុមជំនុំជួបប្រទះនូវការរងទុក្ខបៀតបៀនលើកទី១ បន្ទាប់ពីបានទទួលសេរីភាពរួចមកនោះ ។

យស់ មូល្លី យស់ អែមស៊ីថាន យស់ សុគន្ធ យ៉ង ស៊ីថា (អៀង) និងគ្រូគង្វាល សៀង អង់ ជាអ្នកដើរតួសំខាន់ក្នុងការសុំឲ្យមានសេរីភាពសំរាប់គ្រីស្តបរិស័ទ នៅក្រោមការដឹកនាំរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ។ សេរីភាពនោះផ្តល់នូវសេចក្តីអំណរដល់ក្រុមជំនុំអង្គការគ្រីស្តបរិស័ទអង្គការក្រៅរដ្ឋាភិបាល គ្រីស្តបរិស័ទបេសកកជន និង ប្រជាជនកម្ពុជារហូតមកដល់សព្វថ្ងៃនេះ ។

នៅក្នុងខែ តុលា ឆ្នាំ ១៩៩១ នៅពេលដែលមូល្លី ដាក់ពាក្យធ្វើការនៅអង្គការទស្សនៈពិភពលោកកម្ពុជាប្តីរបស់អ្នកស្រីនៅតែលេងល្បែង ។ ពាក្យសុំចូលធ្វើការរបស់ មូល្លី បានទទួលយល់ព្រម ដូច្នេះធ្វើឲ្យអ្នកស្រី អាចទទួល

នូវបន្ទុកនៃការលេងល្បែងរបស់ប្តីអ្នកស្រីបានព្រមទាំងជួយផ្គត់ផ្គង់កូនទាំងបីនាក់ ដោយប្រាក់ខែរបស់អ្នកស្រីផ្ទាល់ ។ ពេលខ្លះប្តីរបស់អ្នកស្រីហាក់បីដូចជា ចង់ផ្លាស់ប្តូរប៉ុន្តែការផ្លាស់ប្តូរនេះមានរយៈពេលខ្លីប៉ុណ្ណោះ ។ ពេលខ្លះគាត់មិនមកផ្ទះនៅពេលយប់ហើយពេលខ្លះលេងល្បែងរហូតដល់លក់ ម៉ូតូមួយ ឬពីរដែលមូល្លីបានទិញដោយកំលាំងញើសឈាមរបស់អ្នកស្រី ។ អ្នកស្រីធ្វើការដំបូងនៅអង្គការទស្សនៈពិភពលោកមានតួនាទីជាអ្នកទទួលភ្ញៀវ និង ជាអ្នកកាន់បញ្ជីសារពើភ័ណ្ឌ ប៉ុន្តែ ក្រោយមកជ្រើសរើសឲ្យធ្វើការកន្លែងការិយាល័យទ្រទ្រង់ប្រតិបត្តិការ ហើយបន្ទាប់មកប្តូរមកកាន់កន្លែងអភិវឌ្ឍន៍ បុគ្គលិក និងការហ្វឹកហ្វឺនខាងព្រលឹងវិញ្ញាណ និង តួនាទី២ទៀតនៅក្រោមផ្នែកការិយាល័យធនធានមនុស្ស ។ នៅក្រោមការិយាល័យផ្នែកហ្វឹកហ្វឺនខាងព្រលឹងវិញ្ញាណអ្នកស្រីជួយអង្គការទស្សនៈពិភពលោកកម្ពុជា ផ្នែកខាងរៀបចំច្បាប់ស្តីពីស្មារបន្ទាល់គ្រប់ជ្រុងជ្រោយរៀបចំ ការប្រកបគ្រួគង្វាលជួយបកប្រែគុណតំលៃរបស់អង្គការទស្សនៈពិភពលោកឲ្យទៅជាភាសាខ្មែរ បង្រៀនបុគ្គលិកខាងផ្នែកព្រះគម្ពីរសំរបសំរួល ការថ្វាយបង្គំថ្ងៃសុក្រ និង វេទិការព្រះគម្ពីរថ្ងៃអង្គាររៀបចំ និងជួយរៀបចំ Retreat ការណែនាំសំរាប់បុគ្គលិកថ្មី ។ នៅក្នុងខែកុម្ភៈ ១៩៩៨ អ្នកស្រីបានផ្លាស់ប្តូរទៅខេត្តកំពង់ធំ ។ ខេត្តកំពង់ធំជិះឡាន ៣ ម៉ោងឆ្ពោះទៅខាងជើងក្រុងភ្នំពេញ ។ នៅឯខេត្តកំពង់ធំ មូល្លី ធ្វើការជាអ្នកហ្វឹកហ្វឺនខាងព្រលឹងវិញ្ញាណ និង អ្នកដឹកនាំផ្នែកអភិវឌ្ឍន៍បុគ្គលិកពិតជាមានការងារពីរពេញពេលសំរាប់អ្នកស្រី ។ មួយឆ្នាំក្រោយមកម៉ូលីត្រូវបានជ្រើសរើសឲ្យក្លាយទៅជាប្រធានផ្នែកប្រតិបត្តិការប្រចាំខេត្តកំពង់ធំ ។ នៅក្នុងខែកុម្ភៈឆ្នាំ ២០០២ ដោយព្រោះគិតគិតពីបញ្ហាគ្រួសារ អ្នកស្រីបានវិល ត្រឡប់មកភ្នំពេញមកទទួលការងារកន្លែងមួយដែលមិនសូវជាមមាញឹកគឺ កម្មវិធីអភិវឌ្ឍន៍សាងសង់សមត្ថភាពប្រចាំតំបន់ ។ ប្តីរបស់អ្នកស្រីទើបតែចាកចោលអ្នកស្រីនៅក្នុងពេលថ្មីៗ ឥឡូវនេះអ្នកស្រីទទួលខុសត្រូវមើលថែកូនបីនាក់ ប្រុសមួយ ស្រីពីរ ។

HONEYCOMB 5/1 ( October 2004): 165–67

# Cumulative Index

Covering eleven (11) *Honeycomb* issues from July 2000 through October 2004

Bowers, Jr., Russell H. "Balancing Praying with Doing" 4/1 (January 2003): 51–59.
________. "'Faith' in the Book of Ruth" 1/2 (October 2000): 68–79.
________. "Fiction or Fact?" 5/1 (October 2004): 130–32.
________. "Forgiving Those who Trespass Against Us" 1/1 (July 2000): 1–10.
________. "Gentle Strength: A Model for Ministry" 5/1 (October 2004): 47–67.
________. "God has Come Close" 4/2 (July 2003): 26–33.
________. "Introduction to Philemon" 2/1 (January 2001): 42–55.
________. "Jonah—The Reluctant Missionary" 3/1 (January 2002): 72–80.
________. "The Key to Joy" 2/2 (April 2001): 64–76.
________. "On Respecting Beliefs and People" 3/1(January 2002): 18–22.
________. "Portrait of a Leader" 4/1 (January 2003): 106–16.
________. "Success and Successors" 2/3 (July 2001): 61–71.
________. "Translating for Understanding" 3/3 (October 2002): 61–79.
________. Introduction and Conclusion to "Writers for Cambodia from Cambodia" 5/1 (October 2004): 12–13.

Caldwell, Darrell. "Book Review: *Poles Apart* by John R.Davis" 1/1 (July 2000): 79–84.

Caldwell, Susan. "An Unexpectedly Precious Gift" 3/2 (April 2002): 75–83.

Chipps, Graham. "Delegation: An Introduction" 4/1 (January 2003): 1–11.
________. "Wholistic Ministry and Mission" 1/1 (July 2000): 24–31.

Choy, Robert. "God and Money, Part One" 1/2 (October 2000): 47–55.

Compain, Alice. "How Can They Believe?" 2/3 (July 2001): 1–7.

Fender, Mark. "Biography: Noun Pheap" 1/2 (October 2000): 97–101.

Forbes, Heather. "Such as These—A Framework for Understanding" 3/2 (April 2002): 1–9.

Gourley, Steve. "Responding to the Rape of Cambodian Children" 3/2 (April 2002): 100–11.

Gray, Laurence. "Do Justice, Love Mercy" 4/1 (January 2003): 75–85.

Heng Cheng. "The Calling and Great Obligation of Church Leaders" 3/1 (January 2002): 12–17.

Jayakaran, Ravi I. "Our Experience with Wholistic PLA's" 2/1 (January 2001) 1–10.

Lepelaar, Rolf. "Human Rights and Responsibilities: Approaching a Biblical Balance" 3/1 (January 2002): 47–55.

Lindquist, Wes: "Missionary–National Relationships" 2/3 (July 2001): 19–30.

Long Sambath. "Faithful Servant" 5/1 (October 2004): 20–22 .

Lopacka, Jane. "Conflict" 1/2 (October 2000): 1–14.

Maher, Brian. "Cambodian Youth in the New Millennium" 1/1 (July 2000): 53–59.
________. "Biography: Molly Yos" 5/1 (October 2004): 137–47.

Maher, Debbi. "Biography: Yos Em Sithan" 2/1 (January 2001): 129–32.
________. "Biography: Yourng Soth" 3/1 (January 2002): 98–102.

Michellotti, Gioia, and Noren Vann Kim. "Glorifying the Creator with our Creativity" 5/1 (October 2004): 1–4.

Miles, Glenn. "A Christian Response to Disability in Cambodia" 3/2 (April 2002): 41–54.
________. "Breakdown of the Cambodian Family" 2/2 (April 2001): 16–23.
________. "Confronting Pornography: Choosing Life" 3/2 (April 2002): 134–38.
________. "Pastors, Fathers, and Shepherds: Models of the Kingdom" 4/2 (July 2003): 16–19.

Miller, Glen, E. "Christian Development in a Buddhist Country" 3/3 (October 2002): 1–22.

Noren Vann Kim. "How God Turned my Mourning into Dancing" 4/1 (January 2003): 158–70.

Ponchaud, François. "Training Adults to Become Christian in the Catholic Church" 2/1 (January 2001): 77–85.

Sam Sarin. "Autobiography: Sam Sarin" 2/3 (July 2001): 100–05.

Saokhon Sireyvath. "My Father and Love" 5/1 (October 2004): 23–24.

Shaw, Douglas. "The Value of Wise Rabbits" 4/1 (January 2003): 30–38.

Sok Nhep Arun. "A Christian Perspective on Corruption" 4/2 (July 2003): 49–55.
________. "Indigenization of a National Church" 2/1 (January 2001): 99–110.
________. "Translating the Bible into Khmer" 1/1 (July 2000): 43–46.

Soun Neang. "A Determined Disabled Daughter" 3/2 (April 2002): 34–40.

Street, Margaret, R. "The Christian and Suffering" 2/2 (April 2001): 38–41.

Truong Leapromluc. "The Heart of the Father" 5/1 (October 2004): 17–19.

Uon Seila. "Bamboo" 2/2 (April 2001): 10–15.
________. "Biography: Christopher LaPal" 2/2 (April 2001): 110–15.
________. "Biography: Ngov Vorn" 3/3 (October 2002): 135–39.
________. "Biography: Samoeun Intal" 1/1 (July 2000): 68–72.
________. "Biography: Seang Aung" 4/2 (April 2003): 73–76.
________. "A Cockfight in a Common Nest" 4/2 (April 2003): 10–15.
________. "The Glow from Amsterdam 2000" 1/2 (April 2000): 41–46.
________. "The Proud Palm Tree" 3/3 (October 2002): 111–14.
________. "Wearing A Helmet" 3/1 (January 2002): 42–46.

Vejlupkova, Linda. "Abigail, the Peace Maker" 5/1(October 2004): 103–12.

Webber, Ian. "Intercession" 2/1 (January 2001): 26–31.

Weese, Wightman. "Seminar Reflections" 5/1(October 2004): 14–16.

Youngquist, Neal. "God and Money, Part Two—Debt and Savings" 2/2 (April 2001): 50–54.
________. "God and Money, Part Three—The Search for True Riches" 2/3 (July 2001): 49–53.
________. "Watch and Pray" 3/3 (October 2002): 115–19.